# ពិធីធ្វើបុណ្យពុទ្ធាភិសេក

## ពីសម័យបុរាណ

លី សុវីរ



**រូបនេះ ខ្ញុំបានពី** : ឧបាសក **លឹម ឈុន** ឧបាសិកា **ចាយ គង់**

ដែលលោកបានធ្វើបុណ្យពុទ្ធាភិសេក ពី :

ថ្ងៃ ១៦ ៗ ៩ ព.ស ២៥៤៧ = ទី ៦ សីហា គ.ស ២០០៣

ព.ស. ២៥៤៨ គ.ស. ២០០៤

4.30
១
www.elibraryofcambodia.org

# ពុទ្ធាភិសេកបុរាណ

**១. អត្ថបទពុទ្ធាភិសេកទី១** បានមកពី

ឃុំគោកខ្ចក ស្រុកកំពង់ត្របែក ខែត្រព្រៃវែង

**២. អត្ថបទពុទ្ធាភិសេកទី២** បានមកពី

ឃុំអរិយក្សត្រ ស្រុកល្វាឯម ខែត្រកណ្ដាល

**៣. អត្ថបទពុទ្ធាភិសេកទី៣** បានមកពី

ឃុំត្រពាំងគរ ស្រុកជើងព្រៃ ខែត្រកំពង់ចាម

**៤. អត្ថបទពុទ្ធាភិសេកទី៤** ជាអត្ថបទ

សម្ដេចព្រះសង្ឃរាជ **ជួន ណាត**

អតីតសាស្ត្រាចារ្យមធ្យមសិក្សា

**លី សុវីរ**

រក្សាសិទ្ធិ

www.elibraryofcambodia.org

# ប្រវត្តិរូបសង្ខេប



**លី សុវីរ**

**លី សុវីរ** កើតនៅថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំរោង ព.ស.២៤៧២ ត្រូវនឹងថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩២៨ នៅភូមិឫស្សីធ្លង់ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង ឪពុកព្រះនាម **លី អែម** ម្តាយព្រះនាម **ខិន ឌ៉ាន់** ។

ពីអាយុ ១ឆ្នាំ រហូតដល់អាយុ ២០ឆ្នាំ នៅជាមួយឪពុកម្តាយខំរកស៊ីបំរើឪពុកម្តាយ គ្មានបានរៀនសូត្រអ្វីទាំងអស់។ លុះដល់អាយុ ២១ឆ្នាំ ឪពុកម្តាយបានអនុញ្ញាតអោយបួសរៀននៅវត្តសិរីមង្គល ហៅព្រៃរវ៉ាយ ដែលជាវត្តកេរដំនែលពីឪពុក ស្ថិតនៅក្នុងឃុំទឹកថ្លា ស្រុកបាភ្នំ ខេត្តព្រៃវែង បួសនៅក្នុងសំនាក់ព្រះតេជព្រះគុណ គង់ឃី ជាព្រះឧបជ្ឈាយ៍. ព្រះតេជព្រះគុណ លី អ៊ុម ជាឧបសម្បទាចារ្យ ។

www.elibraryofcambodia.org

លុះដល់អាយុ ២២ឆ្នាំ បានចេញទៅរៀនភាសាបាលី នៅវត្តព្រៃទំពូង, វត្តព្រែកចង្ក្រានលើ, វត្តសារាវ៉ន, វត្តឧណ្ណាលោម។ នៅក្នុងគ.ស.១៩៥៦ បានប្រលងជាប់ចូលរៀន នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត។ លុះដល់គ.ស.១៩៦៦ បានប្រលងបញ្ចប់បរិញ្ញាប័ត្រទស្សនវិជ្ជាសាសនា នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។

ពេលលាចាកសិក្ខាបទ នៅឆ្នាំ ១៩៦៦ បានធ្វើជាសាស្ត្រាចារ្យនៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ១ឆ្នាំ បានធ្វើការនៅសូណោព្រឹម ២ឆ្នាំ ។

នៅឆ្នាំ ១៩៦៧ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនាង ឡាយ ប៊ុនណា នៅភូមិព្រែកថ្មី ស្រុកកៀនស្វាយ ខេត្រកណ្ដាល មានកូនស្រី ៤នាក់ និងកូនប្រុស ៣នាក់។ បច្ចុប្បន្នស្លាប់អស់ ២នាក់ នៅសល់កូនស្រី ៣នាក់ និងកូនប្រុស ២នាក់ ។

នៅឆ្នាំ ១៩៦៩ បានធ្វើជាសាស្ត្រាចារ្យ នៅវិទ្យាល័យសិរីមង្គល (រកាកោង)។ នៅឆ្នាំ ១៩៧២ ធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យខ្មែរអង់គ្លេស (បឹងត្របែក)។ នៅឆ្នាំ ១៩៧៥ ទៅនៅស្រុកកំណើត។ នៅឆ្នាំ ១៩៧៩ ធ្វើគ្រូនៅសាលាបឋមសិក្សាវត្តបឹងព្រះ។ នៅឆ្នាំ ១៩៨០ ធ្វើជាអ្នកនិពន្ធសៀវភៅសិក្សានៅក្រសួងអប់រំ។ នៅឆ្នាំ ១៩៩៧ ខែតុលា ចូលនិវត្តន៍ ។

**លី សុវីរ**

អតីតសាស្ត្រាចារ្យមធ្យមសិក្សា

រក្សាសិទ្ធ

www.elibraryofcambodia.org

# អារម្ភកថា

ខ្ញុំបានយល់ថា បើជនជាតិណាមួយ ដែលមានអរិយធម៌ពង់វង្សបានល្អ ហើយ មានអរិយធម៌ចេះតែរីកចំរើនឡើងតាមលំដាប់ ជនជាតិនោះ ឈ្មោះថា មាន អរិយធម៌ខ្ពង់ខ្ពស់ ល្អប្រសើរបំផុត នៅក្នុងសកលលោក ។

ការយល់បែបនេះ ធ្វើអោយខ្ញុំខំស្រាវជ្រាវ ពីប្រពៃណីធ្វើពុទ្ធាភិសេក ដែលពុទ្ធបរិស័ទបានធ្វើពីសម័យបុរាណ។ មានឯកសារ ៣ ច្បាប់ ប្រហែលជា កើតមាននៅសម័យឧត្តុង្គ រឺក៏សម័យលង្វែកផងក៏មិនដឹង។ ឯឯកសារ ១ ទៀត មានប្រាកដ នៅពាក់កណ្តាលសតវត្សរ៍ទី ២០ ។

**ខ្ញុំសូមបញ្ជាក់ពីប្រភពឯកសារទាំង ៤ នេះ :**

១. អត្ថបទពុទ្ធាភិសេកទី ១ នេះ ជាសាស្ត្រាស្លឹករឹតខ្នាតខ្លី ដែល ព្រះធម្មវង្សា **សិន ឃឹម** ចៅអធិការវត្តលង្កា ក្រុងភ្នំពេញ ព្រះអង្គបាន ប្រគល់មកអោយខ្ញុំ នៅពេលដែលព្រះអង្គកំពុងមានអាពាធ ជិតសុគត។ ព្រះ ធម្មវង្សា **សិន ឃឹម** ព្រះអង្គមានកំនើតនៅឃុំគោកខ្ចក ស្រុកកំពង់ត្របែក ខែត្រព្រៃវែង។ ឯកសារនេះ មានកំនើតនៅខែត្រព្រៃវែង ។

២. អត្ថបទពុទ្ធាភិសេកទី ២ នេះ ជាសាស្ត្រាស្លឹករឹតខ្នាតខ្លី ដែលអង្គការ FEMC បានទៅថតចំលងពីវត្តខ្សាច់ពោធិអារាម ភូមិខ្សាច់ ឃុំអរិយក្សត្រ ស្រុក ល្វាឯម ខែត្រកណ្តាល ។



www.elibraryofcambodia.org

៣. អត្ថបទពុទ្ធាភិសេកទី ៣ នេះ ជាក្រាំង ដែលអង្គការ FEMC បាន ថតចំលងចេញពីវត្តពោធិវតនារាម ឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។

៤ . អត្ថបទពុទ្ធាភិសេកទី ៤ នេះ ខ្ញុំបានចំលងចេញពីពិធីពុទ្ធាភិសេក ដែលសម្តេចព្រះមហាសុមេធាធិបតី **ជ.ណា** ជោតញ្ញាណោ ព្រះសង្ឃរាជ គណៈមហានិកាយ បានរៀបរៀង នៅពាក់កណ្តាល សតវត្សទី ២០ ។

នៅបណ្តាអត្ថបទទាំង ៤ នេះ មានអត្ថបទ ៣ ខាងដើមជាអត្ថបទបុរាណ ពិបាកមើលណាស់ ឯអត្ថបទទី ៤ ជាអត្ថបទសម័យ ស្រួលអាន ស្រួលយល់ មិន បាច់គិត រឺពិចារណាឡើយ ។

ឯអត្ថបទបុរាណ ៣ ខាងដើម ខ្ញុំបានយកមកអាន ១ ចប់ ជា ២ ចប់ នៅគ្រប់អត្ថបទ , ពាក្យខ្លះខ្ញុំអានមិនរួច , ពាក្យខ្លះខ្ញុំមិនយល់ន័យ , ពាក្យខ្លះ សំគាល់វត្ថុ ខ្ញុំមិនដែលស្គាល់ , ... ពាក្យខ្លះជាពាក្យបាលី ។ ឯឃ្លាខ្លះ រឺល្បះខ្លះជា របស់បាលីសុទ្ធសាត ហើយបាលីទាំងនេះ មិនមែនមានឃ្លា រឺល្បះត្រឹមត្រូវទេ គឺ ជាឃ្លាល្បះតាប់ដាក់ ធ្វើអោយខ្ញុំមិនយល់ មិនចេះ ខ្ញុំមិនអាចកែបាន ធ្វើអោយ ខ្ញុំភាថយ អស់រយៈពេលជិត ១ ឆ្នាំ ។

តែនៅពេលក្រោយមក ខ្ញុំបានយល់ថា

១. ខ្លួនបានកើតនៅចុងសម័យនោះផង

២. ខ្លួនបានរៀនអក្សរបែបនេះខ្លះផង

ខ្លួននៅតែខ្លាចសំនេរបែបនេះ ទំរាំគ្នាខ្លះ មិនដែលបានឃើញបែបនេះផង



www.elibraryofcambodia.org

ខ្លះធ្លាប់បានឃើញដែរ តែមិនអាចមើលបាន។ ចុះបើគ្នាចង់ដឹងពីអរិយធម៌ខ្មែរ ពីរបៀបធ្វើពុទ្ធាភិសេក ពីសម័យបុរាណ តើអោយគ្នាធ្វើបែបណា ?

កាលបើមានការយល់ឃើញបែបនេះវិញ ទើបមានការបង្អំចិត្តខ្ញុំ អោយចាប់មើល ចាប់គិត ចាប់ធ្វើឯកសារទាំង ៣ នេះឡើងវិញ ក្នុងគោលបំនងដើម្បីធ្វើឯកសារទាំង ៣ នេះ អោយក្មួយទាំងអស់មើលអត្ថបទនេះបាន និងយល់ន័យក្នុងអត្ថបទនេះបាន អំពីប្រពៃណីធ្វើពិធីពុទ្ធាភិសេក របស់សង្គមខ្មែរ ពីសម័យបុរាណផង ។

តែពាក្យខ្លះ ខ្ញុំមើលមិនរួច មិនយល់ន័យ ខ្ញុំបានសរសេរតាមការយល់ ប្រាកដជាមានការខុសឆ្គង។ បើពាក្យបាលីវិញ ខ្ញុំបានចេះបាលីខ្លះៗ ពាក្យខ្លះខ្ញុំយល់ ខ្ញុំកែសំរួល តែពាក្យខ្លះដែលខ្ញុំមិនយល់ ខ្ញុំទុកនៅដដែល ។

**សំនូមពរ :**

បើលោកអ្នកអាន បានមើលឃើញថា ពាក្យណាក៏ដោយ ខ្ញុំបានសរសេរខុសក្តី មិនត្រូវន័យក្តី សូមមេត្តាជួយកែសំរួល និងសូមផ្តល់យោបល់មកអោយខ្ញុំ ដើម្បីអោយខ្ញុំបានចេះយល់ផង និងបានកែពាក្យនៅក្នុងអត្ថបទសៀវភៅនេះផង ពីព្រោះ ពាក្យនៅក្នុងអត្ថបទនេះ មានការពិបាកយល់ណាស់ ។

១. សំនេរបុរាណ គឺលោកសរសេរតាមការនឹកឃើញ តាមការយល់ឃើញរបស់ខ្លួន ពីព្រោះនៅសម័យនោះ មិនទាន់មានក្បួនសំនេរនៅឡើយទេ :

ឧ - ចាមរ > ច្ចាំម៉រ , ចាំម៉រ , ចាំ្យម៉រ្យ , ...



www.elibraryofcambodia.org

- បែមន់ > ព្យមន្ត្រ , ព្យរមុន , ពារមន់ , ...

- បេឆា > មេន្ឆា , ...

- កម្ទប > កន់ទុប , កញ្ចុប , ...

២ . ព្យញ្ជនៈប្រកប សរសេរដូចជាផ្ញើជើង

ឧ - ឡើង > ល្ងើ , ឡើយ > ល្យើ

- ទាំង > ទ្វាំ , បាំង > ប្វាំ

- ហើយ > ហ្យើ , កើយ > ក្យើ

៣ . សញ្ញាព្យញ្ជនៈ "ត" ប្រើជា "ដ" ផង ជា "ត" ផង

ឧ - ដាក់លើ > តាក្លលើ , តាក់តែង > តាក្វតែ្ង

- ដាក់ក្រោម > តាក្លក្រោ , តុបតែង > តុ្ប តែ្ង

៤ . សញ្ញា "ឡ" មិនឃើញមានប្រើនៅក្នុងអត្ថបទទាំង ៣ នេះទេ ពីព្រោះ ព្យញ្ជនៈ "ឡ" ប្រើជា "ល"

ឧ - ពាក្យឡើង > ល្ងើ , តាំឡើង > តម្ងើ

៥ . ពាក្យនៅក្នុងឃ្លាក្តី ក្នុងល្បះក្តី បុរាណបាននិយាយថា

- ប្រាក់តំលឹង ៥ = ប្រាក់ ៥ តំលឹង

- សំពត់សហត្ថ ៥ = សំពត់ស ៥ ហត្ថ , ...

៦ . ពាក្យបាលី ដែលលោកយកមកប្រើនៅក្នុងអត្ថបទនេះ ពិបាកយល់


www.elibraryofcambodia.org

ណាស់ ពីព្រោះ ពាក្យខ្លះគ្មានវិភត្តិ . ពាក្យខ្លះមានវិភត្តិដែរ តែពាក្យខ្លះត្រូវដាក់ខាងមុខ មកដាក់ក្រោយ ធ្វើអោយពិបាកយល់ណាស់។ ពាក្យខ្មែរខ្លះ ជូនកាលយារក្លាយចេញពីភាពដើម

ឧ - មេឆា > មេន្មា . កច្ឆប > កន្ធាប

បើពាក្យខ្មែរ អាចកាត់យល់បាលខ្លះ តែបើជាពាក្យបាលីវិញ ពិបាកយល់ណាស់ ។

៧ . នៅក្នុងអត្ថបទនេះ មានពាក្យខ្លះ បើទុកជាខ្ញុំខំមើលហើយមើលទៀត នៅតែយល់ពុំបាន ខ្ញុំត្រូវទុកនៅដដែល ដូចជា

ភូមា . ឱដ្ឋា . សូតិ . ព្រឹស . កន្ទុយមាន់ . អក្ខុសនៈ . តទូ . បយ្ហូវិ . នី . ចក្ខុមារេ .ចក្ខុតោភិ . ...

៨ . នៅក្នុងអត្ថបទទាំង ៣ នេះ ខ្ញុំបានកែសំនេរបុរាណ មកជាសំនេរបច្ចុប្បន្នប៉ុនោះ ឯន័យសេចក្ដីនៅក្នុងឃ្លា . ល្បះ ខ្ញុំទុកនៅដដែលដូចដើម ។

**សូមចញ្ជាក់**

ខ្ញុំជាអ្នកកាន់ព្រះពុទ្ធសាសនា ថែមជាអ្នកបានរៀនព្រះពុទ្ធសាសនាផងខ្ញុំមិនយល់ថា អត្ថបទពុទ្ធាភិសេកទាំង ៣ នេះ ជាច្បាប់មានភាពវិសេសវិសាលជាងច្បាប់ដទៃ រឺប្រសើរជាងច្បាប់សម្ដេចសង្ឃរាជ **ជួន.ណាត** ដែលព្រះអង្គបានសរសេរទុកមកនោះ រឺប្រសើរជាងរបៀបដែលគេបានធ្វើ នៅសម័យបច្ចុប្បន្ននេះក៏ទេដែរ ។


www.elibraryofcambodia.org

ខ្ញុំគ្រាន់តែចង់បញ្ជាក់ ពីរបៀបធ្វើពុទ្ធាភិសេក ដែលពុទ្ធបរិស័ទបានធ្វើពី សម័យបុរាណនោះ មានលក្ខណៈបែបណា។ បើយើងយករបៀបធ្វើពុទ្ធាភិសេក ពីសម័យនោះ មកប្រៀបធៀបនឹងរបៀបធ្វើពុទ្ធាភិសេក នៅសម័យពាក់កណ្តាល សតវត្សទី ២០ គឺសម័យសម្តេចព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃរាជ **ជួន.ណាត** បានធ្វើអត្ថបទពុទ្ធាភិសេកផង និងសម័យបច្ចុប្បន្ន ដែលពុទ្ធបរិស័ទ បានធ្វើពុទ្ធាភិសេក ព.ស ១៥៤៧ ផង តើមានលក្ខណៈបែបណា ?

បើយោលទៅលើទ្រឹស្តីព្រះពុទ្ធសាសនា បើយើងមានព្រះពុទ្ធបដិមា យើងនិមន្តព្រះសង្ឃមក ជយន្តោ ហើយគោរពថ្វាយបង្គំ ជាការល្អប្រពៃណាស់ទៅហើយ , រីយើងគ្រាន់តែសំគាល់ក្នុងចិត្តថារូបនេះ ជារូបស្នងព្រះពុទ្ធ ហើយគោរពថ្វាយបង្គំ ជាការល្អប្រសើរណាស់ហើយដែរ ។

សូមលោកបញ្ញវន្តទាំងអស់ មេត្តាជួយរិះគន់ស្ថាបនា ដោយសេចក្តីអនុគ្រោះផងចុះ ។

ថ្ងៃ ១៨ ខែ ធ្នូ ឆ្នាំ ព.ស ២៥៤៧ / គ.ស ២០០៣

**ឈី. ស៊ុវីរ**

សាស្ត្រាចារ្យ មធ្យមសិក្សា

រក្សាសិទ្ធិ

www.elibraryofcambodia.org

*ឯកសារទី១*

# វានអភិសេកព្រះ

វានខាងក្រោមនេះ ខ្ញុំបានពីព្រះធម្មវង្សា **ស៊ិន ឃីម** ចៅអធិការ វត្តលង្កា។ ពេលព្រះអង្គជិតព្រះអនិច្ចធម្ម លោកបានប្រគល់មកអោយខ្ញុំ ហើយព្រះអង្គបានប្រាប់ខ្ញុំថា វាននេះបានពីប្អូនរបស់អាត្មានៅឃុំ គោកខ្ចក ស្រុកកំពុងត្របែក ខេត្ត ព្រៃវែង ។ វាននេះ ជាកេរមរតក ពីជីតារបស់អាត្មា ។

សូមអាចារ្យយកវាននេះ ទៅទុកអោយបានគង់វង្សផង ។



www.elibraryofcambodia.org

# នេះវានអភិសេកព្រះ

នេះនឹងស្រដី ឯច្បាប់រណ្តាប់អភិសេកអង្គព្រះពុទ្ធរូបថ្មីនោះជាដើម គឺមាន នៅគ្រឿងអដ្ឋបរិក្ខារទាំង៨ជំពូកគឺ :

| | | | | | |
|---|---|---|---|---|---|
| ១. | បាត្រ | ១ | ៥. | វត្ថពន្ធ | ១ |
| ២. | ស្បង់ | ១ | ៦. | ស្បង់ស្រង់ទឹក | ១ |
| ៣. | ចីពរ | ១ | ៧. | កាំបិតកោរ | ១ |
| ៤. | សង្ឃាដី | ១ | ៨. | ម្ជុលតែងដេរស្បង់ | ១ ។ |

នេះឯងហៅគ្រឿងអដ្ឋបរិក្ខារទាំង ៨ជំពូកហោង ។

ព្រោះកាលព្រះពុទ្ធដ៏អម្ចាស់នៃយើងនេះ ស្តេចចេញទៅទ្រង់ព្រះផ្នួសនោះ មានព្រហ្ម ១ នៅឋានអកនិដ្ឋព្រហ្ម បាននាំគ្រឿងអដ្ឋបរិក្ខារទាំង៨ជំពូកនេះឯង ដាក់ថ្វាយចុះមកថ្វាយព្រះអង្គហោង។ រីឯគ្រឿងបរិក្ខារឯទៀតក្រៅពីនេះតាម ដោយចិត្តសទ្ធាហោង ។

ហើយទើបអោយធ្វើនូវចាមរ បៃមន់ សែនត្លែន ជាគ្រឿងប្រដាប់នឹងដង្ហែ ព្រះអង្គនោះគឺ : ចាមរ១គូ , បៃមន់ ១គូ , សែនត្លែន ១គូ , ឆត្រឬត ១គូ , អភិរម ១គូ , ឱង្គា ១គូ , ព្រឹស ( ព្រឹសភៈ ) ១គូ , ស្វេតិ ១គូ , ព្រះខ័ន ៤ , តំបង មូល តំបងជ្រុង ១គូ , កន្ទុយកោន់ ១គូ , ទៀនព្រះឆព្វណ្ណរង្សី ១គូ នីមួយៗ ទំងន់តំលឹង១ , ទៀនជ័យ១ ប្រវែងកំពស់ព្រះអង្គ។ ហើយអោយមានដើម ពោធិនាពព្រឹក្ស ឯដើមពោធិនាពព្រឹក្សនោះ អោយយកស្លឹកស្បូវភ្លាំង ១ កណ្តាប់ដៃ នៅស្លឹកពោធិ ៧មកចងជាមួយគ្នា ហើយទុកក្រោយអាសន៍ព្រះ ទើប



www.elibraryofcambodia.org

អោយរៀបធ្វើនូវរូបភាពគឺរូបសត្វអម្រឹក , បក្សាបក្សី , មេឆា , កច្ឆប សព្វសារពើទាំងឡាយ ហើយទើបរៀបគ្រែបញ្ចត្តបវរពុទ្ធអាសន៍ ក្រាលនូវកំរាលចៀមចំព្រៃព្រំទន់ ទើបស្រេចស្រាប់គ្រប់ហើយ អោយទៅនិមន្តអង្គព្រះពុទ្ធរូបឯណាដែលចាស់មកជាគ្រូ នៃព្រះពុទ្ធរូបកសាងថ្មីនោះ ហើយអោយនិមន្តមកដាក់តំកល់ពួតលើកំរាល ហើយអោយយកអង្គព្រះពុទ្ធរូបកសាងថ្មីនោះមកដាក់ជាមុខនៃព្រះពុទ្ធរូបចាស់នោះបោង។ ហើយទើបអោយអាចារ្យរៀបបើកព្រះនេត្រព្រះពុទ្ធរូបថ្មីនោះ។ ឯរណ្ដាប់នោះ ព្រាក់តំលឹង ៥ , សំពត់សហ្ត ៥ , ស្លាដម ៤ , ចំទីបង្អែម ៤ , ទឹកអប់ ស្រាដបពីរ , ក្បាលជ្រូក ១ពូ នេះសឹងដាក់ឆ្វេងស្ដាំ។ ទើបអោយអាចារ្យសូត្ររំងាប់ ស្តូតី រួចអោយសូត្រគាថានេះ។
សិទ្ធិកិច្ចំ សិទ្ធិកម្មំ សិទ្ធិការា តថាគតស្ស ពុទ្ធស្ស មេត្តា នត្ថិ រោគា ភវន្តុ តេ ។

រួចហើយអោយយកម្ជុលចូលទៅបើកព្រះនេត្រព្រះអង្គ។ កាលនឹងបើកនោះ

អោយសូត្រថាដូចនេះ { ចក្ខុមារេ / ចក្ខុសោតិ } ម.អ.ឧ { - ស្ដាំ / - ឆ្វេង } រួចហើយ

អោយយកផ្កាជ្រលក់ក្នុងទឹកសម្បួរ ហើយស្រពព្រះភក្ត្រព្រះអង្គនោះ អោយ

សូត្រដូចនេះ { - ពុទ្ធំ / - ធម្មំ / - សង្ឃំ } ចក្ខុទិព្វសោតំ វិសោធយិ។ ហើយអោយយក

ប្រុស ៤ ស្រី ៤ មកបង្វិលពពិល។ កាលនឹងបង្វិលនោះអោយសូត្រថា ឥមស្មឹ រាជគលំ សុរក្ខន្តុ។ លុះសូត្ររួចបង្វិលរួចហើយ អោយសូត្រសសើរព្រះអង្គកាលនៅជាមហាក្សត្រនោះដូចនេះ :



www.elibraryofcambodia.org

យើងខ្ញុំបង្គំ ទសករប្រណម ទុកលើសិរសា
សសើរព្រះអង្គ កាលជាក្សត្រា សោយរាជ្យនៅនា
កបិលភ័ស្តុបូរី ។

សោយរាជ្យសម្បត្តិ ប្រសាទរោងរត្ន ព្រះស្នំជលស្រី
ប៉ែតម៉ឺនសែនពាន់ សំរាប់រាត្រី ស្តេចគង់នៅនៃ
ទែនកែវរត្នផ្ទង់ ។

កាលនោះសម័យ ព្រះអង្គជៀវស្ទួជ័យ មានព្រះចំនង់
ដើម្បីយាត្រា លេលាព្រាច់ត្រង់ ចេញបន្លែងបង់
លេងរាជឱទ្យាន ។

ព្រះតោយបន្លែង ព្រះនេត្រទើបឯង ទតទៅសព្វប្រាណ
ការស់រស់ភ្ញីផង ល្អរល្អងរូបហាន ធ៌រធុំសព្វប្រាណ
ត្រលប់គន្ធា ។

ខ្លះរីកខ្លះរោយ ស្រពោនជ្រុសដោយ សព្វប្រុកមាតា
ព្រះសោបបន្លែង លង់ព្រុះចិន្តា ការស់រស់បុផ្ផា
រុះរោយបាត់បង់ ។

ស្តេចគិតរំពឹង អនិច្ចាវិពរឹង ផ្កានប៉ុរីត្រង់
យល់មិនទៀងទេ សឹងប្រែពុំគង់ នៅនាវដ្តសង្ស
សត្វនានាណា ។

នោះទើបស្តេចចូល ថ្កានរាជអំបូរ នៃមហាក្សត្រា
ព្រុះដល់រោងរត្ន ប្រសាទរចនា ទែនទើបសោភា
ប្រសើរមង្គល ។


www.elibraryofcambodia.org

ស្ដេចឡើងទៅផ្ទំ លើរត្នសូត៌សប បន្ទំផ្ដើងផ្ដល់
ស្ដេចមើលអស់ស្រី ព្រះស្នំស្ដេចយល់ ពរង់ពរក់សោតសល់
ដូចខ្មោចស្មសាន ។

ខ្លះដេកផ្កាប់មុខ ខ្លះសោតស្រមុក សោតសឹងតែមាន
ខ្លះផ្ងារស្ដួកស្ដឹង រិលរឹងប្រែប្រាណ ហៀរទឹកមាត់មាន
សក់សោតរសាយ ។

ខ្លះនៅទាំងភ្លុង ជើងដៃត្រយូង ត្រយាងរាយមាយ
ស្លើតស្លក់មុខវៀច បាកក់គលដូចព្រាយ មាត់ខាំញញាយ
សង្កូតធ្មេញផង ។

អ្នកខ្លះរំសាយ សក់សោតអន្លាយ រសាយចំនង
អ្នកខ្លះមមើ មមោយសោតហោង រាងស្ដួកស្ដឹងផង
មានភ្នែកស្លឹតស្លៃ ។

ទើបស្ដេចអនិច្ចា ថារូបនេះណា សោតសឹងតែប្រែ
សឹងស្រោយឥតខ្លឹម ទេទឹមឥតតង រូបអើយស្មូនទេ
ឥតខ្លឹមមួយអង្គ ។

ទើបស្ដេចយាត្រា អុចទៀនឈ្វាលា នាងផ្ទំលក់លង់
អស់ស្រីព្រះស្នំ ដេករំពឹកអង្គ ទើបស្ដេចគិតចង់
ចេញបួសវៀងស្ថាន ។

គិតកាលអធ្រាត្រ ហៅឆន្នអាមាត្យ មកគិតតែបាន
ព្រះស្ដែងយកសេះ កំហែងបៅហាន ចងគ្រឿងនូវអាន
នាំមកលេងថ្វាត់ ។


www.elibraryofcambodia.org

ទើបឆន្ទអាមាត្យ ក្រាបលាព្រះបាទ ទៅដល់រោងរត្ន
យកសេះធំមួយ ប្រវែង១០ហត្ថ គួរនូវមហាក្សត្រ
ចងគ្រឿងរចនា ។

កំលាំងជាញជ័យ សម្បុរសខៀវខ្ចី ដូចផ្កាក្តាំងងា
កំលាំងសោតច្រើន ឥតគណនា នាំថ្វាយក្សត្រា
ព្រះបរមនាថ ។

អស្ចារ្យមហិមា ទោះទាំងទេវតា មួយម៉ឺនលោកធាតុ
សឹងមកបង្គំ ប្រណម្យភាវនា ទើបស្តេចអធិច្ឋា
អធិដ្ឋានស្មោះ ។

ទោះអញទៅបាន សប្តិពេជ្រតាញាណ ត្រេចត្រាចំពោះ
ទ្វារខ្ទាប់ប៉ុន្មាន សូមបានរង្គោះ ដូចចិន្តាស្មោះ
នៃអញនេះម្តង ។

តែជះសម្តោ ព្រះអង្គប្រាថ្នា បានដូចបំណង
រនុករុករាំង បើកបាំងក្រផង តែជះស្តេចផ្សង
របើកមាត់ទ្វារ ។

ទើបស្តេចលើលា ដល់រាជមាតា រាល័យសង្ហារ
នឹងចូលទៅថើប រាហុលកុមារ ខ្លាចក្រែងនាងនាថ
រលឹកឡើងណោ ។

ទើបស្តេចពិតពិល ព្រះនេត្ររមិល នាងសន្ទ្រា
ហាក់ដូចនឹងសើច ដូចនឹងចរចា អោយអាយសោភា
ប្រពៃគ្រប់លក្ខណ៍ ។



www.elibraryofcambodia.org

រីអស់ស្រីផង     គួរអោយខ្ពើមហោង     មិនគួរពុំនាក់
គួរតែនូវខ្ពើម     រអើមប្រត្យក្ស     ទើបស្តេចប្រែភ័ក្ត្រ
ចេញបួសលែងខ្ចី ។

ទើបស្តេចត្រអាល     ទៅដល់ផ្ទៃរទ្វារ     ផែលឡើងពាជី
ពាជីសោតស្គាល់     ដើមព្រះភូមិ     ចេញសាងបារមី
ស្តេចគ្រាឯងហោង ។

ព្រះអង្គសីហនាទ     ហៅឆន្ទអាមាត្យ     ចេញទៅជាមួង
អោយកាន់កន្ទុយ     សេះស្តេចហោះផ្សង     ហាហៀវរំលង
លើរាជពិភព ។

កក្រើកសូពា     ទាំងឆកាពោ     ព្រហ្មលោកស្ទែងស្ទប់
ភ្នំមាលាផ្កា     គ្រប់គ្រាន់សព្វគ្រប់     គ្រប់គ្រាន់ពេញភព
ពរសាធុការ ។

ព្រះព្រហ្មទ្រង់ឆត្រ     ព្រះឥន្ទហោះថ្វាត់     ទ្រមាត់អស្សា
ព្រះចតុលោកបាល     ទ្រជើងអស្សពាហ៍     រំលែងហោត់ទ្វារ
ចេញចរយាត្រា ។

សូត្រដល់ត្រង់នេះ អោយលារៀបដង្ហែព្រះអង្គសិន ។

កាលរៀបដង្ហែនោះ អោយរើសសឹងប្រុសកំលោះកាន់គ្រឿង ចាមរ. បៃបន់. សែនត្វូន  នូវអស់គ្រឿងទាំងឡាយនោះ អោយសុទ្ធសឹងប្រុសកំលោះហោង។ ទើបរើសប្រុសម្នាក់ អោយស្លៀកបួលពណ៌ខៀវ ធ្វើជាព្រះឥន្ទកាន់ស័ង្ខ ដើរមុនព្រះអង្គ ហើយអោយរើសប្រុសម្នាក់វិញទៀត អោយស្លៀកសធ្វើជាព្រះព្រហ្មកាំងឆត្រ ទើបអោយរើស៤នាក់ទៀតស្លៀកបួលពាក់លឿង ដៃកាន់នូវព្រះខាន់



www.elibraryofcambodia.org

ទាំង៤ ធ្វើជាព្រះចតុលោកបាលទាំង៤ ដើរដង្ហែព្រះអង្គ ហើយអោយរើសម្នាក់វិញទៀត អោយស្លៀកបូលពាក់សធ្វើជាព្រះព្រហ្មបាំងឆត្រ ដើរដង្ហែព្រះអង្គអមទាំងសងខាងរៀងទៅ។ ទើបអោយរើសម្នាក់វិញទៀត អោយស្លៀកបូលពណ៌ក្របាម ធ្វើជាឆន្នអាមាត្យពន្លសជីវី អោយដើរតាមក្រោយ ។

លុះដល់ដង្ហែព្រះអង្គចេញទៅផុតអំពីក្លោងទ្វារ មានមារមកឃាត់អំពីមុខ អោយឈប់សិន។ ទើបអោយម្នាក់ទៅសូត្រពាក្យខាងមារ ដែលឃាត់ថាដូចនេះ :

កាលស្ដេចចេញទៅ មានមារមួយក្លៅ មកឃាត់តវ៉ា
ថាព្រះសិទ្ធត្ថ អ្នកកុំយាត្រា ចេញសាងចរិយា
នេះយល់ជាឆ្គង ។
អ្នករើបសម្បត្តិ បបាចក្រពត្តិ- ធិរាជនោះហោង
នៅ៧ថ្ងៃ នោះនៃស្ដេចផ្ដង អោយអ្នកឯងហោង
តាមចិត្តប្រាថ្នា ។

(ចប់មារ)

ទើបព្រះអង្គឆ្លើយ ថាវើយមារអើយ កុំបឹងចរចា
សម្បត្តិអស់នោះ អញពុំប្រាថ្នា អញខ្ពើមណាស់ណា
ឥតគេពេញនាបាន ។
សម្បត្តិនោះនៃ ស្មើកំហាកវិស័យ អង្គអញមិនមាន
គួរអោយអញខ្ពើម រអើមក្នុងប្រាណ អញពុំចង់បាន
សម្បត្តិសង្សារ ។



www.elibraryofcambodia.org

( ចប់ព្រះអង្គ )

ទើបក្រុងមារឆ្លើយថា

ឱះឱ ! អ្នកអើយ សម្បត្តិដល់ហើយ អ្នកពុំប្រាថ្នា
អស់ទាំងសម្បត្តិ អ្នកកាត់ចេញណា ត្រង់បុត្រភរិយា
គួរអោយសង្វេគ ។
ហើយអ្នកនឹងបាន ជាមហាក្សត្រក្សាន្ត ម្ចាស់ទ្វីប៤នៃ
យសអ្នកផុតផ្ទើង រុងរឿងថ្លាថ្លៃ ដូចពាក្យខ្ញុំនៃ
ពិតពុំមុសា ។

( ចប់មារ )

ព្រះអង្គឆ្លើយទៅ ថាមារកំពៅ កុំមីងចរចា
អស់ទាំងយសសក្តិ អញពុំប្រាថ្នា ទោះបុត្រភរិយា
ពុំមានសង្វេគ ។
យកអ្វីមិនបាន នឹងពេជ្រតាញណ្ហា នាំសត្វនោះនៃ
នាំអស់ទេវតា នូវសុភាល័យ រុំយមារចង្រៃ
ចូលមឹងចេញទៅ ។

ផ្ចាញ់មាររួចហើយ អោយតាំងភូមា ៣ជង់ ហើយអោយដង្ហែព្រះអង្គ ប្រទក្សិណទៅហោង ។ លុះប្រទក្សិណ ៣ជុំហើយ អោយយារនៅមាត់ទ្វារសិន ។ ទើបអោយរៀបដាក់ព្រះកេសព្រះអង្គ នេះអង្គព្រះពុទ្ធរូបតូច ឯព្រះជីវីធំ អោយដង្ហែតែត្រៃហោង ។ ឯរណ្តាប់ដាក់ព្រះកេសនោះ ស្លាធម៌ ១គូ . ទៀន ១គូ . ធូប ១គូ . ផ្កា ១គូ . ប្រាក់ស្លឹង ៤ . ទឹកសម្បូរ ១ផ្តិល . កន្ទោង ១ ហើយទើបយក



www.elibraryofcambodia.org

ព្រដាសក្តិ ស្លឹកចេកក្តី មកធ្វើជាសជី ហើយគ្របទៅលើម្ហូលព្រះ ទើបអោយព្រះខ័នមកកាត់អបទេសក្រវាសចេញពីព្រះកេសព្រះអង្គ ៣ដង ហើយយកកាំបិតកោរ មកកោរក្រវាស ៣ដង រួចហើយដាក់ទៅក្នុងកន្ទោងនោះ ទើបយកកន្ទោងនោះមកបន្ទួលឡើង បោះឡើងទៅលើហោង ។

រីឯកាត់កោរអោយសូត្រដូចនេះ :

**ឱកាស អហំ ភន្តេ សព្វសិរីសា ពុទ្ធំ មហានិក្ខមំ ធារមី ២**

សូត្របីចប់ហើយ ទើបកាត់កោរទៅហោង ។

លុះកាត់កោររួចហើយ អោយយកទឹកអប់គន្ធពិដោរ នូវសម្បូរមកកក់ស្រង់ជីរះ ព្រះកេសព្រះអង្គហោង។ លុះស្រង់ស្រេចហើយដង្ហែព្រះអង្គ ចូលទៅគំកល់នៅលើរាសនាដូចដែលវិញហោង។ ហើយទើបយកអំបោះទៅព័ទ្ធអំពីព្រះពុទ្ធរូបចាស់ មកអង្គព្រះពុទ្ធរូបថ្មី ហើយអោយយកអស់គ្រឿង ចាមរ . បៃបន់ . សែនគ្វាន់ នៅអស់រូបភាពគឺ សត្វអប្រិកបក្សីបក្សា មេឆា កច្ឆប សព្វសារពើទាំងឡាយនោះមករៀបជាជួរ សងខាងរាសទីព្រះរៀងទៅមុខព្រះអង្គហើយអោយយករំបោះមកព័ទ្ធសីមា។ **ឥមស្មឹ រាជគលំ សុរត្ថន្ត** ។ រួចហើយអោយនិមន្តព្រះគម្ពែងសង្ឃ សូត្រព្រះទិព្វមន្ត ព្រះមហាសម័យ ទើបអោយអញ្ជើញអស់ទេវតា ទាំង៨ទិស នូវព្រះយមរាជ មកជាសាក្សីហោង។ លុះសូត្រព្រះទិព្វមន្តរួចហើយ អោយនិមន្ត ទេសនា ព្រះធម្មគោរពព្រះមហាល័យ ព្រះមាតុគុណ ព្រះបឋមត្រាស់ ។

លុះទេសនារួចហើយ អោយរកប្រុស៤ ស្រី៤ មកអង្គុយកាន់ផ្កាស្លា ក្លួមទាំង៨នោះ។ ឯប្រុស-ស្រី សឹងអោយភាវនាអង្គព្រះសីមាជាន់ពីងហោង។ ឯប្រុស ៤នាក់នោះ ម្នាក់ថាដូចនេះ **សម្មាទិដ្ឋិ** . ម្នាក់ទៀតថា **សម្មាសង្កប្បោ** .



www.elibraryofcambodia.org

ម្នាក់ទៀតថា **សម្មាវាចា** , ម្នាក់ទៀតថា **សម្មាកម្មន្តោ** ( នេះប្រុស ) ។ ឯស្រីថាដូចនេះ ម្នាក់ថា **សម្មាអាជីវោ** , ម្នាក់ទៀតថា **សម្មាវាយាមោ** , ម្នាក់ទៀតថា **សម្មាសតិ** , ម្នាក់ទៀតថា **សម្មាសមាធិ** ។ ហើយទើបអោយនិមន្តព្រះសង្ឃ៤អង្គជាសង្ឃត្ថេរ ជាធំតែងតាំងក្នុងទីលក្ខណ៍ អភិសេកព្រះនោះ អោយនិមន្តលោកសូត្រ និង ឧបាសកសូត្រនោះ ពុំគួរឡើយ ព្បិតគ្មានសីលក្នុងខ្លួន និងសូត្រអញ្ជើញព្រះបារមីព្រះបរមធាតុពុំបាន ។

ដូចនេះ អោយនិមន្តលោកសូត្រអារាធនា ព្រះបារមីព្រះបរមធាតុ ថាដូចនេះ

យើងខ្ញុំបង្គំប្រណម ពុទ្ធបានឧត្តម នៃព្រះបរមជិនស្រី ។
ទេព្តាមនុស្សយក្ខកិរី មូលមកភក្តី បង្គំបូជាសព្វថ្ងៃ ។
បង្គំព្រះបិដកត្រៃ នព្វលោកធម៌ថ្លៃ ពីដូចទន្ទូវកលនាវា ។
បង្គំពុទ្ធឱស្សសាស្តា ទ្រង់ត្រាស់ទេសនា ទូន្មាននៃសត្វផងគ្រប់ ។
ដោយតេជះខ្ញុំគោរព សូមជៀសឧបទ្រព ចង្រៃកុំបីបៀតបៀន ។
យើងខ្ញុំតាំងចិត្តប្រធាន ធ្វើបុណ្យអោយទាន ចាំសីលបេត្តាភាវនា ។
អញ្ជើញព្រះធាតុថ្លៃថ្លា នៃព្រះសាស្តា ស្តេចគង់នៅស្ថានលោកគ្គី ។
ចូលស្តេចនិមន្តមកខ្ចី ឆាប់ៗវៃៗ កុំបីអោយនៅយូរហោរ ។
ចូលក្នុងពុទ្ធរូបសោភា ព្រោងព្រាយភ្លឺថ្លា រចនានូវពណ៌រស្មី ។
ព្រះធាតុនៃព្រះជិនស្រី នៅសព្វបារមី នៅនៃកោះកែវលង្កា ។
នៅក្នុងជម្ពូទីបា នៃស្ថាននានា ស្ងួតាភុជង្គនាគគ្គី ។
អញ្ជើញព្រះធាតុជិនស្រី រួសរាន់ឃ្លាតខ្ចី ចូលមកក្នុងព្រះបដិមា ។
ចង្កូមកែវស្តាំសោភា ខាងលើនោះណា ស្ថិតនៃត្រៃត្រិង្សាសួគ៌ស្រី ។
ចង្កូមកែវស្តាំពិសី ខាងក្រោមនោះក្តី ស្ថិតនៅកោះកែវលង្កា ។



www.elibraryofcambodia.org

ចង្កូមកែវឆ្វេងលើសាស្តា  ទៅស្ថិតនៅនា  នគរគន្ធាបុរី ។
ចង្កូមឆ្វេងក្រោមជិនស្រី  ល្អល្អះពិសី  ស្ថិតនៅពិភពនាគា ។
អញ្ជើញចូលមកឆាប់រ៉ា  ចូលក្នុងបដិមា  រួចនានូវពណ៌រស្មី ។
ធាតុដងកាំបិតជិនស្រី  ខាងស្តាំពិសី  ស្ថិតនៅសីងហុនទ្វីប ។
ធាតុដងកាំបិតសាស្តា  ខាងឆ្វេងនោះណា  ស្ថិតនៅស្ថានព្រហ្មពណ្ណរាយ ។
ព្រះកេសឧណ្ណាលោមព្រាយ  រស្មីភ្លឺឆ្លាយ  នូវបាតលីបុត្តបុរី ។
ទន្តីសាការជិនស្រី  ព្រះនេត្រលោមក្តី  ព្រះទន្តសែសិបនោះណា ។
ព្រះធាតុនូវព្រះនខា  អញ្ជើញឆាប់រ៉ា  ចូលក្នុងពុទ្ធរូបឆាប់ខ្មី ។
ព្រះកេតុមាលាជិនស្រី  ព្រោងព្រាយរស្មី  ល្អឯកឥតអ្វីឧបមា ។
ព្រះព្យាមបការនោះណា  រស្មីភ្លឺថ្លា  សខៀវឡើងច្រាលល្អក្រៃ ។
ហែតងអនេកប្រពៃ  ឆព្វណ្ណរង្សី  ឆ្លៀលឆ្លាត់ច្រវាត់សោះសា ។
ភ្លឺច្រាលដាលដល់វេហាស៍  ទាំងទសទិសា  ពិពណ៌ពិពិធរង្សី ។
ដូចហិមគិរីស្ទូតស្រី  ពុំនោះគោភតរៃ  ដូចកល់ឥន្ទធនូថ្ងៃថ្លា ។
អញ្ជើញរស្មីសាស្តា  មួយមកឆាប់រ៉ា  ចូលក្នុងពុទ្ធរូបនោះនៃ ។
ទោះទាំងទសពលញ្ញាណញៀយ្យ  ទសបារមីថ្លៃ  នូវទសបរមត្ថបារមី ។
នព្វលោកុត្តរធម៌ក្តី  ធម៌ព្រះជិនស្រី  ទាំងប្រាំមួយម៉ឺន៤ពាន់ ។
ទាំងគម្ពីរញ្ញាណសោភ័ណ  ជ្រៅលើសសិទ្ធន្ត៍  សមុទ្រនៅសាគរា ។
ទាំងឈានញ្ញាណញៀយ្យថ្លៃថ្លា  ព្រោះព្រោងប្រាជ្ញា  ឈ្វេងយល់រស់អាថ៌សព្វាយ ។
ព្រះទ័យជ្រៅជ្រះទូលាយ  ឈ្វេងយល់សព្វសាយ  ទូទៅលោកិយលោកា ។
ទ្រង់ត្រាស់ព្រះធម៌ទេសនា  ប្រោសសត្វសំខ្យា  គ្រប់ដែនភាវាភពត្រៃ ។
អញ្ជើញព្រះធម៌ជិនស្រី  ចូលមកឆាប់ខ្មី  ចូលក្នុងរូបព្រះបដិមា ។



www.elibraryofcambodia.org

ទាំងស្បង់ផ្ចិតផ្ចង់រចនា ចីពរក្តីណោ សង្ឃាដី ហង៉ុក វត្ថពន្ធ ។
រស្មីលឿង១ល្អលន់ បើនឹងគួរគន់ បីដូចនៅកែវសុវណ្ណា ។
ពុំនោះដូចផ្កាចំប៉ា ពុំនោះសោតណោ ដូចផ្កាទទឹមល្អក្រៃ ។
ចាំងផ្ចិតនិស្សិតគ្រប់ក្រៃ ចីវរថ្លាថ្លៃ ផ្ចិតផ្ចង់រំនរថ្វាត់ថ្វាយ ។
បល្លង្កមាលមាសពណ្ណរាយ រស្មីព្រោងព្រាយ អរញ្ជើញពុទ្ធរូបគង់ថ្កាត់ ។
យើងខ្ញុំអភិសេកពុទ្ធរតន៍ អោយបរិបូរស្សិទ្ធ ជាម្ចាស់ក្រុងក្រៃលោកា ។
ព្រះពុទ្ធពីមុនក្តីណោ សល់សែនសំខ្យា ច្រើនក្រៃលើសខ្សាច់សមុទ្រ ។
ទាំងព្រះសិអារ្យប្រាកដ ជាអង្គព្រះពុទ្ធ បានត្រាស់ទៅមុខក្តីណោ ។
អរហន្តសល់សែនសំខ្យា ច្រើនក្រៃមហិមា នឹងរាប់គណនាពុំបាន ។
មានបុណ្យបារមីថ្កើងថ្កាន ព្រោសសត្វសព្វស្ថាន អោយបានសម្បត្តិទាំងបី ។
សូមតែតេជះបារមី ព្រះពុទ្ធនោះក្តី នៅអស់អង្គអរហន្តា ។
ចូលមកក្នុងរូបបដិមា ចំរើនចេស្តា ជយានុភាពបង្គល ។
យើងខ្ញុំសឹងខ្ញុំខ្វាយខ្វល់ រួសរៀបតាំកល់ តាំកើងនូវគ្រឿងបូជា ។
លាជនូវទៀនធូបភ្ញីផ្កា ប្រសើរថ្លៃថ្លា វន្ទាគោរពសព្វថ្ងៃ ។
គ្រប់គ្រឿងប្រដាប់នោះនៃ ត្រកាលប្រពៃ យើងខ្ញុំថ្វាយព្រះបដិមា ។
ចាមរ. បែមន់ ត្រៀបត្រា សែនធ្ងន់រចនា ពិដានលាប្រទីបទាំងឡាយ ។
ផ្កានចាំងពីលើឆើតឆាយ ឆត្រទង់ពណ្ណរាយ ទៀនធូបអុជភ្លឺព្រោងព្រាយ ។
បាយសីឆ្វេងស្តាំជាអាទិ៍ យើងខ្ញុំរៀបស្អាត អភិសេកព្រះពុទ្ធបដិមា ។
មធុបាយាសសោភា រៀមរៀបរចនា ដណ្តាំស្អិតស្អាតល្អក្រៃ ។
ដាក់គ្រឿងក្រអូបប្រពៃ សឹងមានតំលៃ ចំខ្ទិនពិដោរភាភាយ ។
បង្អែមចំអាបទាំងឡាយ ដាក់ទុករៀងរាយ នូវបាយចំនីច្រើនក្រៃ ។



www.elibraryofcambodia.org

សព្វញ្ជនៈផ្លាផ្លែ ប្រសើរប្រពៃ មានឱជារសពិសា ។
ក្រចេះជូងចន្ទគន្ធា សារពើបូជា ប្រេងម្សៅក្រអូបខ្ជួរខ្វាយ ។
ស្លាចមិទឹកអប់ទាំងឡាយ ទៀនធូបព្រោងព្រាយ តោមកែវរំយោលល្អក្រៃ ។
ទឹកអប់ក្រអូបប្រពៃ បើនឹងឧបមេយ្យ ឧបមាដូចកល់គង្គា ។
បកពីពិភពនាគា ពុំនោះឧបមា ដូចទឹកអំពីសួគ៌ស្រី ។
ឯររស់អាហារចំនី ត្រកាលពិសី ពិសាដូចទឹកភោជនា ។
យើងខ្ញុំលើកថ្វាយបូជា នៃព្រះបដិមា ព្រះពុទ្ធរូបថ្កើងថ្កាន ។
សូមបារមីព្រះទ្រង់ញាណ អញ្ជើញមកថ្កាន មកស្ថិតនៅព្រះបដិមា ។
យើងខ្ញុំសូមជូនចេស្តា ស្តីពីជយា ជំនះឈ្នះមារទាំងឡាយ ។
កំចាត់ទុកសោកក្រុងកាយ រោគភ័យសម្ងាយ កុំបីមកបៀតបៀនបាន ។
សូមអោយបានបុណ្យថ្កើងថ្កាន ពីព្រះប្រធាន ជាទិដ្ឋធម្មវេទនី ។
អោយបានសម្បត្តិសួគ៌ស្រី ព្រាផ្កាភ្នីៗ អោយបានដូចចិត្តប្រាថ្នា ។
យើងខ្ញុំសូមទាន់សាសនា នៃព្រះភគវា នាមព្រះសិអារ្យមេត្រី ។
អោយបានសម្បត្តិទាំងពា ពីព្រះជិនស្រី កុំបីអោយមានឃ្លាតឃ្លា ។

នេះចប់អារាធនាព្រះបរមធាតុរួចហើយ អោយនិមន្តលោកសូត្រពុទ្ធាពិសេក ហើយទើបអោយអាចារ្យសូត្រសរសើរ ព្រះលាយល័ក្ខណ៍ព្រះធម្មកាយព្រះអង្គថា ដូចនេះ :

សព្វញ្ញុតញ្ញាណបវរសីសំ ។ និព្វានារម្មណបវរវិសសិតកេសំ ។ ចតុត្ថជ្ឈានបវរលលាដំ ។ វជិរសម្មាបត្តិញាណបវរឱណ្ណាភាសំ ។ នីលកសិណសោភាតិកង្ខបវរភមុគ្គលំ ។ ទិព្វចក្ខុ បដិញ្ញាណចក្ខុ សមន្តចក្ខុ ពុទ្ធចក្ខុ បវរចក្ខុទ្វយំ ។ ទិព្វសោតញ្ញាណបវរសោតទ្វយំ ។ គោត្រភូញាណ បវរឧតង្គមឃានំ ។



www.elibraryofcambodia.org

មគ្គផលវិមុត្តិផល បវរតន្ទទ្វយំ ។ សត្តកំ សម្ពោធិបត្តិយញ្ញាណបវរសុភទន្តា ។
លោកិយលោកុត្តរញ្ញាណបវរឱដ្ឋទ្វយំ ។ ចតុមគ្គញ្ញាណបវរចតុទាឋា ។ ចតុសច្ច
ញ្ញាណបវរជិវ្ហា អបដិហតញ្ញាណបវរហនុកំ ។ អនុត្តរវិមោក្ខាធិគមនញ្ញាណ
បវរខណ្ឋំ ។ តិលក្ខណញ្ញាណបវរវិលសត្តតិវិវិភាធិតំ ។ ចតុវេសារជ្ជញ្ញាណ បវរពា
ហុទ្វយំ ។ ទសានុស្សតិញ្ញាណ បវរវត្តង្គុលិសោភា ។ សត្តសម្ពោជ្ឈង្គបវរបិណោ
ឧរត្ថលំ ។ អាសយានុសយញ្ញាណបវរថនយុគ្គលំ ។ ទសពលញ្ញាណបវរមជ្ឈបង្គំ ។
បដិច្ចសមុប្បាទញ្ញាណបវរនាភិ ។ បញ្ចិន្ទ្រិយំ បញ្ចពលំ បវរជឃនំ ។ ចតុសម្មប
ដ្ឋានបវរឩរុទ្វយំ ។ ទសកុសលកម្មបថបវរជង្ឃទ្វយំ ។ ចតុរិទ្ធិបាទំបវរបាទទ្វយំ ។
សីលសមាធិបញ្ញា បវរសំឃាដិ ។ ហិរោត្តប្បញ្ញាណបវរបំសុកូលចីវរំ ។ អដ្ឋង្គិក
មគ្គញ្ញាណបវរអន្តរវាសកំ ។ ចតុសតិបដ្ឋានបវរកាយពន្ធនំ អហន្តេសទេវមនុស្សា-
នំ ពុទ្ធោ អតីវិរោចតិយស្សុតមគ្គមង្គានិញ្ញាណសព្វញ្ញុតាធិកំ ធម្មកាយបតំ ពុទ្ធា-
នបេតំ លោកនាយកំ ។ ធម្មកាយពន្ធលក្ខណំ យោការវិចរកុលបុត្តោ ។ តិក្ខណ
ញ្ញាណោ សព្វញ្ញុតពុទ្ធភាវំ បថេន្តោ បនុបុនំ អនុស្សរិតតំ ។ ពុទ្ធោ ទ្វាទសកោដ្ឋោ
វហន្តោ អតីសិ ឧ បមោ បវត្តោ ឧល្ហិសោទិចំ សោ អន្តរស្សកោ ភវេ ។

សូត្រសរសើរព្រះលាយល័ក្ខណ៍ព្រះកាយព្រះអង្គរួចហើយ លុះដល់ទៅ
រងាវ អោយរៀបដណ្តាំបាយចង្ហាន់ មធុបាយស ។ នោះអោយប្រដាប់គ្រាន១ ,
ខ្ទះ១ ហើយបកស្រូវតំនើប ១ពែង , ស្រូវខ្សាយ ១ពែង , ល្ង ១ពែង , សណ្តែក
បាយ ១ពែង , សណ្តែករាជមាស ១ពែង , ស្ពៅ ១ពែង , ស្ករ ១ពែង , រង្វ
១ពែង , ទឹកឃ្មុំ ១ពែង , ទឹកខ្សីរ ១ពែង , ទឹកដូង ១ពែង , ទឹកគ្រឿងក្រអូប
១ពែង, ខ្ទះដូង ១ពែង ។ ថ្កល់ទុកនឹងពានមាស អោយប្រុសម្នាក់ស្លៀកប្លបពាក់
ខៀវធ្វើជាព្រះឥន្ទ កាន់ស័ង្ខអង្គុយលុតជង្គង់ពីទិសបស្ចិមមុខទៅគ្រាន ហើយអោយ



www.elibraryofcambodia.org

យកម្នាក់ស្លៀកហូលពាក់ស ធ្វើជាព្រះព្រហ្មកាន់ឆត្រតាំងពីទិសបូព៌ ឈមមុខទៅក្រាន។ ហើយយក៤នាក់វិញទៀតស្លៀកហូលពាក់លឿង ធ្វើជាព្រះចតុលោកបាលទាំង៤ កាន់ព្រះខ័នរង្គុយបែរមុខចេញទាំង៤ជ្រុង។ ទើបអោយយកស្រី៣នាក់អោយស្លៀកស ពាក់ស ទាំង៣នាក់ហើយ អោយម្នាក់យកអុសទៅដុតក្នុងក្រាន ទើបម្នាក់យកខ្ទះទៅដាំលើក្រាន ទើបម្នាក់យកអង្ករ , ល្ង , សណ្តែក , នូវទឹកខ្ទិះ របស់ទាំងនោះ ទៅដាក់ក្នុងខ្ទះ ហើយទើបអោយព្រះឥន្ទផ្លុំស័ង្ខ គោះរពាំង បាញ់កាំភ្លើង គំកើងនូវតូរ្យតន្ត្រី ហើយអោយរៀបចំនីភោជនអាហារ គឺបង្អែមចំរាប ធំ បន្លែកទាំងឡាយមកដាក់ឆ្វេងស្តាំ នៅព្រះភ័ក្ត្រហើយអោយសូត្រដូចនេះ :

យើងខ្ញុំសូមខំខ្វាយខ្វល់ រួសរៀបតំកល់ តំកើងនូវគ្រឿងបូជា ។
ឆ្មៅឆ្លាតជារូបនាគា ត្រគុយកុកិន្នរា វិជ្ជាធរនៅកិន្នរី ។
សិង្ហគោរូបគោក្របី រូបសេះដំរី រាជសីហ៍នូវរូបគជសារ ។
រមាំងរមាសខ្លោងខ្លា គឺសិង្ហលៀងភា ពំពែស្វានបៀបចាមរី ។
ករវិកបៃបរបក្សី សារិកាកែវក្តី គ្រួសក្រៀលចង្កៀលខ្យងផង ។
កុកក្រកអកប៉ើនូវកែងកង សេកសោមត្រយង នូវរូបមាន់ទោមាន់ព្រៃ ។
ទទាសេកបោរល្អក្រៃ ចចាតប្រវៃ លលកចេកទុំស្ទិតចៅ ។
រូបរាហូចេកពាវៅ រូបសេកសោមនៅ រូបសត្វក្លោកបក្សា ។
រូបឆ្លាបក្រពើត្រីខ្យា ត្រីរាជត្រីប្រា ត្រីប្រួលត្រីកាបែកកាបោ ។
អណ្តើងច្រកែងក្លាំងបាយ ត្រីពោត្រីក្រាញ់ មានរូបត្រីក្រួសត្រីក្រាយ ។
ប្រហោតរូបស្លាតសណ្តាយ ត្រីសាបរបាយ នូវបបែអណ្តើកត្រសែ ។
រូបពស់ត្រីរស់ល្អក្រៃ រូបមករសោតនៃ នូវរូបត្រីផងនានា ។


www.elibraryofcambodia.org

ចាមរ.កែមន់.ត្រៀបត្រា    តែនត្ថុនហ្វាលោ    ពន្លឺប្រទីបទាំងឡាយ ។

ផ្កាងបាំងពីលើឆើតឆាយ    ទាគទង់ពណ្ណរាយ    ទៀនធូបរុជភ្លឺព្រោងព្រាយ ។

ពាបេសីឆ្វេងស្តាំឆើតឆាយ    យើងខ្ញុំរៀបថ្វាយ    អភិសេកព្រះពុទ្ធបដិមា ។

មធុបាយាសសោភា    រួសរៀបរចនា    ដំណាំស្ពិតស្អាងល្អក្រៃ ។

ដាក់គ្រឿងក្រអូបប្រពៃ    សឹងមានតំលៃ    ធំខ្ពស់ពិដោរភាភាយ ។

ចំនីចំអាបទាំងឡាយ    ដាក់ទុករៀងរាយ    នូវបាយចំនីច្រើនក្រៃ ។

អានទាំងត្រីសាបត្រីប្រៃ    ត្រីចៀនប្រពៃ    នូវត្រីបង់ខ្លាញ់ផងហោ ។

សព្វព្យញ្ជនៈសោភា    ត្រកាលពិសា    មានឱជារសពន់ពេក ។

ចំនីបង្អែមប្លែកៗ    ជានំឯកៗ    គឺនំសំខ្យានំខ្ញី ។

នំកន្ទ្រាមធោបថ្មីៗ    នំគ្រាបនោះក្តី    នំកែងថងឃឹបហ្មួយផង ។

នំពាំងបឿងអន្សង    អន្សមព្រួកផង    នំគមនំចាំងនំថ្ងៃ ។

គ្រប់គ្រឿងប្រដាប់នៅនៃ    ត្រកាលប្រពៃ    យើងថ្វាយទៅព្រះបដិមា ។

ក្រចេះថ្នូរចន្ទន៍គន្ធា    សារពើបូជា    ប្រេងម្សៅក្រអូបខ្ចូរខ្ចាយ ។

ស្លាធម៌ទឹកអប់ទាំងឡាយ    ទៀនធូបព្រោងព្រាយ    តោមកែវរំយោលល្អក្រៃ ។

ទឹកអប់ក្រអូបប្រពៃ    ហើរឹងឧបមេយ្យ    ឧបមាដូចកលពង្កា ។

មកពីពិភពនាគា    ពុំនោះឧបមា    ដូចទឹកអប់ពីសួគ៌ស្រី ។

ឯរស់អាហារចំនី    ត្រកាលពិសី    ដូចទឹកភុជង្គនាគា ។

យើងខ្ញុំលើកដៃបូជា    នៃព្រះបដិមា    ព្រះពុទ្ធរូបថ្កើងថ្កាន ។

សូមបារមីព្រះទ្រង់ញាណ    អញ្ជើញមកថ្កាន    មកស្ថិតនៅព្រះបដិមា ។

យើងខ្ញុំសូមជូនចេស្តា    ស្តុតិជយោ    ជិនះឈ្នះមារទាំងឡាយ ។

កំចាត់ទុក្ខសោកក្នុងកាយ    រោគរាំពាគរព្វាយ    កុំបីអោយមកបៀតបាន ។



www.elibraryofcambodia.org

សូមអោយបានចំរើនថ្កើងថ្កាន ពីព្រះប្រធាន ជាទិដ្ឋធម្មវេទនី ។
អោយបានសម្បត្តិសួគ៌ត្រៃ ប្រាថ្នាអ្វីៗ អោយបានដូចក្តីប្រាថ្នា ។
យើងខ្ញុំសូមទាន់សាសនា នៃព្រះភគវា ចាំព្រះសិរអារ្យមេត្រី ។
សូមបានសម្បត្តិទាំងបី ពីព្រះជិនស្រី កុំបីអោយមានឃ្លាតឃ្លា ។
ព្រះធម៌បត្តិហោតា សង្ឃេបវន្ទា និដ្ឋិតាចែងចប់ម្លេះហោង ។

សូត្រចប់ហើយ និមន្តព្រះសង្ឃ ៨អង្គ មកសូត្រ ÷

+ ឥតិបិសោ ... , ស្វាក្ខាតោ ... , សុបដិបន្នោ ... ។

+ ពាហុំ ... , មហាការុណិកោ ហើយ សូត្រជយន្តោដល់បទក្ខិណេ ១៩ចប់ ហើយសូត្រភវតុ ស្រេចហោង ។

លុះលោកសង្ឃសូត្រចប់ហើយ ដល់ភ្លឺស្រាង អោយដួសចង្ហាន់មធុបាយាស ដាក់ពាំកល់នឹងភាជន៍មាសហើយ អោយស្រី ៣នាក់ ស្លៀកហូលពាក់សនោះ យកចូលទៅថ្វាយព្រះអង្គ អោយម្នាក់ទូលចង្ហាន់មធុបាយាស ម្នាក់ទូលគ្រឿងទឹក ម្នាក់ទូលគ្រឿងស្លា ។

លុះចូលទៅដល់មុខព្រះភក្ត្រហើយ អោយលុតជង្គង់ថ្វាយបង្គំ ៣ដង ហើយ លើកបន្ទូលឡើង ទើបអោយសូត្រដូចនេះ ÷

អញ្ចាប់នោះពោ នាងពៃសាខា ថ្វាយមធុបាយាស
សឹងគ្រឿងទន់ទិព្វ ពេញទាំងភាជន៍មាស នាងលើកអង្គាស
ថ្វាយព្រះទសពល ។

សូត្រពាចប់ហើយ អោយលើកចូលទៅថ្វាយព្រះអង្គ ។ លុះថ្វាយរួចហើយ អោយយកទឹកអប់ត្រលប់នូវគន្ធពិដោរមកស្រង់ព្រះអង្គ ។ កាលបើនឹងស្រង់នោះ អោយសូត្រគាថាដូចនេះ ÷


www.elibraryofcambodia.org

អោយអភិសេក តេ ពុទ្ធាវទានេ នមោ ឥន្ទំ ន មយ្ហំ ហោហិ ។

សូត្រ៣ចប់ហើយស្រង់ទៅហោង ។

លុះស្រង់ស្រេចហើយ ទើបព្រះអង្គឆាន់ចង្ហាន់មធុបាយាស អស់សំនល់ បរិបូរស្កប់ស្កល់ កាលត្រាស់នោះណា ។

ព្រះអង្គបានស្រេច ខ្សិណនោះសារពេជ្រ បានត្រាស់ព្រាជ្ញា
ផុសរត្នបល្លង្ក ទែនទាំងសុវណ្ណា សឹងរត្នវេក្កា
កើតដោយបារមី ។

ទើបពោធិព្រឹក្ស លំពង់លាស់ស្លឹក ពណ៌ស្រស់ខៀវខ្ចី
ក្រោយរត្នបល្លង្ក បាំងព្រះជិនស្រី ពន្លឺរស្មី
រន្ទាលទែងទុំ ។

(សូត្រ១ចប់)

អោយសូត្រសសើរពោធិនាគព្រឹក្ស អោយសូត្រជាបទបទុម ។

ពោធិព្រឹក្សាសាល ភ្លឺរន្ទាល១ទុំ
ស្លោមស្លឹកស្លឹកត្រសុំ ត្រសាយទៅនៅមែកមាស ។
រុងរឿងព្រះរស្មី នៃពោធិព្រឹក្សភ្លឺថ្លា
ឆ្លាសដូចចន្ទថែងចារ នៃកណ្តាលតារាផង ។
ព្រះពាយបក់ទន់ទង បក់រំលងឫសត្រសង
បក់បោករុករំលង បក់រំភើយដោយផាយផាត់ ។
ត្រជាក់សុខក្សេមក្សាន្ត ដូចវិមានបាំងពាយពទ្ធ
ពីលើបល្លង្ករត្ន ថ្វាយព្រះអង្គគង់សប្បាយ ។
ជាសុខសោភិរំ អស់ឥន្ទព្រហ្មផងទាំងឡាយ



www.elibraryofcambodia.org

សឹងនាំគ្រឿងមកថ្វាយ ពាសពោធិ៍ពេញទាំងឋានលោក ។

សូត្រសសើរពោធិនាគព្រឹក្ស ហើយក្រុងមារាធិរាជ លើកពលបរកច្បាំង ដណ្តើមបរត្នបល្ល័ង្ក ច្បាំងចាញ់ព្រះអង្គហើយ ក្រុងមារាធិរាជចូលមកថ្វាយបង្គំព្រះអង្គនោះដូចនេះ ÷

ក្រៀមនោះមារា គិតខ្លួនអវិជ្ជា ថាឱអញអើយ
ចាលចាញ់សំភារ ការបីព្រះហើយ នេះតើអញអើយ
នឹងគិតកលម្តេច ។

ទើបទ្រង់អារគិត ក្នុងអង្គអស់ចិត្ត ទ្រង់ភ្ញីស្រស់ស្រេច
រៀបប្រដាប់ទៅ ថ្វាយអង្គសារពេជ្រ ចរចូលដល់ស្រេច
ក្រាបបង្គំទូល ។

បពិត្រព្រះអង្គ សូមទានស្រោចស្រង់ ប្រោសខ្ញុំផងរ៉ា
អោះទោសបាបខ្ញុំ សូមទ្រង់ករុណា សូមស្តេចមេត្តា
ទោសខ្ញុំធ្ងន់ក្រៃ ។

បពិត្រខ្ញុំខ្លាច ស្តេចមានអំណាច លើសលែងភពត្រៃ
ទោះទាំងឥន្ទព្រហ្ម តូចធំផងនៃ នៅសួគ៌ាល័យ
ផ្ទឹមពុំបានឡើយ ។

(ចប់ហោរ)

ទើបព្រះអង្គស្តាប់ អម្បាលសារសព្ទ ក្រុងមារទូលឆ្លើយ
ព្រះទ្រង់មេត្តា កុំយកទោសឡើយ អោយមារកាន់ត្បើយ
ទោសទុក្ខនោះផង ។

ព្រះបន្ទូលថា អោយមារនេះណា បានលុះនេះល្អង



www.elibraryofcambodia.org

ព្រះកាយទុកផា ចំនេរទៅហោង អោយបានត្រាស់ផង
ហៅពុទ្ធឥស្វរ ។
ក្សិណនោះជំនុំ ទេវតាផងជុំ ឥន្ទព្រហ្មមិត្តមូល
មកថ្វាយបង្គំ ប្រណមខ្មៅខ្ជួល គ្រឿងទិព្វស្រស់ស្រួល
ថ្វាយអង្គសារពេជ្រ ។
ទ្រង់ភ្ញីមាលា គ្រឿងទិព្វរចនា ថ្វាយព្រះសម្តេច
ភិតានឆត្រទង់ សឹងសងរំលេច គ្រឿងស្រស់ទើបស្រេច
ថ្វាយព្រះជិនស្រី ។
ព្រះអង្គសោយសុខ ប្រសើរឥតទុក្ខ បញ្ចេញរស្មី
ឆ្វាត់ឆ្វៀលចេញទៅ មកជាប្រក្រតី ឆព្វណ្ណរង្សី
នៅនៃបភគវា ។
រីព្រះរស្មី ព្រះអង្គមុនី តាមដោយរចនា
ខ្លះខ្មៅសច្រាល ពពាលមុខា មានលឿងខៀវជា
រុងរឿងរស្មី ។
នេះគឺជំនាល ព្រះអង្គផ្ចាញ់មារ ឈ្មោះអន្យត្ថីយ
សសើរព្រះអង្គ ផ្ចាញ់នូវបារមី ឈ្នះមារហើយនៃ
ឥតមន្ទិលឡើយ ។
ដោះលែងសង្សារ ជៀសលែងខន្ធមារ រំពេចស្រេចហើយ
ព្រះអង្គកំចាត់ ទុក្ខសត្វផងហើយ ជាសំរេចហើយ
នៃមារនេះហោង ។
( សំរេចអភិសេកហោង )



www.elibraryofcambodia.org

លុះព្រឹកឡើងអោយនិមន្តព្រះគម្តែងសង្ឃសូត្រ ពហូ ទេវា ... ឆ្លងសំរេចហោង។ មួយសោតកាលពីល្ងាច អោយនិមន្តព្រះគម្តែងសង្ឃសូត្រព្រះទិព្វមន្តទេសនាព្រះធម្មគោរព មហាល័យ ព្រះមាតុគុណ ព្រះធម្មគុណ ។

លុះទេសនារួចដល់មាន់រងាវ អោយដណ្តាំបាយមធុបាយាសនោះ អោយនិមន្តព្រះសង្ឃ ៨អង្គ មកសូត្រ ÷

ឥតិបិសោ ... , ស្វាក្ខាតោ ... , សុបដិបន្នោ ... , ពាហុំ ... , មហាកា... ហើយសូត្រ ជយន្តោ ដល់បទក្ខិណា ១៩ចប់។ រួចត្រវ៉ាត់រួចសូត្រ នមោ មេ ឥតិបិ... អវិជ្ជា... អនេកជាត... អាកាសដ្ឋា..., សំរេចតែប៉ុណ្ណោះឯង ។

**ឥមស្មឹ រាជសីមានា ខេត្តេ សេបញ្ចវិសតីយោជនសតេ**

**សហស្សានិ { ពុទ្ធំ / ធម្មំ / សង្ឃំ } ជាលបរិក្ខេ តេ រក្ខន្តុ ៗ**

(ចប់ព័ទ្ធសីមា)


www.elibraryofcambodia.org

*ឯកសារទី២*

# ក្បួនពុទ្ធាភិសេក

ក្បួននេះ អង្គការ FEMC បានទៅថតចំលងចេញពីវត្ត ខ្សាច់ពោធិអារ្យ ភូមិខ្សាច់ ឃុំអរិយខ្សត្រ ស្រុកល្វាឯម ខេត្រកណ្តាល ។

លេខកូត A . 09 . 15 . 01



www.elibraryofcambodia.org

# អភិសេក

នេះនឹងស្រដី ឯច្បាប់អភិសេក អង្គព្រះពុទ្ធរូបនោះ អោយប្រដាប់ ភាពកំពូល ភាពនាគ ភាពបេរគា ភាពតទូ ភាពសប្បៀ ភាពបឃូរិ ភាពសារិកា នៅសេក លលក ចាប ទាំងឆ្វេងទាំងស្តាំ សឹងទាំងគូ ហើយលើក ជាដងបញ្ឈរ ហើយ ធ្វើជាទឹកមានឈ្លូកទាំងទងទាំងផ្កាផ្លែផង សឹងដុះរំលេចដោយចន្លោះ អស់ទាំងភាពរៀបទៅមុខព្រះហើយ ធ្វើចាមរ , បៃមន់ . អភិរម ហើយមាន ទាំងគាងឃ្វាយ កំពូលឆត្រូត សឹងមានទង់ជ័យ លើកំពូលនោះហើយ អោយរៀប ៥ស្តាំ ៥ឆ្វេង នោះ សឹងអោយយកប្រុសកំលោះស្អិតស្អាង ស្លៀកសំពត់ក្រវាត់បង្កត អោយកាន់ អស់ប្រដាប់ទាំងនោះឯង ៥ស្តាំ ៥ឆ្វេង សងខាងអាសន៍ព្រះនោះហើយ អោយប្រដាប់ស្លា ក្អម ៨ស្តាំ ៨ឆ្វេង ហើយ និមន្តព្រះគម្ពែងសង្ឃចំរើនព្រះទិព្វមន្ត បបាជ័យ អញ្ជើញអស់ទេវតាលុះចប់ នោះប្រគេនព្រាក់តំលឹង១រង្គ ហើយសំដែងអស់ភ្លេងសួគ៌ តូរ្យតន្ត្រី បាញ់កាំភ្លើង តំលើងអុជអស់ទាំងភ្ញីរន្ទាល ជាសួរេចបោរង។ នេះជាន់រួច។ ហើយឯក្រោយ វិញទៀត អោយច្រូតស្រូវភ្លាំង បាន១កណ្តាប់ដៃ មកវុំអោយល្អ ហើយ អោយយកស្លឹកពោធិ៍បាន៧ អាចងជុំស្រូវវុំនោះ ហើយយកពាន ១ មកតំកល់ អោយបញ្ឈរស្រូវក្នុងពានហើយ យកដីខ្សាច់អោយសល្អ ដាក់ក្នុងពាននោះ ពូនអោយល្អ ខ្ទាប់ស្រូវនោះដូចព្រះចេតិយ ហាក់ដូចមានដើមព្រះពោធិ៍ ដុះលើកំពូល ហើយប្រដាប់បាត្រដី ១ ទាំងស្លោក នូវផ្តិត ១ នូវច្រត់ដែក ១ ឯទុកក្នុងបាត្រនោះ កាំបិតកោរ ១ទាំងស្រោម នៅថ្លុសំលៀង ១ នូវស្រោម



www.elibraryofcambodia.org

ដែកភ្លើង នូវដែកគ្រប់ប្រដាប់ នូវបំពង់ទៀន នូវបំពង់ជីស ដៃខ្មៅផង នូវបំពង់ម្ពុល ចេសផង ហើយប្រដាប់ ១សំរាប់ នេះទុកតំកល់លើអាសនព្រះ ហើយយកបុរសម្នាក់ អោយស្លៀកពាក់ស ជូតស ធ្វើជាព្រះព្រហ្ម កាន់គ្រឿងបរិក្ខារមកថ្វាយព្រះ ហើយក្រាបសំពះ៣ដង ហើយបុរសម្នាក់អោយស្លៀកសំពត់ស លត់ឆាយស្ពាយឆៀង ធ្វើជាតាបសកាន់បាត្រ១ ដាក់កញ្ចប់ប្រអូលសដូវ នូវសាគូ លូនទទួបចូលទៅដល់អាសនព្រះ ហើយថ្វាយបង្គំក្រាបសំពះ៣ដងហើយ យកបុរសអោយស្លៀកខៀវ ពាក់ខៀវ ជូតខៀវ កាន់សង្ខទទួបចូលមកដល់អាសនព្រះហើយ ក្រាបថ្វាយបង្គំ៣ដង ហើយផ្លុំសង្ខ រះរគាំង បាញ់កាំភ្លើង ហើយនិមន្តព្រះតម្កើងសង្ឃ អោយសូត្រពុទ្ធាភិសេក នៅ នមោ មេ នៅមហាជ័យ ៣ហុំ នូវព្រះធម៌យោគ នេះទើបស្លចង្ហាន់មធុបាយាស អោយប្រដាប់ក្រានស្មៀម ១ ឆ្នាំងខ្ទះ ១ យកអំពៅមកធ្វើជាវែកគូរ បើពុំបានអំពៅអោយយកឈើក្រអូបមកធ្វើជាវែក តែងកូរវែកស្មាន់ ១ ទុកតែងដូសផ្តិល ១ ល្អដូសហើយ ធ្វើកេវគ្របហើយ មានផាសល្អគឺពានក្តី តោកក្តី ជាតំកល់អោយល្អក្តី រៀបតំកល់នៅមុខព្រះ ហើយបិតឈើពិដោរ ធ្វើជាអុសបាន ៧ ហើយយកអង្ករស្រូវតំនើបបុកបានពែង ១ . អង្ករស្រូវខ្សាយបុកបានពែង ១ . សាគូពែង ១ . សណ្តែកធំបានពែង ១ . សណ្តែកបាយពែង ១ . សណ្តែករាជមាសបានពែង ១ . ល្ពៅបានពែង ១ . រង្វបានពែង ១ . ទឹកឃ្មុំបានពែង ១ . ទឹកខ្សឺបានពែង ១ . ខ្ទិះដូងបានពែង ១ . ទឹកដូងបានពែង ១ . ទឹកគ្រឿងពិដោរបានពែង ១ . ថ្កល់ទុកនឹងពាន ហើយយកបុរស ១ ស្លៀកខៀវ ពាក់ខៀវ ជូតខៀវ ធ្វើជាព្រះឥន្ទកាន់សង្ខលុតជង្គង់ឈមពីទិសបស្ចឹម មកឯក្រានហើយ យកបុរស ១ ស្លៀកសពាក់ស ជូតស ធ្វើជាព្រះព្រហ្ម កាន់ស្វេតច្ឆត្រ លុតជង្គង់ឈមពីទិសបូព៌ បាំងទៅ



www.elibraryofcambodia.org

ក្រានហើយ យកបុរស ៤នាក់ ស្លៀកលឿង ពាក់លឿង ជូតលឿង អោយដាវ ហូតចេញហើយ ប្រែមុខទៅក្រៅទាំង ៤នាក់ អោយខ្នងមកក្រានហើយ ទើបយកស្រី ៣នាក់ អោយស្លៀកស ដណ្តប់ស្បៃស នាង ១ អោយយកអុស ទៅដុតភ្លើងក្រាននោះ , នាង ១ អោយយកឆ្នាំងខ្ទះលើកឡើងតំកល់លើក្រាន , នាង ១ អោយយករស់គ្រឿងប្រដាប់នឹងស្លចង្ហាន់មធុបាយស ទ្រស្គួយឡើង ទើបអោយបុរសដែលធ្វើជាព្រះឥន្ទនោះ យកអស់គ្រឿងប្រដាប់នោះច្រកក្នុងខ្ទះ រួចហើយ ព្រះឥន្ទផ្លុំសង្ខ រះរគាំង គំលើងអស់តូរ្យតន្ត្រី បាញ់កាំភ្លើងម្តង លុះឆ្អិន ស្រេចហើយ អោយនាង ១ យកវែកដួសដាក់ក្នុងផ្តិលមកតំកល់ក្នុងថាសហើយ ប្រដាប់គ្រឿងទឹក ហើយប្រដាប់គ្រឿងស្លា មកតំកល់ទុកចាំព្រះពម្លែង សូត្រធមិ ពីយ៉ោព លុះដល់អភិសេក ទើបព្រះអាចារ្យឯណាចេះដឹងព្រះធមិ នូវព្រះគាថា អញ្ជើញព្រះ ដាក់អោយស្លៀកស ស្ពាយឆៀងស ធ្វើតាបសយកទៀនធូប ចូលមកថ្វាយព្រះ ហើយសូត្រព្រះធមិអញ្ជើញ ដាក់មករៀបដល់គ្រឿងពិដោរ ស្រង់នៅទឹកអប់គ្រប់អស់ដើមការ រស់ជាស្ទូរេចហើយ ទើបព្រះតាបសសូត្រ ព្រះគាថាអភិសេក ហើយសូត្រអញ្ជើញព្រះឡើងគង់លើអាសន៍ ទើបព្រះឥន្ទ ផ្លុំសង្ខ រះរគាំង គំលើងតូរ្យតន្ត្រី បាញ់កាំភ្លើងម្តង លុះចប់ព្រះធមិពីយ៉ោគ។ ដល់ ព្រះធមិផ្ចាញ់មារ ហើយរៀបនាងទាំង ៤នាក់ ស្លៀកស ដណ្តប់ស នាង ១ ទូល ទឹកដើរមុខនោះ ធ្វើជានាងពៃសាខា , នាង ១ ទូលចង្ហាន់ដើរបន្ទាប់ ធ្វើជានាង សុជាតា , នាង ១ ទូលគ្រឿងស្លា ធ្វើជានាងឧមាទ័យ , នាង ១ អោបថ្វាតស្លា អោយនាងទាំង ៣ ទៅព្រះឥន្ទ ព្រះព្រហ្ម ចតុលោកបាលទាំង ៤ សឹង ១ ម៉ាត់ ក្រុមនោះ ធ្វើជានាងបុណ្ណទាសី ។



www.elibraryofcambodia.org

លុះព្រះធម៌ផ្ចាញ់មារដល់ថ្វាយចង្ហាន់ហើយ អោយរៀបហែចង្ហាន់ចូលទៅថ្វាយព្រះនោះ អោយព្រះឥន្ទកាន់សង្ខដើរមុន ព្រះព្រហ្មកាន់ឆត្របាំងចង្ហាន់ដើរឯក្រោយ អោយព្រះចតុលោកបាល ដើរឆ្វេង ២នាក់ ស្តាំ ២នាក់ សឹងកាន់ដាវហែចូលទៅថ្វាយចង្ហាន់មធុបាយស ទើបអោយព្រះឥន្ទទទួលចង្ហាន់ពីអស់ទាំងនាង ទៅតំកល់នៅមុខព្រះថ្វាយព្រះ ថ្វាយបង្គំ ៣ ដងគ្រប់គ្នាអង្គុយចាំ ចប់ព្រះធម៌ផ្ចាញ់មារហើយ អោយបុរស ៣ នាក់ ឯណាអ្នកនោះអោយស្លៀកលឿងពាក់លឿង ជូតលឿង ១កាន់ខែលដាក់ ១ កាន់ដំបងធ្វើជាព្រះពិស្ណុការ ឯបុរស ១ ស្លៀកខ្មៅ ក្រវាត់វន់លោន ពាក់ខ្មៅ ជូតខ្មៅ ធ្វើជាអលជ្ជិមារ ឥតគ្រឿងកាន់ហើយរៀបផ្លែឈើស្លក ២ ស្រាដប ២ ទៀន ២ យកទៅដាក់ឯទិសបូពិ ហើយបុរសទាំង ៣ ទៅរុជទៀនសែនរំលឹកព្រះបារមីនាងគង្ហីងព្រះធរណីរួចហើយបុរស ១ ធ្វើជាមកលួចស្លកនោះ ឯបុរស ២ ធ្វើជាដើរចេញការស្លក លុះចប់ព្រះធម៌ផ្ចាញ់មារហើយ ព្រះឥន្ទផ្លុំសង្ខ រះរពាំង បាញ់កាំភ្លើង តាំងជើតស្គរធំប្រគំកងហើយបុរសទាំង ២ ធ្វើជាចាប់បុរសចងដៃ អោយកាន់ផ្កា ស្បូវភ្លាំងក៏បាន ផ្កាឈូកក៏បាន នាំចូលមកថ្វាយបង្គំព្រះ ៣ដង អោយថាសូមចាញ់សូមចុះព្រះអង្គហើយ។ និមន្តព្រះគម្តែងសង្ឃអោយពរ ហើយយកចាន ១ ប្រគេនទៅអ្នកសូត្រផ្ចាញ់មារជាសូរេចហោង ។

ហើយអោយរៀបឆ្លង ផ្លែឈើ ទៀនដំថ្វាយព្រះ ដបស្រាច្រត់ ២ អំបោះចាប់ក្លកពាក់ស ពាក់កដបជុំវិញ ហៅអំបោះទាំងអាណោខែត្រ ទៀន ៤ ហើយយកចាស់ឯណាចេះដឹង អោយអង្គុយពីទិសបូពិ ហើយយកអង្ករផ្ដិល ១ ទៀន ១ ប្រាក់បាទ ១ ជាខាន់ខៅ ហើយយកពពិលបាន ២ ទៀន ២ នី ១ ទឹក ១


www.elibraryofcambodia.org

អុជទៀនហើយបិទនៅពពិល ហើយគ្រវាសបាន ៧ បញ្ចេរចេញ និមន្ត តម្លើងសង្ឃ អោយពហូ ទេវ៉ា ហើយបង្វិលទៅទក្ខិណាពត្តិ ។

លុះចប់ពហូ ទេវ៉ាហើយ អោយពពិលក្រវាស ១៩ ចូលហើយ យកម្សៅ ដាក់នឹងផ្តិលផ្តល់នឹងតោក នៅពពិលទាំងភ្លើងទៀន អុជផ្តាច់អំពោះទាំងអស់ ហើយអោយអស់តម្លើងសង្ឃផងរលោសម្សៅ ជាពេជ្រតាញ្ញណសាក្សីមេត្រី អោយ បូជាឧត្តមមង្គលសុខ សួស្តីនោះហោង។ នេះទើបហៅឆ្លងបរិបូរហោង សឹងបាន ផលនោះស្មោះដូចបំនងប្រាថ្នាហោង។ បើអ្នកឯណាធ្វើមិនត្រូវដូចនោះ សឹងបាន ផលកុសលនោះ ឧបមានីដូចទឹកភ្លៀង អោយតែដើមឆ្នាំ ដល់ចុង កណ្តាលឆ្នាំ ទៅដល់ចុងឆ្នាំ ពុំសូវរោយពេញឡើយ នេះឧបមាបីដូចអ្នកផង សាងកូសលនោះហោង បើធ្វើត្រូវដូចច្បាប់បង្គាប់នេះហើយ កុំគិតខ្ជិលឡើយ អធ្យាស្រ័យថាក្រ ចៅក្បាននឹងពិតធ្វើពុំទាន់ឆាន់ តែងគិតអោយត្រូវ អោយ បានដូចព្រះច្បាប់បង្គាប់នេះហើយ អ្នកនោះនឹងបានកុសលផលនោះពេញបរបូរ ឧបមាបីដូចទឹក ភ្លៀងបង្អុររំពីដើមឆ្នាំ លុះដល់ចុងឆ្នាំបក់សឹងតែស្គាល់ហោង ។

នេះវ៉ាទអភិសេកព្រះ បើនឹងរៀបអភិសេក អោយរៀបតាមក្បួន នេះហោង ។

ដល់រៀបនឹងបើកព្រះនេត្រព្រះសាងថ្មីនោះ ស្លាធម៌ ៥ មានផ្កាភ្ញី ទៀនធូប ផ្លែឈើ ៤ ប្រាក់ ៥តំលឹង សំពត់សរភាវ ១ ហើយមានកន្ត្រៃ ១ ក្រាស ១ កាំបិត ស្លាកោរ ១ រៀបតំកល់ព្រះពុទ្ធលើសំពត់ស ស្រេចហើយ អុជទៀនធូបស្លាធម៌ ទាំង ៤ ហើយពាក់អៀងស អោយតាំង នមោ តស្ស ៣ចប់ អោយសូត្រ ព្រះបាលីបើកព្រះនេត្រ ឯម្ជុល ២ ដោតនូវស្លឹកម្លូ សូត្របាលី ៥ចប់ អោយយក ម្ជុលនោះឯង កឹសព្រះនេត្រកាមា ព្រះសូរង ព្រះឱស្ឋ គ្រប់ពូតាមសេចក្តីប្រាថ្នា


www.elibraryofcambodia.org

ឯបាលីអោយសូត្រថា **ពុទ្ធំ ពុទ្ធរូបំ វិវរិត្វា ទិព្វចក្ខុំ ទិបំសូតិ ហោមិៗ** មានបើកព្រះនេត្រព្រះអោយសូត្រ ៥ចប់ បើកព្រះនេត្រហើយ អោយយកកន្ត្រៃកាំបិតស្លាកោរ ទៅកាត់ព្រះកេសាហើយ សូត្រព្រះបាលី ដាក់ព្រះកេសបូជា **កេសាមូលកេសា កេសំមូលកេសំ សឈពុទ្ធំ ឯហិ ទេសិតោៗ** នោះសូត្រ ៣ចប់ យកកាំបិតកោរគ្រវាសបញ្ចេរចេញស្រេចហោង។ អោយស្មាទោសតាមពាក្យសំដីស្រេចហើយ អោយវន្ទាយកកិរិយា **ឱភាស អហំ ភន្តេ អារាធនានិមន្តអាសនេ អហំ ឥតិ តថាគតោៗ** សូត្រ ៣ចប់ និមន្តព្រះឡើងលើអាសន៍។ **បញ្ញាគរិសហាពុទ្ធោ សមណា ន វិនិមុនតិ តំ ហេតុភារំ ភវន្តិៗ** សូត្រ ៣ចប់និមន្តព្រះចុះអំពីអាសន៍។ **ឱភាស បព្វជ្ជំ ចេត្តិយា ពុទ្ធិនាពុទ្ធិកតំ ចេត្តិយា លោភានំ ពោធិនំ យភន្តស្ស ន វិចតិ ហរិមារស្ស ហហិតកចច្ឆន្ត សម្មាហិតំ គហិត្វា សម្មាហិតច្ឆន្ទ ពុទ្ធរូបញ្ច អត្តានញ្ច បតិមន្ទលំ បតិដ្ឋិតាៗ** នេះបំបួសព្រះអភិសេកជាស្វរេច។ **ឥមស្មឹ រាជសីមានោ ខេត្តេ សមន្តា**

**សត្តិយា ជនសត្តសហស្សាន** { **ពុទ្ធំ** / **ធម្មំ** / **សង្ឃំ** } **ជាលប្បខិតិរក្ខន្តុ សុរក្ខន្តុៗ**

នេះពាក្យសីមា។ **សហាឡូរបរិបរាជា ឋានសព្វតោ អាភាសរសាសី បរបរសក្ខិរណា ទេវតា រក្ខន្តុ មេ ៗ** នេះបាលីព័ទ្ធសីមា។ **អភិសេកេ ទានេទរនេត្វា ទ្វេ នេត្វា ចក្ខុវិញ្ញាណំៗ** សូត្រ៣ចប់រួចបើកព្រះនេត្រព្រះ។ **ក្រូវេតិភា មហាព្រហ្មអង្គលីខិតិពិស្សនេ ភិញ្ចិ ប្រសិទ្ធិ មេ**



www.elibraryofcambodia.org

**ស្វាហា** ។ សូត្រ ពាចប់កាន់ម្ជុលកើសព្រះនេត្រព្រះ ។ **តស្ស ទេន ឃាទេន បិសិត្វា សម្មាសម្ពុទ្ធស្ស សិរីមតោ សទ្ធម្មញ្ច សព្វជិត្វា ភត្វា សង្ឃស្ស សបញ្ញំ សិនបច្ចការសេតសតស្ស រតនតយេ អនុភាវេន អសេសិត្វា អតិមេត្តា សម្មាសោជី៚** សូត្រ ពាចប់រួចកាន់ព្រាក់ក្រវាសព្រះនេត្រ ។ **បក្ខរូបកំ កម្ពលំ ថតំសិត្វា ទេ្វ ហត្ថា នាវិបសិរឃុទហេ ឥតិបិសោ ន ស្វាខ្យាតោ៚** សូត្រ ពាចប់លត់បកផ្ទៀងសូត្រ **កេសេម្មូលកេសាបិកថា ខមិំនត្តាវនានេធនតេនត៚** ខាត់ព្រះនេត្រព្រះ ។ **កេសម្មូលកេសា សព្វពុទ្ធេហិ ទេសិតា ភមនភាយ និព្វានំ នញ្ច វិទ្ធិនត្ថិ ៚** នេះដាក់ព្រះកេសាព្រះ ពាចប់ ។ **តិនេត សំហេសតនា តេបញ្ចតិសនោ ៚** ពាចប់អោយប្រួចទឹក ។ **ឥមស្មឹ រាជាសីមានា ខេត្ត សមន្តា សតិយា ជនសត្តសហស្សាន ពុទ្ធំ ជាសមរក្ខន្តិ សូរក្ខន្តិ និធម្មំ ជាបរក្ខន្តិរក្ខន្តិ សុរក្ខន្តិ បិសំឃំជាលបខិបិរក្ខន្តិ សុរក្ខន្តិ ៚** នេះពាក់សីមាចាប់អំបោះសីមា ។ **ឥមស្មឹ រាជសីមានា អក្ខរសន្តា លេខយន្តសព្វពន្ធំៗ អរហំៗ ៚** ធេងអំបោះសីមានឹងបង្គោល ។ ពាចប់ ។



www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| បូពិ | | បូពិ | ភូមនិសេទេវតា ឥរក្ខន្តុ | | តលឥសានសិ - |
| អាគ្នេយ៍ | ល្វសាន | អាគ្នេយ៍ | អាកាសនិសេទេវតា | | តភូប អាកាស |
| ទក្សិណ | ទិសេពជ្រ ៧ ពន្ធំ ។ | ទក្សិណ | ឥរក្ខន្តុ | | ៣ចប់ |
| នីរតី | នេះឈរជើងសីមា | នីរតី | | | |
| បស្ចឹម | ពាន់អំបោះនិងសីមា | បស្ចឹម | និសេទេវតា ឥរក្ខន្តុ ។ នេះទ្រូតជើង | | |
| ពាយព្យ | បង្គោល ៣ចប់ | ពាយព្យ | ស្មេហ៍ ។ ឥតិ តណ្ហា ឥតិ ត្សមារំ ឥតិ | | |
| ឧត្តរ | | ឧត្តរ | នារា ជុំកោលិហិ ៧ ព្រះគង្ហីងព្រះធរណី | | |
| ល្វសាន | | ល្វសាន | យរសពុទ្ធា ឯហិ ៧ ពុទ្ធំ ធម្មំ សង្ឃំ និកាយ | | |

**អហារកំ សព្វពុទ្ធាលិហិៗ អហោ ឧទកានិសិទ្ធិតេ ជាលិហិៗ វាយេ សិទ្ធិតេ ជាលិហិៗ ហុំតវិសិទ្ធិតេជោ សបទាញ្ញុំ ភវន្តុ តេ សព្វសត្រូវ វិនាសន្តិ ៗ** នេះសូត្រដើររកនាងគង្ហីងព្រះធរណី ៣ចប់ ។ **ភសាកេសិសតោយជា គង្គាសោកំរាជតន្តិ មារសីមានា បតិថាតុំ អសុតោន្តា ជលាយឹសុ ពុទ្ធានុភាវេន មារសេនាបរាជិតា និសោ និសំវិធំ សេត្វា អសេសតោ ៗ** នេះគាថាផ្ចាញ់មារ ៣ចប់ ។

នេះស្រដីឯច្បាប់នឹងដាក់ដើមធមិទេសនា គឺសឹងដ៏មានកំនត់ដោយនៅឧត្តមផ្សំសទ្ធានេះឯងហោង ឯព្រះធម្មគោរព , ព្រះមហាល័យ , ព្រះមាតុគុណេ ដើមធមិបាទ ២ បូជាតំលឹង ៥ ព្រះតេមិយ .ព្រះជនក , ព្រះសុវណ្ណសាម , ព្រះនេមិរាជ ដើមធមិបាទ ៣ បូជាតំលឹង ៧ បាទ ១ , ព្រះមហោសថ ដើមធមិបាទ ១០ បូជាតំលឹង ១ តំលឹង២ បាទ ១២ , ភូរិទត្ត ដើមធមិតំលឹង ១ បូជាតំលឹង ៩ , ព្រះចន្ទកុមារ , ព្រះនារទ ដើមធមិបាទ ៣ បូជាតំលឹង ៧ បាទ ១



www.elibraryofcambodia.org

ព្រះពិធូរ ដើមធមិតំលឹង ១ បូជាតំលឹង ៩ , ព្រះវេស្សន្តរ ដើមធមិ បាទ ៦ បូជាតំលឹង ១៣ បាទ ២ , ព្រះបឋមសម្ពោធ នូវព្រះអភិសេក ដើមធមិតំលឹង១ បូជាតំលឹង ៩ , ព្រះធម្មចក្រ នូវនាងយសសន្ធភនិព្វាន , នូវព្រះនិព្វាន , ព្រះមាពាន់ , ព្រះទសវង្ស , ព្រះអនាគតវង្ស , ដើមធមិបាទ ៣ បូជាតំលឹង ៧ បាទ ១ អស់អានិសង្ស នូវចំពេងបុណ្យ ដើមបាទ ២ បូជាតំលឹង ៤ បាទ ២ ។ នេះប្រដាប់នឹងរៀបបូជាព្រះធម្មទេសនា ទាំងអស់គ្រប់ជាតិ បើនឹងរៀបបូជា អោយរៀបតាមក្បួនបង្គាប់នេះហោង ។

**ពុទ្ធំ**<br>
**ធម្មំ** } **ច និរោធន្តិ អរហំ និព្វានំ ទុរតិកមោ ៗ**<br>
**សង្ឃំ**

នេះប្រទក្សិណបុណ្យ ។

**អតិយនានំ សរំ ហោតុ និព្វចក្ខុបញ្ញា ឱភាស អហំ ភន្តេ សព្វសច្ចយេ ពហុលកំ មន្តលំ ភរោមិ ៗ** នេះបាលីនិមន្ត។ **ចក្ខុនិព្វានំ បរមសុខំ ៗ** នេះបាលីសូត្រឡើងពេលក្រវាសទៀន ។


www.elibraryofcambodia.org

*ឯកសារទី ៣*

# ក្បួនពុទ្ធាភិសេក

ក្បួននេះ អង្គការ FEMC បានថតចំលងចេញ ក្បួនពុទ្ធាភិសេក វត្តពោធិរតនារាម ឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្រកំពង់ចាម ។

ដោយមានភាពវែងអន្លាយ ក្បួនទី ៣នេះ ខ្ញុំមិនបានចំលងយក " ធមិពុទ្ធាភិសេក , ធមិយ៉ោក , ធមិផ្ចាញ់មារ " មកដាក់ក្នុងសៀវភៅនេះទេ។ ខ្ញុំគ្រាន់តែបានចំលងយក ពីរបៀបធ្វើពុទ្ធាភិសេក ពីបុរាណមកបញ្ជាក់ប៉ុននោះឯង ។



www.elibraryofcambodia.org

មនោបុព្វង្គមា មានចិត្តនោះប្រសើរជាដើម ជាប្រធាន។ មនោសេដ្ឋា មានចិត្តថ្លាសទ្ធាជាមង្គលប្រសើរនោះ។ មនោមយា មានចិត្តនោះជ្រះថ្លាហើយ មានពិព្យាយាមនោះច្រើន។ បពិត្រវីលោកដ៏ចំរើនអើយ ត្បិតលោកអាចារ្យនឹងចាចែងសំដែង ទំនងដើមបាលី ប្រែជាកិរិយាសេចក្តី តាមព្រះពុទ្ធឱស្ឋទ្រង់ត្រាស់ថ្លែងសំដែងថា ព្រះធមិវិសេសទេសនា មកទុកក្នុងគម្ពីរព្រះធម្មសម្តោធជាពិស្តារស្រាប់ហើយ ។

នេះនឹងនិទានជាសង្ខេបទេ នោះថាបើនរូបុរសបុគ្គលប្រុសស្រីឯណាមួយប្រកបដោយមនោចេតនា ទាំងលក្ខណៈជ្រះថ្លាបរិសុទ្ធជាអសង្ខារិក នឹកប្រនីរូបអង្គអាត្មាទីទៃ១ ហើយមកមានចិត្តកាត់តំលាសទ្ធា ប្រថ្នាមគ្គផល កុសលខ្វល់ខ្វាយចាយទ្រព្យផ្គផ្គាប់រណ្តាប់ចាត់ចែង ចេញឈ្នួល ទៅជួលជាងមកស្អាងអង្គព្រះពុទ្ធរូប ស្អាប់ស្អងព្រះសាសនា ជាកុសលទៅអនាគតកាលនោះ ទោះធ្វើនឹងបាយកំលោច ជាខ្នុក នឹងម្រក្សណ៍ក្តី ទោះធ្វើនឹងមាស នឹងប្រាក់ក្តី ទោះធ្វើនឹងទង់ហ្វាក្តី ទង់តាមទង់ដែងក្តី ធ្វើនឹង សំរិទ្ធ . ស្ពាន់ . សំនក្តី ធ្វើនឹងឈើខ្លឹម នឹងឥដ្ឋ នឹងថ្មក្តី សិលាក្តី ទោះតូចក្តី ធំក្តី។

លុះជាងនោះ ស្អាងរចនារួចជាសូរេចហើយ ទើបអោយអ្នកដើមការរៀបរកគ្រឿងប្រដាប់ នឹងធ្វើបុណ្យឆ្លងមគ្គផល ទោះនឹងទេសនា អោយចប់ទេសន៍ក្តី នោះរណ្តាប់សង់សាលា សង់រោងក្តី ទោះធ្វើបុណ្យ ធ្វើលើគោកក្តី លើទឹកក្តី។ កាលណា នឹងសង់សាលារោងរួចហើយ អោយរកប្រដាប់ធ្វើរាជវ័តិជុំវិញនោះហើយ វាស់អំពីសាលា រោង ចេញទៅអោយបាន ៨ហត្ថ ហើយអោយបោះច្បោះ ចងរាជវ័តិជុំវិញ ហើយទុកមាត់ទ្វារទាំង ៤ ទិសបូព៌ . ទក្សិណ . ឧត្តរ



www.elibraryofcambodia.org

បស្ទឹម ហើយអោយធ្វើឆត្រូត ដាកចារ តាមជួររាជវីតិជុំហើយ អោយធ្វើភានទេត្តា ដាក់គ្រប់ទិសទាំង ៨ ហើយអោយវាស់ពីរាជវីតិនោះ ទៅទិសបូពាំ ៩ហត្ថ ហើយអោយធ្វើភានទសបារមីធំ ចំទិសបូព៌ អោយធ្វើភានធំ ១ ដាក់ខាងឯជើង ទន្ទឹមនឹងភានទសបារមី នោះជាភានយមរាជ ចំងាយហត្ថ ១ ចំអាម១អំពីគ្នា អោយធ្វើមានដំបូលទាំងអស់ ភានធំទាំង ២នោះ មានថ្នាក់បី ហើយអោយមានរាជវីតិជុំភានធំនោះ អោយបាន ៣ហត្ថជុំវិញ។ ឯភានទិស ៨ នោះ អោយថ្នាក់ ២ ហើយធ្វើដំបូលទាំងអស់ដូចគ្នា ហើយទើបរកប្រដាប់កាត់ទង់ដាក់គ្រប់ទិសទាំង ៨ អោយមានគោមបង្ហួតខ្សែចងបន្តឹងរួចហើយ ទើបអោយរកប្រដាប់ធ្វើអកូសនៈ តំកល់ព្រះពុទ្ធរូបរួចហើយ ទើបអោយរាំងវាំងននបាំងនៅឯគ្រែចម្លាសនៈព្រះនោះ ខាងឯលើ អោយចងពិតានបាំងជាលំអ ហើយទើបអោយរៀបក្រាល នូវកំរាលឧត្តមថ្មុំថ្មើងល្អប្រសើរ ហើយទើបអោយអ្នកដើមការរករណ្តាប់ស្លាម្លូ ទៀនធូបទៅរកអ្នកឯណាមួយ មានតិរិះប្រាជ្ញាច្រើន ហើយដឹងចេះចាយចែករំលែកទានស្មើគ្នាល្អ អោយល្មមសមគួរតាមកំលាំងច្រើនតិច ហើយមានពិព្យាយាម បានរក្សា សីល ៥ ចាំសីល ៨ បរិសុទ្ធហើយ អោយអញ្ជើញយកមកជាចៅបង្គាប់ អោយរៀបប្រដាប់សំពត់ស សំលៀកបំពាក់វត្ថពន្ធស្តាយឆៀង ១ សំរាប់សឹងបរិសុទ្ធហើយ អោយប្រដាប់គ្រឿងស្លា គ្រឿងដំនេក គ្រឿងទឹក គ្រឿងបាយ សព្វគ្រប់ហើយ ទើបលើកប្រគល់ជូនទៅឧបបាតិកជាអាចារ្យស្រេចហើយ ទើបលោកអ្នកដើមការ អោយអាចារ្យមើលរកឫក្សពារពេលាថ្ងៃឯណាមានជោគស្រីសួរស្តីល្អ នឹងចូលរោង ជាដើមបុណ្យនោះ អោយអ្នកដើមការ រកគ្នាទៅនិមន្តព្រះពុទ្ធរូបចាស់បាន ១ អង្គ មកគង់ជាកសិណ អោយទាន់ពារពេលាល្អក្នុងថ្ងៃនោះ ហើយទើបយកគម្ពីរគ្រប់ទសជាតក៏


www.elibraryofcambodia.org

មកជាមួយនឹងព្រះពុទ្ធរូបនោះហើយ អោយអាចារ្យបង្គាប់អ្នកដើមការ អោយធ្វើបាយសី ៥ថ្នាក់ ១គូ មកដាក់ឆ្វេង ស្តាំ នៅអាសនៈព្រះហើយ អោយរៀបគ្រឿងបូជា ១ សំរាប់ដាក់ទៀនធូប លាជ ផ្កាភ្ញី អោយសព្វគ្រប់ហើយ អោយលើកមកតំកល់ថ្វាយព្រះហើយ ទើបនិមន្តព្រះថ្មីមកដាក់តំកល់អំពីមុខព្រះពុទ្ធរូបចាស់ ហើយទើបអោយអាចារ្យ យកអំបោះ ៣ សរសៃ មកចាប់បញ្ចូលគ្នាធ្វើអំបោះសីមាទាក់កព្រះពុទ្ធរូបចាស់មកព្រះពុទ្ធរូបថ្មី អោយគិតរកកន្លែងជំនុំសង្ឃ គង់សំដែងព្រះទិព្វមន្តនោះហើយ អោយអាចារ្យយកភាជន៍ ១ ថ្កល់ត្រៃ យកមកតំកល់ខាងស្តាំព្រះថ្មីនោះហើយ យកបាត្រមកដាក់ខាងឆ្វេងព្រះថ្មីហើយ យកផ្ចិតនៅយាមខាងស្តាំ អោយច្រូតចងស្បូវភ្លាំងនឹងស្លឹកពោធិ៍ មកចងជាមួយគ្នា បញ្ឈរខាងឆ្វេងនៅអាសនៈ ក្នុងសាលានោះហើយ ទើបអោយអ្នកដើមការ រៀបប្រដាប់ក្រុងពាលី ប្តឹងប្រាប់ព្រះស្រុកនោះ អំពីថ្ងៃរសៀលល្ងាចទើបនឹងរស្តង្គត ហើយអោយរៀបប្រដាប់ ទឹកអប់ ១គូ . ស្លាធម៌ ១គូ . ដាក់គ្រប់រានទាំង ៨ទិស ហើយអោយធ្វើកន្ទោង ៨ ដាក់ស្លាទិព្វពីរម៉ាត់ បារី ២ ដាក់កន្ទោងគ្រប់រានទាំង ៨ ទិស ធ្វើកន្ទោង ៨ ទៀត ដាក់លាជ ផ្កាគ្រប់រានទាំង ៨ នោះហោង ។

លុះព្រឹកឡើងទៀតនោះ អោយធ្វើកន្ទោង ៨ ដាក់ចំនី បង្អែមគ្រប់រានទាំង ៨ ទិសនោះតែសព្វថ្ងៃ ដឹងលក្ខណៈជ្រៅបរិសុទ្ធល្អប្រសើរ បាន ១ ព្រះអង្គ គង់ខាងលើ ជាអធិបតីធំ ហើយជំនុំព្រះគម្តែងសង្ឃ ប៉ុន្មាន ៧ អង្គក្តីមកគង់ជាជួរ អណ្តាប់របៀបរៀបរៀងប្រសើរហើយ ទើបអោយលើកអស់សំរាប់ទឹក ស្លា គន្ធាសព្វប្រគេនគ្រប់អង្គហើយ ទើបអោយអ្នកដើមការប៉ុន្មានអ្នកក្តី ជូនអស់គ្រឿងបរិក្ខារ សំពត់វត្ថព័ន្ធ នៅរបស់ល្អ អាក្រក់ តិចច្រើនក្តី



www.elibraryofcambodia.org

យកមកតាំកល់កណ្ដាលសាលានោះសព្វគ្រប់ហើយ ទើបអោយអ្នកដើមការប្រុស ស្រីធំតូច ប៉ុន្មាននោះមកសុំហើយ ទើបអញ្ជើញអាចារ្យជាចៅបង្គាប់ មកអង្គុយ លើកំរាលសមគួរហើយ ទើបអោយអ្នកដើមការ ធំតូចប៉ុន្មាន១ លើកអស់គ្រឿង បរិក្ខារ ច្រើនតិច ល្អ អាក្រក់ វត្ថុអ្វី១ ទាំងអស់នោះ ជូនទៅលោកអាចារ្យ ជា កសិណា អោយលោកចាត់ចែងបែងចែកចាយបូជា ធម្មទេសនា ក្នុងការកុសល បុណ្យនោះ អោយគ្រប់បានជាបច្ច័យនៃទាន ជាស្ពានទៅពួដ៏អនាគត ដូចសេចក្ដី យើងប្រាថ្នា ទើបអាចារ្យនោះ ទទួលយកអស់សំពត់វត្ថុ នោះមកទុកក្នុងកន្លែង សមគួរ ទើបអាចារ្យនោះនាំអស់អ្នកដើមការ តូចធំ ស្រីប្រុស របស់ទ្រព្យ ប៉ុន្មាន ១ ចូលទៅប្រណិបតន៏ លោកមហាថេរជាធំថា បពិត្រព្រះមហាថេរដ៏ ចំរើនអើយ យើងខ្ញុំជាអ្នកដើមការទាំងអំបាលនេះ សូមអារាធនា និមន្ត ព្រះករុណាជាអម្ចាស់ មកគង់នៅជាអធិបតី ពេជ្រញាណធ្វើជាធំ បំរើអស់យើង ខ្ញុំ ក្នុងទីស្អាងការកុសលនេះ សូមអោយអម្ចាស់ជួយទំនុកបំរុង តំរង់អស់យើងខ្ញុំ បានត្រង់តាមគន្លងព្រះពុទ្ធជាអម្ចាស់ ទៅពួដ៏អនាគត ទៀងទាត់ប្រាកដដូច សេចក្ដីប្រាថ្នាអស់យើងខ្ញុំ សូមពិតអម្ចាស់ជាប្រធានសាក្សី អោយអស់យើងខ្ញុំ ជាអំបាលនេះ ទើបមហាថេរទទួលថា សាធុ រួចហើយ ទើបអោយដំបូន្មានថា បពិត្រអស់អ្នកដើមការដ៏មានសទ្ធាចំរើនអើយ វិគន្លងធម៌ព្រះនោះគឺ សេចក្ដីនោះ អោយសង្រួមចិត្ត អោយទាននោះ ១ . ខន្តីនោះ កាន់ចិត្តអំនត់នោះ ១ . មេត្តា នោះ ១ អោយកាន់ចិត្តកតញ្ញូកតវេទី ជ្រះថ្លាល្អបរិសុទ្ធ អោយមានមេត្រីអានិត អាសូរល្អត្រាប្រនីរូបឯង រូបគេហើយ អោយអ្នកទទួលរក្សាសីល ៥ អោយខ្ជាប់ ក្នុងទីដែលអ្នកកំពុងស្អាងនោះ ទើបហៅស្គាល់ម្ដាយបរលោក អាពួកបរលោក នោះ គឺទានជាម្ដាយ សីលជាឪពុកនេះឯង តែងនឹងនាំរូបអង្គអាត្មាទីទៃ ១ ទៅ



www.elibraryofcambodia.org

តាមផ្លូវ សួគ៌ និព្វាន ដ៏ជាស្ថានបរមសុខប្រសើរទៀងប្រាកដហោង ។

ទើបអាចារ្យនូវអ្នកអស់អ្នកដើមការប៉ុន្មាន ៗ ទទួលថា សាធុ រួចហើយ ទើបថយមកអង្គុយដោយទៅទិសមគួរហើយ ទើបអោយអុជប្រទីបឈ្វាលា ក្នុងសាលានោះ ឯក្រៅសាលានោះ អោយបង្ហូត គោម ទង់ នូវកណ្ដឹង លើកឡើង អោយគ្រប់ទិស ហើយអោយបង្ហូតគោមគ្រប់ទិស ហើយអោយអុជទៀន ធូប គ្រប់ភានតូចធំឡើង ហើយទើបអោយអាចារ្យជាធំ ចេញទៅអារាធនា នៅភានធំនោះប្តឹងទេវតាគ្រប់ទិសរួចហើយ ទើបវិលចូលមកអង្គុយនៅកណ្ដាលសាលា ទើបអុជទៀន ធូបឡើង ហើយអោយក្រាបថ្វាយបង្គំ នមស្សការស្មាលាទោស ធ្វើកំហុស ធ្វើបាប កម្មពៀរវេរា អំពីថ្ងៃ ខែ ឆ្នាំ ណាក្តី នៅក្នុងជាតិនេះ ព្រេងជាតិនាយមកក្តី នោះខ្ញុំដើមការទាំងអស់អំបាលនេះ សូមស្មាលាទោសនោះ មាននៅកាយកម្ម វចីកម្មនោះ ខ្ញុំសូមលា កុំអោយចងពៀរវេរាកម្ម ទៅជាតិក្រោយវិញឡើយ ព្រះអម្ចាស់អើយ គង់ជាប្រធានសាក្សីជំរះបាប អោយអស់យើងខ្ញុំនោះហោង ។

លុះធ្វើស្មាលាទោសរួចហើយ ទើបនមស្សការថ្វាយបង្គំព្រះទៅហោង រួចហើយទើបអាចារ្យក្រាបថ្វាយបង្គំ សូមអារាធនា សូមស្មាទានសីល តាមលក្ខណៈ រួចទើបអារាធនានិមន្តព្រះមហាថេរ នៅជំនុំសង្ឃសូត្រព្រះទិព្វមន្ត ព្រះមហាសម័យ អញ្ជើញទេវតាមកជាសាក្សី ហើយអោយអុជ ទៀន ធូប ស្លាធមិ ទឹកអប់ ទឹកសម្បួរឡើង ។លុះសូត្រព្រះទិព្វមន្តចប់ហើយ ទើបអោយគោះគង ទូងភេរី លេងភ្លេងដូរ្យជន្ត្រីឡើង ទទួលកំសាន្តព្រះធមិទៅហោង ។ ហើយអោយគ្រែធម្មាអាសនា ជើងអាធារ ហើយអោយចងព្យួររំយោលផ្កាភ្ញីមាលា ស្លាធមិ ពាក់សំយុងនោះហើយ នៅជើង ហើយទើបអារាធនានិមន្ត



www.elibraryofcambodia.org

ព្រះគម្ពែងសង្ឃ សំដែងព្រះធម្មទេសនា ក្នុងគម្ពីរព្រះធម្មគោរព . ព្រះមហាល័យ. ព្រះមាតុគុណ ហើយអោយបិតប្រាក់បូជាដើមធម៌ស្លឹងបី អោយគ្រប់ព្រះធម៌នោះ លុះទេសនាចប់ហើយ ទើបអោយបូជាព្រះធម៌ តាមកំលាំងទ្រព្យច្រើនតិច ជាឧត្តម អ្នកមធ្យម អ្នកមានសទ្ធា តាមតែអាចារ្យរិះគិតអោយល្មមសមគួរ នឹងទ្រព្យតិចច្រើនហោង កុំអោយបង្គាប់បង្ខំទ្រព្យគេ។ មួយសោត បើទ្រព្យគេ តិច មធ្យម អោយធ្វើចោលពាក់កណ្តាល អោយទេសនាព្រះធម្មគោរព , ព្រះមហាល័យ , ព្រះមាតុគុណ , និង ព្រះមហោសថ ,ព្រះមហាជាតិ , ព្រះធម្មបឋមសម្ពោធ , អភិសេក ។

បើតិចអំពីនោះទៀត កុំអោយទេសនាគម្ពីរមហាជាតិ , ធម្មសម្ពោធ ,និង អភិសេក។ ឯគម្ពីរព្រះធម្មគោរព , ព្រះមហាល័យ , ព្រះមាតុគុណ កុំអោយចោលឡើយ បើតិចថយអំពីនោះទៀត លោកកុំអោយធ្វើឡើយ ហៅចោរប្លន់ព្រះធម៌ បាបណាស់ហោង។ មួយសោត ឯរណ្តាប់បូជា ព្រះធម៌ទេសនា ព្រះធម្មគោរព , ព្រះមហាល័យ , ព្រះមាតុគុណ ព្រះធម៌ទាំង ៣ នេះ ដាក់រៀបបូជាអោយស្មើនឹងព្រះធម៌ ព្រះតេមិយជាតក , ជនកជាតក , សុវណ្ណសាមជាតក, នេមិរាជជាតក , មហោសថជាតកនោះ អោយបូជាលើសដើមកំលាំង ឯព្រះភូរិទត្តជាតក , ចន្ទកុមារជាតក , នារទជាតកស្មើដូចដើម ឯព្រះពិធូរជាតក , វេស្សន្តរជាតក អោយលើសដើមពីកំលាំងហោង ។

ឯបិទប្រាក់ដើមបូជា ធម៌ទេសនា ទសជាតិនោះ ជាតិ ១ ដើមបិទស្លឹង១, ជាតិ ២ បិទស្លឹង២, ជាតិ ៣ បិទស្លឹង៣, ជាតិ ៤ បិទស្លឹង៤, ជាតិ ៥ បិទស្លឹង៥ , ជាតិ ៦ បិទស្លឹង៦, ជាតិ ៧ បិទស្លឹង៧, ជាតិ ៨ បិទស្លឹង៨, ជាតិ ៩ បិទស្លឹង៩, ជាតិ ១០ បិទស្លឹង១០។ មួយសោត បើកាលណាទេសនាក្នុងគម្ពីរទសជាតក៏នោះ


www.elibraryofcambodia.org

រៀងរាបទៅដល់គម្ពីរមហាវេស្សន្តរ នោះអោយអាចារ្យដាក់ប្រដាប់នឹង ទេសនាព្រះមហាជាតិនោះតាមគាថា : ទៀន ១ ពាន់ . ធូប ១ ពាន់ . ស្លា ១ពាន់ . ម្លូ ១ ពាន់ . ស្លាធ្វា . ថ្នាំ ១ ពាន់ . បាយពុំនូត ១ ពាន់ . ផ្កាឈូក ១ ពាន់ . ផ្កាក្រមុត ១ ពាន់ . ផ្កាកណ្ដៀង ១ពាន់ . ហើយប្រដាប់ធ្វើ ប្រទាសពាសពីលើ ហើយអោយធ្វើទង់ឆត្រ ១ ពាន់ ដាក់ពីលើនោះហើយ អោយចង រំយោលទង់នៅផ្កាភ្ញីផងទាំងពួងនឹងប្រទាសនោះ ធ្វើជាពិតានពាន់ ទើបអោយយកក្រមួន មកសូន្យជារូបដំរីបច្ច័យនាគេន្ទ្រ នៅរូបសេះទីមរទេះ នៅរូបព្រះវេស្សន្តរ នៅនាងមេទ្រី រូបបាជាលី នាងគ្រឹស្នា នៅរូបព្រាហ្មណ៍ ១ ហើយថ្កល់លើភាជន៍យកបកទេសនា ហើយអោយយកសំពត់ស មកក្រាលពីមុខគ្រែ សំរាប់បាចពរាងឯគ្រែទេសនានោះ អោយដាក់ឈមមុខទៅទិសបូពិ ដាក់នាក្រោមជើងផ្កាពាន់នោះ ទើបអោយយកជើងពីរ មកដាក់ទឹកអប់ ហើយដាំព្រលិត លំចង់ ទើបដាក់នៅមុខគ្រែឆ្វេង ស្ដាំ ហើយធ្វើបាយសី ៥ ថ្នាក់ ១ គូ មកដាក់ឆ្វេងស្ដាំរួចហើយ ស្លាធម៌កូនចេក ១ គូ មកដាក់មុខបាយសីឆ្វេងស្ដាំនោះ ឆ្វេងស្ដាំគ្រែនោះ ទើបយកជើងធំ ១ មកដាក់ទឹកអប់នៅមុខជើងអាចារ ដែលថ្កល់គម្ពីរនោះ អោយយកឈើមកដាក់ខ្វែង នៅមាត់ជើងនោះ ទុកសំរាប់នឹងអុជទៀនពាន់ ធូបពាន់នោះ ទើបអោយរកផ្លែឈើជាដើម គឺចេក . អំពៅ . ដូងទាំងឡាយ ធ្លាយស្លាទាំងស្មែងនូវខ្នុរ ក្រូច នូវផ្លែឈើផង អោយដាក់ពាក់ចងទាំងដើម ទាំងធ្លាយ . ទាំងចង្កោម អោយល្អ មានផ្កាផ្លែ ចងព្យួររំយោលជុំវិញ អោយដូចស្ថានព្រៃហិមពាន្ត . ស្ថានភ្នំគិរីវង្កត បូជាធម៌ទេសនា គំរប់ ១០ជាតិ ទោះនឹងទេសនា មហាជាតិក្ដី ព្រះគាថាពាន់ក្ដី អោយចប់តែ ១ថ្ងៃ ហើយអោយអុជទៀនពាន់ ធូបពាន់ នោះថ្វាយគ្រប់ទាំង ១៣កណ្ឌ តាមរណ្ដាប់ ។



www.elibraryofcambodia.org

លុះសំដែងចប់ហើយ ទើបអោយអាចារ្យនូវអ្នកដើមការ លើកអស់គ្រឿងប្រដាប់ដែលបូជាធម៌ទេសនាប្រគេនគ្រប់កណ្ឌ ទើបលោកទទួលរួចហើយទើបភត្តា **ភវតុ សព្វមង្គលំ ...** ២ ឯទាយកអ្នកដើមការ ទទួលប្រួចទឹកសំរេចមគ្គផលទៅហោង ។

វីអាចារ្យនឹងបង្គាប់អ្នកដើមការផងទាំងពួង អោយរៀបរណ្ដាប់អភិសេកនោះមាន ៣ប្រការ គឺឧក្រិដ្ឋ ១ , មជ្ឈិម ១ , តូច ១ ។ ឯឧក្រិដ្ឋនោះ គឺវីរិយាធិក : អោយរៀបធ្វើឆត្រូត ១៦ ឆ្វេងស្ដាំ ចាមរ បៃមន់ សែនត្វ័ន ទាំង ៣ មុខនេះ សឹងតែ ១៦ ឆ្វេងស្ដាំ ១ មុខ ក្មេងកុមារី ១៦ ទឹកអប់ ១៦ ស្លាធម៌ដូង ១៦ វីក្មេងជាទេ[១] ការក្សាអោយអង្គុយពីក្រៅនោះ ៩ នាក់ ទាំងឆ្វេងស្ដាំ អោយកាន់ស្លាធម៌កូនចេកគ្រប់ទាំង ៩ នាក់ នោះហោង រណ្ដាប់របៀបសឹងតែ ១៦ ឆ្វេងស្ដាំគ្រប់គ្រឿងបរិក្ខារទាំងអស់នេះ ឈ្មោះយ៉ាងឯកអភិសេកព្រះបាលីធំ បើរៀបសូត្រព្រះទិព្វមន្តគ្រប់ទាំង ៩ ទិសហោង ។

យ៉ាងទោអោយរៀបរណ្ដាប់ ធ្វើឆត្រូត ៨ ឆ្វេងស្ដាំ , ចាមរ , បៃមន់ , សែនត្វ័ន ៨ ឆ្វេងស្ដាំ ១មុខ ទាំង ៣មុខនេះ ក្មេងកុមារកុមារី ៨នាក់ឆ្វេងស្ដាំ , ក្អមទឹកអប់ ៨ ឆ្វេងស្ដាំ , ស្លាធម៌ដូង ៨ ឆ្វេងស្ដាំ ក្មេងប្រុសព្រហ្មចារីកាន់ស្លាធម៌កូនចេកនោះ ៩ នាក់គ្រប់ស្លាធម៌ទាំង ៩ នោះហោង នេះឈ្មោះយ៉ាងទោហៅសទ្ធាធិក រៀបរណ្ដាប់អ្វីៗ សឹងតែ ៨ ឆ្វេងស្ដាំ ១ មុខៗហោង។ មួយសោតវីធម៌នោះ អោយធ្វើឆត្រូត ១០ ឆ្វេងស្ដាំ ចាមរ , បៃមន់ , សែនត្វ័ន

---

(១) ច្បាប់ដើម : វ៉ីក្មេងជាទ្វេរ កែ ក្មេងទេ ។ កែក្ដីមិនកែក្ដី នៅតែពិបាកនៅតែយល់មិនបាន ។



www.elibraryofcambodia.org

ទាំង ៣មុខនោះ សឹងតែ ៥ ក្ដេងស្ដាំ ១មុខ ត្រូវជា ៣០ទាំង ៣មុខហើយ អោយធ្វើដងប្រវែងពីរហត្ថ ១ចំអាម ក៏បានហើយ ដោតដាក់នឹងដើមចេក ៥ម្ខាង ឯឆត្រូតនោះ អោយធ្វើ ៥រូត ១ដើម គ្រប់ទាំង ១០ ហើយធ្វើរូបភាព ជាសត្វទឹក សត្វហើរ លើគោក សត្វហើរ សត្វវារនៅដី នៅសព្វសត្វអម្រឹក បក្សី បក្សា អោយសព្វគ្រប់នោះ ទោះឆ្លាក់ឈើក្ដី ទោះនឹងគូរជាលំនៅក្ដី អោយ សព្វគ្រប់សត្វនោះហោង ហើយអោយយកក្អមថ្មីបាន ៨ មកគូរជាគំនូរលាបថ្នាំ អោយល្អ តាមចិត្តរចនាទុកជាមួយអន្លើ ហើយអោយយកផ្លែដូងបាន ៨ មកចិតធ្វើជារាងផ្កា អោយយកក្រមួនមកសិតធ្វើជាផ្កា ដោតនៅផ្លែដូងនោះ អោយដោតម្លូ ៥ ស្លា ៥ ផ្កាសិតនឹងក្រមួន ៥ , ទៀន ៥ , ធូប ៥ , ទៀនកណ្ដាល នោះ អោយយកឈើប្រវែង ១ ហត្ថ ១ ចំអាម មកដោតតអោយវែងឡើង ហើយ អោយយកកូនចេកបាន ៥ មកធ្វើជាស្លាធមិ កូនចេកប្រវែងហត្ថ ១ ចំអាម ១ ជើងនោះកំពស់ហត្ថ ១ ហើយដោតម្លូ ៣ ស្លា ៣ ហើយកន្ទាស់ ១ ដោតទៀនអុជ ហើយអោយបាយសី ៩ ថ្នាក់ ១គូ ទើបស្លាធមិកូនចេកនោះ ១គូ ប្រវែង ២ហត្ថ ១ ចំអាម ជើងកំពស់ហត្ថ ១ ហើយអោយដោតម្លូ ៩ ស្លា ៩ ដោតធ្វើជាថ្នាក់ ៣ ថ្នាក់ម្លូ ៣ ថ្នាក់ស្លា ៣ ហើយធ្វើ ស្លា ម្លូ ដោតចងព្យួរ រំយោលផ្កាភ្ញី អោយល្អទាំងគូ នោះហៅស្លាធមិទ្រង់គ្រឿង ។

យ៉ាងត្រី នេះហៅយ៉ាង តរិយា ព្រះបញ្ញាធិក ជាសង្ខេបតែប៉ុននេះ អោយអាចារ្យផងទាំងឡាយទាំងពួង ពិចារណាមើលរៀបតាមកំលាំងសទ្ធា អ្នកដើមការមានទ្រព្យច្រើន កុំអោយធ្វើអធ្យាស្រ័យឡើយ ហាក់ដូចជាអ្នកមាន ចង់អោយក្រ បើធ្វើអោយត្រឹមត្រូវតាមតរិយាក្បួនទាំង ៣ បទនេះ ហៅសាមី បរិចាកមហាប្រសើរពេក នឹងគណនា ឧបមាបីដូចអ្នកខ្សត់ចង់ជាអ្នកមាន អ្នក



www.elibraryofcambodia.org

សក្តិយសតូចទាប ចង់បានជាអ្នកធំ សក្តិយសធំនេះ ហៅថាសាមីទានប្រសើរហោង ។

អោយអាចារ្យពិចារណាមើល បើអ្នកដើមការនោះជាអ្នកហោង តិចទ្រព្យ អោយធ្វើតាមតិច បើច្រើនអោយធ្វើតាមច្រើន អោយល្មមសមគួរ កុំអោយសង្ខេបថយពេក អោយត្រូវតាមលក្ខណៈ តរិយាព្រះសាងបារមី ទាំង៣បទនោះ គឺ បញ្ញាធិក , សទ្ធាធិក , វិរិយាធិក ដោយឧត្តមមធ្យមសទ្ធា បទនេះអាចារ្យនឹងសំដែង តែផ្លូវបញ្ញាធិក ១ នេះជាសង្ខេប យ៉ាងតូចតិច អោយវិត្ថារតទៅហោង ។

មួយសោត កាលណាបើទេសនា ដល់ព្រះបឋមសម្ពោធនោះ អោយអ្នកដើមការ យកសង្ឃឹកមករៀបប្រដាប់ដាក់អោយគ្រប់គ្រឿងបរិក្ខារ អ្នកបួសជាដើមនោះ គឺត្រៃចីវរ , បាត្រ , ផ្តិត , ច្រត នៅគ្រឿងដំនេក , គ្រឿងស្លា , គ្រឿងបាយ , គ្រឿងទឹក នូវសារពើភោជនចំនី ផ្លែឈើផង តាមមានតាមគ្មាន រណ្តាប់អំពីនោះ អោយមានគម្ពីរសាស្ត្រា ជើងអាធារ ដែកចារ ស្នាប់ដៃផង នៅបំពង់អម្ពុល បំពង់ដីសផ្ទផង នូវចេស ខ្សែសាស្ត្រា ខ្សែបលុព្វ(១) សាស្ត្រាជាទឹកផង ។

រណ្តាប់ពីនោះ អោយមានកាំបិតបន្ទោះ , កាំបិតកោរ , កាំបិតវិន័យ ហើយអោយមានទាំងអន្លូង បន្ទេក បាតទ្វិត នៅជើងដែក រណោរ ដែកឆាប នូវផ្ទសំល្បៀង ផ្ទល្អិត ផ្ទគ្រាត នូវដែកភ្លើង ក្រដាស់ប៉ុយផង អោយសព្វគ្រប់កុំអោយខ្វះឡើយ បើគ្មានអោយអាចារ្យមើលប្រមាណប្រដាប់ ឯណាល្មម

(១) ខ្សែបលុព្វ ប្រហែលជាខ្សែចងព័ទ្ធរំសាស្ត្រាពីខាងក្រៅ ជួយពិចារណារកសំនេរនិងការប្រើ ។



www.elibraryofcambodia.org

សង្វេបបាន អោយអធ្យាស្រ័យលែងចោល តាមដោយនៅហោង គ្មាននោះហោង ។

លុះរៀបសង្សឹករួចហើយ អោយដាក់ខាងអាសនព្រះ ទុកជាមួយអន្លើហើយ ទើបអាចារ្យអោយអ្នកដើមការ រកក្មេងស្រីព្រហ្មចារី ៤ នាក់ ប្រុសព្រហ្មចារី ៤ នាក់ យកមកអោយងូតទឹកជំរះខ្លួនរួចហើយ ទើបស្អិតស្អាង លាបប្រេងម្សៅ ឯប្រដាប់ អោយស្លៀកស ស្ពាយឆៀងស ទាំងប្រុស ទាំងស្រីនោះអោយកាន់ក្អម ដាក់ផ្កាដូងលើ ហើយអោយក្មេងប្រុសបរិសុទ្ធ បាន ៩ នាក់មកស្អិតស្អាង អោយកាន់ស្លាធមិកូនចេកគ្រប់តួទាំង ៩ នាក់នោះហោង ឯអ្នកជូរជាតិ ពុំគួរ កុំអោយមកអង្គុយអភិសេក អោយយកឈើឯណា មានខ្លឹនក្រអូបនោះអោយយកមកទុកដុតដណ្តាំចង្ហាន់ មធុបាយាសនោះ អោយរកមកទុកប្រដាប់អោយសព្វគ្រប់អំពីថ្ងៃ ។

លុះទេសនាព្រះបឋមសម្ពោធចប់ហើយ ទើបអោយអាចារ្យ នូវលោកមហាថេរ ដ៏ជាអធិបតីធំតាក់តែង អោយអាចារ្យយកគ្រែធម្មាអាសនា ១ មករៀបតំកល់តំកើង នៅមុខព្រះអម្ចាស់នោះហើយ ទើបអោយក្រាលនូវកំរាលល្អទើបអោយយកស្បូវភ្លាំងទាំង ៨ កណ្តាប់នោះមកក្រាលហើយ ទើបនិមន្តព្រះថ្មីនោះមកគង់លើកំរាលស្បូវនោះ ទោះតំកល់នឹងភាជន៍អ្វីៗ អោយខ្ពស់រុងរឿងដូចម្តេចៗក្តី កុំអោយចោលស្បូវនោះឡើយ ហើយអោយយកស្វេតច្ឆត្រ មកចងបិទបាំងព្រះនោះហើយ អោយយកត្រៃចីវរមកថ្កល់ជាគូ នៅមុខព្រះភក្រ្តខាងស្តាំដាក់នៅមុខព្រះភក្រ្តខាងឆ្វេង ហើយយកផ្កាស្បូវភ្លាំង ដាក់នៅចំពោះព្រះភក្រ្តខាងជិតព្រះអង្គ អណ្តាប់អំពីត្រៃចីវរនិច្ចាមក អោយដាក់ជើងទឹកស្រះនោះទាំងសងខាងព្រះ ទើបអភិសេកនោះ ។


www.elibraryofcambodia.org

បាយសី ៩ ថ្នាក់ទាំងគូ ដាក់នៅខាងស្រះនោះ អណ្តាប់អំពីបាយសីនោះ មកអោយស្លាធមិទ្រង់គ្រឿងធ្វើនឹងកូនចេកទាំងគូនោះ មកដាក់នៅមុខបាយសីទាំងគូឆ្វេងស្តាំ អោយចន្លោះនៅមុខព្រះភក្ត្រ អោយប្រដាប់គ្រឿងបូជាទៀន ៥ , ធូប ៥ , លាជ ៥ , ផ្កា ៥ បិតថ្កល់ដាក់ភាជន៍នោះ មកដាក់បន្ទាប់ស្រះនោះ។ ឯស្លឹកពោធិ៍ដែលចងនឹងកូនឈើនោះ អោយដោតចងអំពីក្រោយព្រះហើយអោយយកផ្ចិតមកចងបញ្ឈរពីខាងស្តាំ អោយយកច្រតមកចងបញ្ឈរពីខាងឆ្វេង ហើយយកគម្ពីរដាក់ដែកចារស្នាប់ដៃ នូវស្លឹកសាស្ត្រា មកដាក់រុំផងគ្នា ហើយយកមកដាក់ពីខាងស្តាំ ជាមួយនឹងត្រៃ អោយយកថង់យាមដាក់គ្រឿងស្លានោះគឺអភិសេកតូចធំ ប្រនាកអកកំបោរ យកមកដាក់ពីខាងឆ្វេង ជាមួយនឹងបាត្រ អោយយកកាំបិតស្លាកោរ កាំបិតព្រះវិន័យ បំពង់ដីស ថ្ម បំពង់ម្ជុល នូវចេសផង ដាក់ក្នុងបាត្រនោះហើយ ទើបអោយយកព្រះឱង្ការមកតំកល់ នៅមុខព្រះភក្ត្រព្រះ ទើបអោយយកឆត្ររូត មកដោតដាក់សងខាង ឆ្វេងស្តាំ ព្រះអង្គនោះ ៤ម្ខាង អោយដោតចាមរម្ខាង ដោតបៃមន់ ៤ម្ខាង ដោតសែនត្វ័ន ៤ម្ខាងទាំងសងខាងឆ្វេងស្តាំ រួចហើយអណ្តោប់អំពីនោះ អោយរៀបដោតអស់រូបភាពសត្វអម្រឹក បក្សី នៅមេឆា ឆ្លាម ម្ករ ពិន្ទុង នូវសត្វវារ សត្វលូន សត្វសូតិសត្វហិមពាន្ត ស្រមុតនូវសារពើ សត្វទឹក សត្វគោក សត្វហើរ សត្វលូន សត្វវារនោះសព្វគ្រប់ហើយ ទើបអោយទុកចន្លោះកណ្តាល ប្រមាណទូលាយល្មមចុះ លោកគង់សូត្រ ពាហុំ ៩ អង្គបាន នៅសូត្រពុទ្ធាភិសេក ២អង្គផង ហើយយកក្អមដែលគូនោះ មកដាក់ជាពីររួចហើយ យកផ្កាដូងដាក់ថ្កល់លើមាត់ក្អមនោះហើយ អោយយកស្លាធមិទាំង ៩ នោះមក ដាក់ទៀបរៀបជាតំន អំពីក្អមទាំងសងខាងរួចហើយ លុះល្ងាចទើបអោយរៀបប្រដាប់ស្លាធមិ ទឹកអប់ សឹង ៨ នូវ



www.elibraryofcambodia.org

ទឹកសម្បូរ អំបោះមង្គលហើយ អោយយកបាយសី នៅស្លាធមិទឹកអប់ រណ្តាប់ ជាថ្មី អោយគ្រប់រៀបទេវតា ហើយស្លាជីព បារី នូវកន្ទោងធំមួយ ដាក់លាជ ផ្កា អោយគ្រប់វានទាំង ៨ នូវគោមដងទង់នោះ អោយរៀបរណ្តាប់ជាថ្មី ដាក់ ថ្វាយសព្វគ្រប់ដូចពោល់ អំពីដើមនោះហើយ អោយអាចារ្យយកអំបោះ ៣ សរសៃ មកចាប់ធ្វើជាសីមា អោយព័ទ្ធជុំវិញព្រះចាស់មកដល់ព្រះថ្មី រៀងដាក់ ចុងមកដល់ទីសូត្រព្រះទិព្វមន្ត នៅទីដែលលោកគង់ សូត្រពុទ្ធាភិសេក រួច សព្វគ្រប់ហើយ ទើបអោយអាចារ្យអុជទៀនធូប ទើបអប់ស្លាឡើងហើយ ទើប អោយអាចារ្យយកអំបោះមង្គល មកដាក់លើព្រះពុទ្ធរូបថ្មី ១ ដាក់លើគ្រែ ១ ទើបអោយអុជទៀនធូបថ្វាយនាងគង្ហីងព្រះធរណី នូវវានទេវតាតូចធំ នូវគោម ដងទង់ គ្រប់ទិសទាំងអស់សព្វគ្រប់ហើយ ទើបអោយអាចារ្យនោះ១ ចេញសូត្រ បាលីប្តឹងទេវតា នៅវានធំប្រជុំគ្រប់ទិសហើយ ទើបអោយអាចារ្យចូលមកអុជ ទៀនធូប ប្រទីបញ្ចាលាឡើង ក្រាបថ្វាយបង្គំព្រះ រួចសព្វគ្រប់ទាំងអ្នកដើមការ នោះហើយ ទើបអោយអាចារ្យអារាធនាសូមសីលរួច ទើបអោយនិមន្តមហាថេរ ជាអធិបតីធំ នៅព្រះតម្កើងសង្ឃ សូត្រព្រះទិព្វមន្តមង្គលបរិត្ត នូវមហាសម័យ អញ្ជើញអស់ទេវតា នូវព្រះធម្មចក្រ ឥតិបិសោ យន្តុទ្ទិមិតំ មង្គលចក្រវាល ស្រេចសូត្រមន្តហើយ អោយទូងភេរី បាញ់កាំភ្លើង អុជភ្ញីវន្ទា កញ្ចែចតាម លំដាប់លំដោយ តាមមានតាមបាន អណ្តាប់ពីនោះ អោយលេងភ្លេងតូរ្យតន្ត្រី នៅសារពើភ្លេងបន្លែងដង្ហែថ្វាយព្រះ កុំអោយស្ងាត់សោះសូន្យឡើយ ។

លុះសូត្រមន្តរួចហើយ ទើបអោយអ្នកដើមការ រៀបមកអោយលោក អាចារ្យ នឹងសូត្រថ្វាយព្រះលក្ខណៈ បើកព្រះនេត្រ ចំរើនព្រះកេសានោះ អោយរៀបគ្រឿងបូជា ១ សំរាប់ បិតទៀនលោកុត្តរធមិទាំង ៤នោះ ទៀន ១


www.elibraryofcambodia.org

ទំងន់តំលឹង ១ ទាំង ៥ នោះ ឯកំពស់ប្រវែង ១៩ ធ្នាប់ ១ . ៨ ធ្នាប់ ១ . ៧ ធ្នាប់ ១ . ៦ ធ្នាប់ ១ . ៥ ធ្នាប់ ១ . គ្រប់ទាំង ៥ នោះហើយ ធូប ៥ . លាជ ៥ . ផ្កា ៥ . ហើយអោយធ្វើទៀន ១ គូ ប្រវែង ១ ហត្ថ ១ ចំអាម ត្រូវជា ១ ចំអាម ព្រះ ដ៏ជាអម្ចាស់ នោះតំលឹង ៨ ក៏បាន . ៤ ក៏បាន យកមកតំកល់នៅឆ្វេងស្តាំ ព្រះភក្ត្រ អុជថ្វាយ អំពីល្ងាចដល់ព្រឹកឡើង ឯវណ្ណាប់ព្រះពិស្ណុការនោះ ផ្លែឈើ ៤ ឆ្វេង ស្តាំ ប្រាក់តំលឹងឆ្វេងស្តាំ សំពត់សហត្ថ ៥ ឆ្វេងស្តាំ ក្បាលជ្រូកម្សៅ ឆ្វេងស្តាំ បង្អែមចំអាបឆ្វេងស្តាំ ទឹកអប់ស្លាធមិ ៤ ឆ្វេងស្តាំ បាយសីធំ ៥ ថ្នាក់ ឆ្វេងស្តាំ ទឹកសម្បុរ ១ ផ្តិល ហើយរកម្ជុល ១ គូ កន្ត្រៃ ១ កាំបិតស្លាកោរមៀន មាស ១ យកមកដាក់ថ្កល់នឹងជើងពាន ទើបអោយក្រាលគឺ ចៀមចំព្រៃព្រំ ហើយទើបលើកអស់គ្រឿងប្រដាប់ដូចបង្ហាប់នោះ មករៀបជាជួរឆ្វេងស្តាំ នៅ មុខព្រះភក្ត្រព្រះថ្មីនោះ ហើយទើបអោយអាចារ្យអុជទៀនធូប ដោតបិទរស់ គ្រឿងប្រដាប់នោះឡើង ហើយអោយអាចារ្យសូត្រអញ្ជើញព្រះពិស្ណុការ ៣ ចប់ អោយអ្នកដើមការអធិស្ឋានសែន ៣ ដង ហើយទើបអោយអាចារ្យអុជទៀន លោកុត្តរទាំង ៥ នោះឡើង ទើបអោយអាចារ្យក្រាបថ្វាយបង្គំ នមស្សការ រួច ហើយ ទើបអោយអាចារ្យ សូត្របាលីថ្វាយព្រះលក្ខណៈ ៣ ចប់ សូត្របាលី ២ ចប់អោយឈប់ ហើយអោយយកទឹកសម្បុរ មកសូត្ររំងាប់បាចទៅលើព្រះថ្មី ទើបយកម្ជុលទាំង ២ មក សូត្របាលីបើកព្រះនេត្រនោះ ៣ ចប់ម្ខាង ហើយ ម្ជុល ២ នោះ មកគៀស ៣ ដងម្ខាង រួចហើយទើបយកកន្ត្រៃ មកសូត្ររំងាប់ ទើបយកកន្ត្រៃនោះ កាត់ក្រវាស អបទេស ៣ ដងហើយ ទើបយកកាំបិតកោរ មកសូត្រចំរើនព្រះកេសនោះ ហើយកាំបិតកោរនោះ ក្រវាស ៣ដង រួចហើយ ទើបយកទឹកអប់ក្រអូប មកស្រង់ជំរះព្រះអង្គ រួចហើយទើបលើកឡើង ដាក់



www.elibraryofcambodia.org

តំកល់លើកំរាលថ្មើងដូចដែលរិញ ទើបអាចារ្យក្រាបថ្វាយបង្គំ សូត្រថ្វាយព្រះលក្ខណៈ ៣ ចប់ទៀត ហើយសូត្រពោធិបក្ខិយធម៌ ៣ ចប់ នៅលោកុត្តរជ្ឈាន ៣ ចប់ ជា ៩ ចប់ទាំងបទនោះ រួចហើយទើបអាចារ្យនិមន្តមហាថេរ ដ៏ជាអធិបតីធំ មកគង់កណ្តាលទី កំរាលថ្មើងនោះហើយ ទើបសូត្រអារាធនា អញ្ជើញទសបារមី ព្រះត្រាស់ឯរអតីតកន្លង ទៅស្ថិតនៅស្ថានសួគ៌ ព្រហ្មលោកនាយក្តី ស្ថិតស្ថានឯណា១ក្តី មកសើរីទ្ធិទ្រទ្រង់អានិសង្ស ក្នុងស្នាងព្រះពុទ្ធរូបថ្មីនោះហោង ។

លុះពេលាយប់យូរជ្រៅទៅល្មម បានម៉ោង ៣ ជាបឋមយាម ១ នោះស្ងាត់ល្មមអ្នកចាស់ងងុយដេកហើយ ទើបអោយអាចារ្យយកអស់ក្មេងព្រហ្មចារីប្រុស ៤ . ស្រី ៤ នោះមករៀបអោយអង្គុយកាន់ក្អម ដាក់ផ្កាដូងលើនោះ ៤ នាក់ម្ខាង ប្រុសខាងស្តាំព្រះភក្រ្តព្រះ ស្រីខាងឆ្វេងព្រះភក្រ្តព្រះអង្គ ។

ឯអ្នកកាន់ស្លាធមិកំលោះ អង្គុយតអំពីអ្នកកាន់ក្អម ៤ ម្ខាងអង្គុយព័ទ្ធពីចុងបំផុត ១ អោយមានទៀនអុជទាំងអស់រាល់ផ្កា ស្លាធមិនោះ លុះរៀបស្រេចហើយ អោយទុកចន្លោះកណ្តាល អំពីទៀន ៥ ធូប ៥ នោះ អោយទូលាយប្រមាណលោកគង់សូត្រ ៣ហុំ នោះ ៩ អង្គបាន។ ឯអ្នកអង្គុយកាន់ផ្កា ក្អម នូវស្លាធមិនោះ អោយរៀបអង្គុយអមជាស្តាំឆ្វេង ពោកសូត្រពុទ្ធាភិសេក កុំអោយជិតពេកឆ្ងាយពេក ហើយអោយធ្វើបាយសី ៩ ថ្នាក់ឆ្វេងស្តាំ ដាក់ប្រទីបជ័យអុជថ្វាយកុំអោយលែងឡើយ ។

លុះកាលណាបើរៀបផ្គូផ្គាប់សព្វគ្រប់ហើយ ទើបអោយអាចារ្យអារាធនានិមន្តលោកមហាថេរ ជាភិក្ខុ ៩ អង្គក្តី ៨ អង្គក្តី មកគង់កណ្តាលអោយសំដែងអាបត្តិ រួចសព្វគ្រប់ហើយ ទើបអោយវន្ទាអារាធនាព្រះបារមីសូត្រនមស្សការ ក្រាបថ្វាយបង្គំរួចហើយ អោយអ្នកដើមការ ផ្តុំត្រៃសង្ខ បីបទ


www.elibraryofcambodia.org

កំសាន្តហើយ អោយតាំងភុម្មា ហ៊ោ ៣ ដងហើយ អោយអាចារ្យអនុមោទនា ៣ ដង ទើបនិមន្តលោកសូត្រនមស្សការ ពាហុំ ទទេ ៤ ចប់ពាហុំ ហើយមហាការុណិកោ ជយន្តោផង ៥ ចប់ ត្រូវជា ៩ ចប់ សូត្រតែជយន្តោ ១៩ ចប់ សូត្រតែត្រីបអភិសេកេ នោះ ៩ ចប់ទាំងអស់ត្រូវជា ៣៣ ចប់ហោង ។

បើលោកសូត្រពាហុំ បាន ៤ ចប់ហើយ ទើបអោយអាចារ្យកាន់ពពិលអុជទៀនឡើង ហើយអនុមោទនា បង្វិលពីស្តាំទៅឆ្វេង ជាទក្ខិណាពត្តិទៅ លុះដល់ចប់ព្រះធម៌នោះហើយ អោយអាចារ្យអ្នកកាន់ពពិលនោះ លុតជង្គង់ហើយកាន់ផ្ទុំ សូត្រវំងាប់ បក់ផ្សែងទៅលើព្រះថ្មីនោះហោង ។

ឯបង្វិលពពិលនោះ អោយលេងភ្លេងកន្ទោងហែទៅ។ លុះដល់ចប់ព្រះធម៌ហើយ ទើបអោយគោះរគាំង វាយគង ទូងភេរី លេងភ្លេងតូរ្យតន្ត្រី ទាំង ៥ កំសាន្តទៅហោង។ ហើយអោយអាចារ្យនិមន្តលោក ៥ អង្គ ពង់នៅទិព្វ ទើបអោយនិមន្តលោកបាន ២ អង្គ មកពង់សំដែងអាបត្តិ រួចហើយ ទើបអោយវន្ទាអារាធនា នមស្សការក្រាបថ្វាយបង្គំ រួចហើយ អោយគោះរគាំង ផ្លុំត្រែសង្ខ សូមប្រគំស្នែង វាយគង ទូងភេរី ៣ បទហើយ តាំងហ៊ោ ៣ ដង ទើបអាចារ្យតាំងនមោ អារាធនា ៣ ដងហើយ ទើបលោកតាំងនមោ សូត្រពុទ្ធាភិសេកនោះជាបទមហាកំសាន្តទៅហោង ។

ឯក្មេងអ្នកកាន់ផ្កា ក្អមទឹកអប់ទាំង ៨ នោះ អោយអ្នកអាចារ្យប្រដៅធម៌អដ្ឋង្គិកមគ្គ ៨ បទនោះគឺ សម្មាទិដ្ឋិ ១ , សម្មាសង្កប្បោ ១ , សម្មាវាចា ១ , សម្មាកម្មន្តោ ១ , សម្មាអាជីវោ ១ , សម្មាវាយាមោ ១ , សម្មាសតិ ១ , សម្មាសមាធិ ១។ ទាំង ៨ បទនេះ អោយអាចារ្យប្រដៅ អំពីស្រីរួចមកប្រុស អោយគ្រប់អ្នកកាន់ក្អមផ្កា ក្អមទាំង ៨ នាក់នោះ ឯអ្នកកាន់ស្លាធម៌ធំទាំង ៩


www.elibraryofcambodia.org

នោះ អោយអ្នកអាចារ្យប្រដៅធម៌ នវហារាទិគុណទាំង ៩ បទនេះគឺ ឥតិបិ សោ ភគវា អរហំ ១ , ឥតិបិ សោ ភគវា សម្មាសម្ពុទ្ធោ ១ , ឥតិបិ សោ ភគវា វិជ្ជាចរណសម្បន្នោ ១ , ឥតិបិ សោ ភគវា សុគតោ ១ , ឥតិបិ សោ ភគវា លោកវិទូ ១ , ឥតិបិ សោ ភគវា អនុត្តរោ បុរិសទម្មសារថិ ១ , ឥតិបិ សោ ភគវា សត្ថាទេវមនុស្សានំ ១ , ឥតិបិ សោ ភគវា ពុទ្ធោ ១ , ឥតិបិ សោ ភគវា ភគវាតិ ១ ។

ធម៌ទាំង ៩ បទនេះ អោយទន្ទេញគ្រប់ទាំង ៩ នាក់ ទំរាំតែលោកសូត្រពុទ្ធាភិសេក ចប់នោះ អោយអាចារ្យអធិដ្ឋាន ជាទេវតា ទាំង ៩ នាក់ អោយសូត្រសរសើរគុណព្រះ កាលព្រះអង្គបានត្រាស់ អោយអ្នកទាំងអំបាលនោះផ្ចិតផ្ចង់តំរង់ចិត្តអោយនឹងល្អ ហើយកុំអោយនឹកអំពីអំពើអធម្មកម្ម អាក្រក់នោះឡើយ ហើយអាចារ្យហាមប្រដៅអ្នកដើមការ ទាំងអស់តូចធំប៉ុន្មានៗ ដែលបានស្គាល់នោះ ផ្ចិតផ្ចង់តំរង់ចិត្តតាមគន្លង កុំអោយនឹកអំពីអំពើអធម្មកម្មលាមកអាក្រក់នោះឡើយ ហើយនឹងបានជ្រះអស់បាបពៀរវេរាកម្មប៉ុន្មានៗ នឹងបានដូចសេចក្តីប្រាថ្នា សព្វគ្រូអាត្មា ទីទៃៗ លុះដល់គ្រា តែសូត្រពុទ្ធាភិសេកចប់ហើយ អោយពោះរគាំង វាយគង ទូងភេរី លេងភ្លេងតូរ្យតន្ត្រី កំសាន្តមកបន្តទៅហោង ។

លុះដល់ពេលភត្តា ភវតុ អោយអាចារ្យនៅអ្នកដើមការទទួលច្រូចទឹកសិរីទ្ធិ មគ្គផលទៅហើយ ទើបអោយអ្នកដើមការ រកក្មេងប្រុស ២ នាក់ អោយមានសំលេងនោះពីរោះ មកអោយស្លៀកសហើយ អោយយកមកអង្គុយនៅមុខព្រះភក្ត្រព្រះ ហើយនៅលើកំរាលនោះ អោយក្រាបសូត្រនមស្សការថ្វាយបង្គំព្រះពុទ្ធរូបរួចហើយ អោយអង្គុយបត់ជើង ហើយលើកដៃប្រណមឡើង


www.elibraryofcambodia.org

តាំងសូត្រធម៌យោកជាបទព្រះធម៌យោក រៀងទៅដល់បទ នមោ មេ ថ្វាយជ័យព្រះមុន។ លុះដល់ចប់ហើយ អោយសូត្របទ ផ្ចាញ់មារ តទៅវិញទៀត ។

ឯអ្នកអាចារ្យនោះ បង្គាប់អ្នកដើមការអោយរៀបដណ្តាំបាយធ្វើមធុបាយាស អោយយកក្មេងព្រហ្មចារី ប្រុស ស្រី នោះ ចូលមកក្នុងពិធីមង្គលមកបកស្រូវរើសអង្ករ ដុសខាត់អោយល្អបរិសុទ្ធ លុះដល់អ្នកសូត្រផ្ចាញ់មារនោះចប់ហើយ ទើបនឹងដល់មជ្ឈិមយាម ម៉ោង ៣ នឹងភ្លឺនោះ អោយអាចារ្យយកក្មេងព្រហ្មចារីម្នាក់មកអធិដ្ឋាន បង្កាត់ភ្លើងដណ្តាំចម្អិនមធុបាយាសនោះ ក្មេងស្រី ៤ នាក់នោះ លោកសន្មត់អោយឈ្មោះជានាងស្រី សុជាតា ១ , ឈ្មោះនាង បុណ្ណទាសី ១ , ឈ្មោះនាងពៃសាខា ១ , ឈ្មោះនាង ឧអាទ័យ ១។ ឯក្មេងប្រុស ៤ នាក់នោះលោកសន្មត់ អោយឈ្មោះជា ចតុលោកបាលទាំង ៤ ព្រះបាទធតរដ្ឋ ១ , ព្រះបាទវិរុឡ្ហក ១ , ព្រះបាទវិរូបក្ខ ១ , ព្រះបាទកុវេរមហារាជ ១ ។

កាលនាងស្រីសុជាតា ដណ្តាំបាយមធុបាយាសនោះ ព្រះចតុលោកបាល ជាអ្នកល្បាតក្រៅ ក្រែងមារាធិរាជយកថ្នាំពិសមកដាក់ក្នុងមធុបាយាស ស៊ីងកាន់គ្រឿងអាវុធ គយឃ្លាំទាំង ៤ ទិស អោយបុរសម្នាក់ ជាទេវតា កាន់ឆត្របាំងអំពីលើក្បាល ចង្ក្រានអោយយកបុរសម្នាក់កាន់ដាវ អង្គុយពីខាងឆ្វេងស្តាំ ជួយដុតភ្លើង ហើយយកទឹកររប់ មកស្ងោររំងាស់អោយឆ្អិនអង្ករជាមុន ទើបអោយជាត់ចេញអោយស្រស់ ហើយយកទឹកដោះគោ ទឹកឃ្មុំ ទឹកអំពៅ នៅអស់គ្រឿងបង្អែមទាំងឡាយ នៅគ្រឿងក្រអូបសព្វគ្រប់ហើយ មកចាក់កូរអោយពុះល្អ កុំអោយខ្លោច កុំអោយបៀវចេញ អំពីមាត់ឆ្នាំងនោះ លុះឆ្អិនល្អហើយ អោយយកស្លឹកមកទ្រាប់បាតថ្ពិលចាក់រលាក់អេក អោយអស់កុំអោយសល់ឡើយ ហើយ



www.elibraryofcambodia.org

អោយរៀបជើងពានដាក់ផ្កា ១ ផ្តិល ទឹកអប់ ១ ជើងពានចង្ហាន់ ១ ជើងពាន ស្លា ១ អោយបិទទៀនគ្រប់ហើយ អោយផ្ទៀងមើល ។

លុះពេលាចូលមកវិញ ដណ្តឹងវិញទៀតថា ឧកាស បពិត្រលោកទេវតា អម្ចាស់ថ្លៃខ្ញុំអើយ សូមទានព្រះអង្គតើនហើយរឺនៅឡើយ ? ទើបអាចារ្យ ឆ្លើយប្រាប់ថា នៅឡើយនាង ។ ទើបរំកិលថយចេញទៀត បង្អង់បន្តិច ទើបចូល មកវិញទៀត ដណ្តឹងថា ឧកាស បពិត្រលោកទេវតា អម្ចាស់ថ្លៃខ្ញុំអើយ ព្រះអង្គ តើនហើយរឺនៅឡើយ ? ទើបអាចារ្យឆ្លើយថា ព្រះអង្គតើនហើយ ។ ទើបនឹង សោយព្រះស្រីរួច ។ ទើបនាងដណ្តឹងថា បពិត្រលោកទេវតា អម្ចាស់ខ្ញុំអើយ បើ ព្រះអង្គតើនហើយ ខ្ញុំសូមចូលទៅកាន់ព្រះអង្គបានរឺទេ ? ទើបអាចារ្យឆ្លើយ ប្រាប់ថា ពុំដឹងឡើយ ។ ចាំអញទៅក្រាបទូលព្រះអង្គ ទើបអាចារ្យប្រែមុខ ក្រាបថ្វាយបង្គំ ៣ ដងរួចហើយ ទើបប្រែមុខទៅស្រដីប្រាប់នាងវិញថា ព្រះអង្គ ជ្រាបហើយ ព្រះអង្គកុំអោយនាងចូលទៅឡើយ អោយនាងនៅស្ថានក្រៅនេះ ព្រះអង្គមានព្រះបន្ទូល អោយដណ្តឹងឈ្មោះនាង នាងឈ្មោះអ្វី ? ទើបនាងស្ទួយ ផ្កាប្រាប់ថា ខ្ញុំឈ្មោះនាងស្រីសុជាតា ទើបដណ្តឹងឈ្មោះនាង ស្ទួយទឹកអប់វិញ ទៀតថា នាងបន្ទាប់នោះឈ្មោះអ្វី ? ទើបនាងប្រាប់ថាខ្ញុំឈ្មោះ ពៃសាខា ។ ទើបដណ្តឹងឈ្មោះនាងស្ទួយចង្ហាន់ថា នាងបន្ទាប់នោះឈ្មោះអ្វី ? ទើបនាងប្រាប់ ថា ខ្ញុំឈ្មោះនាងបុណ្ណទាសី ។ ទើបដណ្តឹងឈ្មោះនាងស្ទួយពានស្លាថា នាងបន្ទាប់ ឈ្មោះអ្វី ? ទើបនាងប្រាប់ថា ខ្ញុំឈ្មោះនាងឧមាទ័យ ។ ដណ្តឹងឈ្មោះរួចហើយ ទើបអាចារ្យប្រែមុខ ទៅក្រាបថ្វាយបង្គំ ៣ ដងហើយ ប្រែមុខស្រដីប្រាប់វិញថា ឥលូវនេះ ព្រះអង្គមានព្រះបន្ទូល អោយមកដណ្តឹងនាងថា នាងមករកព្រះអង្គ មានបើប្រការប្រាថ្នាអ្វី ? ទើបនាងឆ្លើយថា ខ្ញុំបានលឺព្រះអង្គបានត្រាស់ប្រាជ្ញា


www.elibraryofcambodia.org

សារពេជ្រតាញាណហើយ ខ្ញុំនាំផ្កា គ្រឿងគន្ធ ទូវទឹកអប់ នាំចង្ហាន់ ពានស្លា មកថ្វាយ។ ទើបអាចារ្យស្រដីថា បើដូចនោះ ចាំអញទៅក្រាបទូល ទើបប្រែមុខ ទៅក្រាបទូល ថ្វាយបង្គំ ៣ ដងវិញទៀតរួចហើយ ប្រែមុខទៅស្រដីវិញថា ឥលូវនេះ ព្រះអង្គជ្រាបហើយ ទ្រង់ព្រះអំនរអនុមោទនា និងផលកុសលសទ្ធា នាង នាំមកថ្វាយព្រះអង្គ មានព្រះបន្ទូល កុំអោយនាងចូលមកឡើយ អោយនាង ប្រគល់មកអញ អញនឹងថ្វាយអោយនាង ទើបលើកប្រគល់អស់គ្រឿងប្រដាប់ នោះមក តែអាចារ្យអធិដ្ឋានក្រាបទូល សូត្របាលីថ្វាយសព្វគ្រប់ហើយ ទើប ប្រែមុខទៅស្រដីប្រាប់ថា ឥលូវនេះ អញថ្វាយអោយនាងរួចហើយ ព្រះអង្គ អនុមោទនា នឹងមានព្រះបន្ទូលផ្ដាំមកអោយនាងក្រាបថ្វាយបង្គំ ហើយអោយ អញអោយពរនាង ចូលនាងទទួលយកពរហោង។ ទើបអាចារ្យសូត្រសព្វពុទ្ធា ១ ចប់ ភវតុ ៣ ចប់ រួចហើយអោយជយចេញហោង ។

ទើបអោយសូត្រថា

| | | |
|---|---|---|
| អពា្កប់នោះហោ | នាងពៃសាខា | ថ្វាយមធុបាយាស |
| សឹងគ្រឿងទិព្វគន្ធ | ពេញទាំងភាជន៍មាស | ទើបនាងអង្គាស |
| | ពាដងស្រេចដល់ ។ | |
| លាយបានកងចក្រ | ទ្រង់ព្រះបុរសលក្ខណ៍ | បញ្ចង្គអស់គល់ |
| ស្ដេចសោយបាយាស | ឥតឯសំនល់ | ទើបស្ដេចតំកល់ |
| | លើកឡើងអធិដ្ឋាន ។ | |

រួចលែងចេញទៅ ហើយអោយអាចារ្យលើកភាជន៍ចង្ហាន់ បណ្ដែតបំផ្លេច ក្នុងស្រះឈូកនោះ រួចហើយអោយលេងមារដណ្ដើមបល្លង្គ។ ឯរបៀបបង់មាត់


www.elibraryofcambodia.org

មារនោះ នំ ១ ថាស កាស ១ ត្រនោត ដល់ចាប់មារនាំចូលមក អោយថ្វាយបង្គំព្រះហើយ អោយបើកសូត្រត្រង់ព្រះទ្រង់ទំនាយមារ ដល់សូត្រទំនាយមារចប់សព្វគ្រប់ហើយ ទើបអោយអាចារ្យនិមន្តលោកបាន ៨ អង្គ មកគង់ព័ទ្ធជុំហើយ អោយអាចារ្យអុជទៀន ៥ ធូប ៥ គ្រឿងបូជានោះ នូវប្រេងប្រទីបទាំង ៥ នូវប្រទីបបាយសីឆ្វេងស្តាំសព្វគ្រប់ហើយ អោយនិមន្តលោកសូត្រអភិសេកនោះ អោយសូត្រតែ ពាហុំ ៤ ចប់ រួចអោយសូត្រ មហាការុណិកោត្រឹមបទ ជយមង្គលេ ៣ ដង ហើយអោយឈប់បង្អង់ យកទឹកអប់មកស្រង់ព្រះរួចហើយ អោយសូត្រជយន្តោ ៣ ចប់តាមកំលាំង ទសបារមីទាំង ៣០ពត់ ដល់លោកសូត្រជយន្តោនោះ អោយអាចារ្យយកបុរសបរិសុទ្ធបាន ១៩ក្តី ៩ ក្តី មកអោយអង្គុយព័ទ្ធពីក្រៅជុំហើយ ទើបអោយអាចារ្យអុជទៀនពពិលទាំង ៥ ឡើងអោយសូត្រថា **ពុទ្ធោ មង្គលំ សម្ពុទ្ធោ ទិព្វចក្ខុមោ ៗ** ឯបង្វិលពពិលអភិសេកព្រះនោះ មិនមានកំនត់មនុស្ស កំនត់ពពិល កំនត់តែសង្ឃសូត្រ ជយន្តោ ៣០ ចប់គ្រប់ហើយ អោយជុំពពិលលត់ទៀន អោយសូត្រថា **សព្វរោគវិនិម្មុត្តោ ៗ លត់ ៗ** លត់ភ្លើងបក់ផ្សែងបញ្ចូលទៅលើព្រះថ្មីនោះរួចហើយ ទើបនិមន្តលោកភត្តា ភវតុ អោយអាចារ្យនូវអ្នកដើមការច្រូចទឹកសំរេចមគ្គផល ទៅហោង ហើយគោះរគាំង វាយគង ទូងភេរី លេងភ្លេងតូរ្យតន្ត្រី របាំចំរៀងកំសាន្ត ឯអាចារ្យនូវអ្នកដើមការ អោយទឹកអប់ក្រអូប មកស្រង់ព្រះអង្គស្រេចហើយ អោយថ្វាយបង្គំព្រះរាល់គ្នា អោយអាចារ្យយកគ្រឿងក្រអូប ក្រចេះជូងចន្ទន៍ មកស្រពស្រលាបលាបចិញ្ចើម ព្រះភក្ត្រព្រះអង្គទើបអោយនិមន្តព្រះថ្មីនោះ ដាក់តាំកល់លើអាសនៈខ្ពស់ប្រសើរ ហើយហើនឹងទេសនាក្រាជាតនោះ អភិសេករួចហើយ ទេសនាព្រះធម្មចក្រ ១ . ទេសនា



www.elibraryofcambodia.org

ព្រះអភិធម្ម ៧ គម្ពីរ ១ , ទេសនាពិម្ពាភិលាប ១ , ទេសនាសន្ធានិព្វាន ១ , ទេសនាព្រះនិព្វាន ១ , ទេសនាមារនិព្វាន ១ , ទេសនាអនាគតវង្ស ហើយអោយនិមន្តព្រះមហាថេរ នូវអស់ជំនុំសង្ឃ អោយបាន ១ អង្គឡើងទៅច្រើនជា ទើបនឹងទេសនាព្រះធម៌សង្គាយនាបាន បើតិចថយពុំបាន ១ អង្គទេ ហៅថារព្ទសង្គាយនា ទេសនាគ្រែ ២ ទៅហោង រួចអោយទេសនា កម្មពៀរ អានិសង្សអ្វី១ដែលសាងនោះ ទៅចំលងបុណ្យហើយ អោយប្រគេនសង្ឃីក នូវអស់គ្រឿងបរិក្ខារ ប្រដាប់គ្រឿងអភិសេកនោះរួចហើយ ទើបអោយរណ្តាប់ ពហូទេវា ឆ្លង សំរេចមគ្គផលទៅហោង។ ការអភិសេកយ៉ាងតូចសង្ខេប តែប៉ុននេះឯងហោង ។

នេះនឹងសំដែង មង្គលពុទ្ធាភិសេក ជាឯកទេសពិសេសទុកជាច្បាប់តទៅ អោយត្រូវតាមបទព្រះបាលី ពុទ្ធាភិសេកមាន ៣ ឈ្មោះបញ្ញាធិក ១ , អភិសេកយ៉ាងតូច ឈ្មោះសទ្ធាធិក ១ , អភិសេកយ៉ាងកណ្តាល ឈ្មោះវីរិយាធិក ១ ។

អភិសេកយ៉ាងធំទាំង ៣ នេះ បើព្រះពុទ្ធរូបនោះគឺព្រះបដិមា នៅព្រះបត់ ព្រះចូឡាមុនី ព្រះសុទ្ធាថ៌ ព្រះចេតីយ ព្រះអង្គតូច១ នោះនឹងអភិសេកយ៉ាងតូច បើព្រះពុទ្ធរូបព្រះជីវី ព្រះសុទ្ធាថ៌ ព្រះចេតីយ ព្រះអង្គធំ១ នឹងអភិសេកយ៉ាងធំ យ៉ាងកណ្តាលគួរ យ៉ាងតូចមិនគួរទេ ។

ឯរបៀបអភិសេកយ៉ាងតូចនោះ អោយធ្វើរណ្តាប់មានឆត្រទ្រួត ៤ , ចាមរ ៤ , បៃមន់ ៤ , សែនត្វែន ៤ , អភិរម ៤ , នេះសឹង ៤ ឆ្វេងស្តាំ សត្វហើរ, សត្វពោក , សត្វទឹក តាមបាន ក្មេងព្រហ្មចារី ប្រុស ៤ , ស្រី ៤ ស្លៀកស ខោនោះស មានក្អម ៨ ទឹកអប់ក្រអូប ស្លាធមិដួង ៨ ដូចសំដែងមកនេះសព្វគ្រប់



www.elibraryofcambodia.org

ហើយ នោះឈ្មោះបញ្ញាធិកយ៉ាងតូច ។ ឯអភិសេកយ៉ាងកណ្តាលនោះ អោយរៀបមានឆត្រូត , ចាមរ , បៃមន់ , សែនតូ័ន , អភិរម នោះសឹង ១ មុខ ៤ ផ្ទេងស្តាំ ដូចគ្នាហើយអោយមានសត្វហើរ , សត្វគោក , សត្វទឹក អោយមានក្មេងព្រហ្មចារី ប្រុស ៨ , ស្រី ៨ អោយស្បៀកសពានាស ក្អមថ្មី ៨ ស្លាធមិដូង ៨ ចង្ក្រាន ឆ្នាំង ១ , អំបោះមង្គលសីមា ស្លឹកពោធិ៍ ស្បូវភ្លាំង ។ អោយរៀបសូត្រមន្ត ៣ ថ្ងៃ ។ រកថ្ងៃអោយត្រូវពេញបុរណ៍មី ថ្ងៃបំផុតថ្ងៃដំបូង បាននៅថ្ងៃ ១៣ កើត អោយតាំងពិធីចូលរោងសូត្រមន្ត របៀបតូចប៉ុននោះ ។

លុះសូត្រមន្តរួច អោយរៀបទេសនាបឋមត្រាស់ យ៉ាងពិស្តារបាន ១ កណ្ឌ រឺ ២ កណ្ឌ ។ លុះចប់ហើយ អោយនិមន្តលោក ២ អង្គ សូត្រពុទ្ធាភិសេក លុះសូត្រចប់ហើយ វេលាព្រឹកឡើង និមន្តលោកដារឆាន់ វេលាថ្ងៃនោះនឹងទេសនាហើយ នឹងចង់លេងភ្លេងអ្វី កំដរបុណ្យក៏តាមចិត្ត ។ ដល់ល្ងាចសូត្រមន្តទៀត លុះរួចហើយ អោយទេសនាបឋមត្រាស់ជាតំនទៅទៀត បាន ២ កណ្ឌ រឺ ៣ កណ្ឌ លុះចប់ហើយអោយក្មេង ២ នាក់ ដែលមានសំលេងចេះបទ អោយសូត្រធមិយ៉ោក , ផ្ចាញ់មារ ដល់ថ្នាក់ដណ្តាំចង្ហាន់ នោះអោយយកក្មេងព្រហ្មចារី ប្រុស ៤ , ស្រី ៤ នាក់ ចូលមកតាំងពិធីបុកស្រូវរើសអង្ករ ដណ្តាំមធុបាយាស រួចរឿងបុណ្យ លុះដល់ព្រឹកឡើងនឹងចូលជាថ្ងៃ ១៥ កើតនោះថ្វាយចង្ហាន់មធុបាយាសរួចស្រេច អោយរៀបសូត្រមន្តទៀតជាគំរប់ ៣ ថ្ងៃ អោយតាំងបាយសីធំ ៧ ថ្នាក់ ១ គូ ។ រៀបពិស្តុការ ប្រាក់ ៥ បាទ ត្រាប្រសាទ របៀបក្រៅពីនោះដូចគ្នា សូត្រមន្តរួច អោយទេសនាបឋមត្រាស់ តទៅទៀត អោយចប់ទាំងគម្ពីរ លុះវេលាទៀបព្រឹក អោយលេងម៉ាលើកមកដណ្តើមបល្លង្គ អោយរៀបរកក្មេងមានសំលេងពិរោះ មកសូត្រសរសើរបារមី ចង់ផ្ចាញ់មារ



www.elibraryofcambodia.org

វេលាបែកបច្ចូស  អោយនិមន្តលោក ៩ អង្គ មកសូត្រ ៣ហ៊ុំ ៤ ចប់ ហើយអោយសូត្រជយន្តោ  អភិសេកអោយបាន ៥៦ ចប់  តាមកំលាំងព្រះពុទ្ធគុណ នោះអោយអាចារ្យអុជទៀនពពិលឡើង បង្វិល ហើយសូត្របាលីដូចនិទានមុននោះ  ហើយអោយបាញ់កាំភ្លើង លេងភ្លេងតូរ្យតន្ត្រី អោយគោះរគាំង វាយគង ទូងភេរី តាំងប៉ោអោយខ្ទរខ្ទាយទ្រហឹងអឺងកង ។

លុះគ្រប់ព្រះធមិហើយ  អោយអាចារ្យផ្លុំពពិល រំងាប់លត់ភ្លើង បក់ផ្សែងទៅលើព្រះថ្មីនោះហើយ បើកព្រះនេត្រ ចៀរព្រះភក្ត្រ  ទើបអោយអ្នកដើមការយកទឹកអប់មកស្រង់ជុំរះព្រះអង្គ   រួចទើបយកគ្រឿងគន្ធពិដោរ  មកលាបស្រលាបព្រះអង្គ  រួចនាំគ្នាអុជទៀន ធូប ឡើង  នមស្សការថ្វាយបង្គំ រួចហើយទើបនិមន្តលោកឆាន់រួចទេសនា  ព្រះធម្មចក្កប្បវត្តនសូត្រ  ដូចនិទានមុននោះសព្វគ្រប់ហើយ   ទើប ពហូ ទេវា ឆ្លង  ទេសនាអានិសង្សព្រះពុទ្ធរូប  សូរេចមង្គលការ  អភិសេកយ៉ាងកណ្តាល ចប់តែប៉ុននេះឯងហោង ។

ឯរបៀប  អភិសេកយ៉ាងធំនោះ  រៀបមានឆត្ររួត , ចាមរ , បៃមន់ , សែនតូន  អភិរមនោះ សឹងតែមួយមុខ១  អោយបាន ១៦  ឆ្វេងស្តាំ ដូចគ្នាអោយមានសត្វហើរ , សត្វគោក , សត្វទឹកដូចគ្នា  ក្មេងព្រហ្មចារី ប្រុស ១៦ , ស្រី ១៦ , ក្អមថ្មីដាក់ទឹកអប់ ១៦ , ស្លាធមិដូង ១៦  សឹងឆ្វេងស្តាំ ដូចគ្នា ក្មេងកាន់ក្អមផ្កាដូងនោះ  អោយស្លៀកសពានាសដូចគ្នា   ហើយរកក្មេងព្រហ្មចារីបាន ៩ នាក់  អោយកាន់ស្លាធមិកូនចេកទាំង ៩ នោះ  សន្មត់ជាទេវតា រក្សាខាងក្រៅដូចសំដែងមុននោះ។  ឯសូត្រមន្ត ៣ ថ្ងៃ  តាំងពិធីចូលរោងសូត្រមន្ត ៨ ទិស និងទិសក្នុងសូត្រមន្ត  រួចអោយទេសនាបឋមត្រាស់ ១ កណ្ឌ ២ កណ្ឌក្តី អោយយ៉ាងពិស្តារ  ហើយអោយអាចារ្យយកអំបោះ  មង្គលសីមាទៅទាក់ឯក្រៅរោងសាលា



www.elibraryofcambodia.org

មកព័ទ្ធជុំវិញ ហើយចូលមកក្នុងរោងសាលា ទាក់អោយជុំទាំង ៨ ទិស នោះ ហើយទើបអោយទាក់ពីព្រះចាស់ មកព្រះថ្មីនោះ អោយទាក់កន្ទុយ អោយដល់ មកទីដែលលោកសូត្រពុទ្ធាភិសេក សូត្រ ៣ហ៊ុំ ... ជយន្តោ នោះ បើនឹងតាំងពិធី សូត្រមន្ត ៣ ថ្ងៃនោះ អោយរកថ្ងៃពេញបុណ៌មីជាថ្ងៃបំផុត ទំនងបាននៅថ្ងៃ ១៣ កើត តាំងពិធីចូលសូត្រមន្តរបៀបដូចមុន ទាំង ៨ ទិស ឯអំបោះមង្គល ព្រះនិស្ស័យ ដែលទាក់ពីព្រះចាស់មកព្រះថ្មីនោះ ទាញទៅដល់ទីសូត្រមន្តទាំង ៩ ទិសនោះ ទាំង ៣ ថ្ងៃនោះ លុះសូត្រមន្ត អោយទេសនា បវមត្រាស់ ១ កណ្ឌ ២ កណ្ឌ ៣ កណ្ឌក្តី អោយពិស្តារដល់ចប់ នឹងនិមន្តលោក ២ អង្គមកសូត្រពុទ្ធាភិសេក ចប់ហើយឈប់វេលាព្រឹកឡើង អោយនិមន្តលោកដារឆាន់ វេលាថ្ងៃ នោះ នឹងចង់ទេសនាក្តី នឹងលេងភ្លេងរបាំរឺ១ កំដរមង្គលការ មកដល់ល្ងាច ក៏តាមចិត្ត លុះដល់វេលាល្ងាច អោយសូត្រមន្តទៀត។ សូត្រមន្តរួចហើយ អោយទេសនាបវមត្រាស់ ជាតំនទៅទៀត បាន ១ កណ្ឌ ២ កណ្ឌក្តី អោយ ពិស្តារទៅ លុះចប់ហើយ អោយរកក្មេងបាន ២ នាក់ ហានសំលេងពិរោះចេះបទ យកមកអោយសូត្រធមិយោគ ផ្ទាញ់មារ ដល់ផ្ទាក់ដណ្តាំចង្ហាន់មធុបាយាស អោយក្មេងព្រហ្មចារី ប្រុស ៤ , ស្រី ៤ នាក់មកសន្ទត់ អោយនាមឈ្មោះ ដូចរឿងមុននោះ លុះព្រឹកឡើងនឹងចូលដល់ថ្ងៃ ១៥ កើតពេញបុណ៌មីនោះ ត្រូវ ថ្វាយចង្ហាន់មធុបាយាស អំពីព្រឹករួចស្រេចហើយ លុះល្ងាចអោយរៀបរបៀប ទាំងអស់ គ្រឿងអភិសេកនោះ ប្រដាប់ក្មេងប្រុសស្រី មកអោយអង្គុយកាន់ក្អម ស្វាធមិផ្កាដូង នៅអស់គ្រឿងឆត្ររូត , ចាមរ , បៃមន់ , សៃនត្ទន , អភិរម នោះ មករៀបដាក់ជាជួរឆ្វេងស្តាំ នៅភាពរូបសព្វសារពើ គ្រឿងអភិសេក តាមយ៉ាងធំ ហើយតាំងរៀបរណ្តាប់ ព្រះពិស្ណុការ ប្រាក់ ៥ តំលឹង ត្រាប្រសាទ


www.elibraryofcambodia.org

បាយសីធំ ១ គូ ៩ ថ្នាក់ ស្លាធម៌ទ្រង់គ្រឿង ១ គូ ធ្វើនឹងកូនចេកកំពស់ ៣ បត្ត។ វីប្រដាប់ក្រៅពីនោះ ដូចយើងបានសំដែងមកពីមុន ជាពិស្តារស្រាប់ហើយ រណ្ដាប់នឹងថ្វាយព្រះលក្ខណានោះអោយសព្វគ្រប់ កុំអោយសង្ខេប កុំអោយខ្វះឡើយ មកតំកល់ទុកជាអណ្ដាប់ ជាជួរឆ្វេងស្ដាំហើយ អោយចងពិតានរនាំងបាំងសន្ទិយា អោយចងទង់តូចទនូវភ្ញីផ្ការំយោល ក្នុងទីសាលារោងនោះ ជាសងខាង ជាលំអប្រសើរ សព្វគ្រប់ដូចសំដែងមកអំពីមុននោះ អោយរៀបប្រដាប់ដាក់រានទេវតា តូចធំ អោយសព្វគ្រប់ហើយ ទើបអោយព័ទ្ធសីមា ក្រៅក្នុងសាលារោងនោះជុំវិញហើយ អោយពាក់ទាក់ពីព្រះចាស់មកព្រះថ្មី ទាញអោយដល់មកទី សូត្រមន្ត ពុទ្ធាភិសេកនោះ លុះវេលាល្ងាចហើយ អោយអុជទៀនធូបថ្វាយទេវតារួច អាចារ្យចេញទៅអារាធនា រានតូចធំ ចូលមក អោយអុជទៀនប្រទីបឈ្វាលាឡើង ហើយថ្វាយបង្គំព្រះ អារាធនា ទសបារមី ប្រកាសទេវតារួច អារាធនាសូត្រស្មាទានសីលរួច អោយនិមន្តលោកសូត្រមន្ត រួចអោយទេសនាបឋមត្រាស់ វិន្នា លុះចប់ហើយ វេលា អោយលេងមារលើកទ័ពមកដណ្ដើមវត្ថុបល្ល័ង្ក បុរស ២ នាក់អោយសូត្រសរសើរបារមីព្រះហើយ លុះចប់មារ បាននាំមារមកថ្វាយបង្គំព្រះ ។

បើកសូត្រត្រង់ព្រះទ្រង់ទំនាយមារនោះរួចហើយ លុះវេលាបែកបច្ចូសនោះ អោយអាចារ្យនិមន្តលោកប្រមូលអំពីទិសទាំង ៨ មកជុំនៅទីក្នុង គង់ព័ទ្ធជុំវិញ កាន់អំបោះព្រះនិស្ស័យ ដែលព័ទ្ធពីព្រះនោះមកកាន់គ្រប់អង្គហើយ និមន្តលោក ពាហុំ ទទេ ៤ ចប់ ហើយមហាការុណិកោ ត្រឹមបទជយមង្គលេ អោយបាន ៩ ចប់ ត្រូវជា ៩ ចប់ហើយឈប់ យកទឹកអប់មកស្រង់ព្រះ រួចទើបនិមន្តលោកសូត្រ ជយន្តោ អភិសេកនោះ អោយបាន ១០៨ ចប់ តាមកំលាំងអដ្ឋវស្ស



www.elibraryofcambodia.org

មង្គល ១០៨ មានក្នុងព្រះអង្គព្រះ ឯបាសក អោយអង្គុយព័ទ្ធពីក្រៅជុំវិញ ទើប អោយអាចារ្យអុជទៀនពពិលទាំង ៩ ឡើង បង្វិលពីស្តាំ ទៅឆ្វេង ជាទក្ខិណោពតិ ហើយសូត្រថា **ពុទ្ធោ មង្គលសម្ភូតោ សម្ពុទ្ធោ ទីបទុត្តមោ ៗ** ហើយបង្វិលទៅ បើមានលេងអ្វី អោយលេងភ្លេងកន្ទោងដង្វាយសព្វសាធុការ តាំងហោអោយពេញអំនាចទៅ លុះលោកសូត្ររួចហើយ អោយអាចារ្យផ្លុំពពិល ទាំង ៩ នោះ រំងាប់បក់ផ្សែងសូត្រថា **សព្វរោគវិនិម្មុត្តោ ៗ** លត់ភ្លើងបក់ ផ្សែងចូលស្រេចហើយ អោយអាចារ្យយកម្ជុល ១ បើកព្រះនេត្រព្រះអោយ សូត្រថា **ពលីយតេ ពុទ្ធមន្តានំ ៗ** បើចេះសូត្រអោយសូត្រ **សុរោ មេ** ទើបអោយអុជទៀនព្រះពិស្ណុការ ស្វាហោទោស សូត្របើកព្រះនេត្រព្រះហើយ យកម្ជុលវាសវង់ព្រះនេត្រ ទាំងឆ្វេងស្តាំ អោយសូត្រថា **តថាគតោ ទិព្វចក្ខុំ វិសោធយិ ជយំ ទេវមនុស្សានំ ៗ** បីរុឡូរួចស្រេចហើយ អោយអ្នកដើមការយកគ្រឿងក្ររូបមកជុំរះព្រះអង្គ ហើយថ្វាយបង្គំគ្រប់គ្នាទៅ ទើបអោយអាចារ្យយកគ្រឿងក្ររូប ចៀមភក្ខ ស្រេចហើយ អោយលេងភ្លេង គ្រប់ល្បែង កំសាន្តទៅ ទើបអោយទេសនាដូចសំដែងមកនោះហើយ ទើប ពហូ ទេវា ឆ្លង សំរេចមង្គលអភិសេក យ៉ាងធំចប់តែប៉ុននេះហោង ។

អភិសេក យ៉ាងតូចពពិល ៥ អកបង្វិល . យ៉ាងកណ្តាលពពិល ៧ មក បង្វិល យ៉ាងធំពពិល ៩ មកបង្វិល ។


www.elibraryofcambodia.org

# បញ្ចុះព្រះលក្ខណៈ

នេះនឹងសំដែង អំពីបុរសបុគ្គលណាមួយ ថាបើសាងព្រះពុទ្ធរូបតូចណាស់ នឹងបញ្ចុះព្រះលក្ខណៈ ពុំបានឡើយ។ បើដល់ថ្ងៃណា នឹងអភិសេកនោះ អោយរៀបរណ្តាប់ព្រះពិស្ណុការ ប្រាក់ ៥ តំលឹង សំពត់ស ៥ ហត្ថ ផ្លែឈើ ៤ បាយសី ៥ ថ្នាក់ ១ គូ ស្លាធមិ ៨ ទឹកអប់ ៨ គ្រឿងបូជា លាជ ផ្កា ទៀន ធូប ស្លាធមិ ៤ ទឹកសម្បុរ ១ ផ្តិល អោយសព្វគ្រប់ដូចសំដែងមក អោយអាចារ្យសូត្រថ្វាយ ព្រះលក្ខណៈរួចហើយ ទើបនឹងអភិសេកបានបោង ។

## បញ្ចុះព្រះកេស

## សព្វញ្ញុតញ្ញាណបវរសីសំ ឱ

## បញ្ចុះមោឡី

## និព្វានារម្មណបវរវិសសិតកេសំ ឱ

## បញ្ចុះនៅថ្ងាស

## ចតុត្ថជ្ឈានបវរលលាដំ ឱ



www.elibraryofcambodia.org

បញ្ចុះចិញ្ចើមទាំងពីរ

នីលកសិណសោភាតិកណ្ឋបវរភមុយុគ្គលំ ២

បញ្ចុះព្រះនេត្រទាំងពីរ

ទិព្វចក្ខុ បដិញ្ញាណចក្ខុ សមន្តចក្ខុ ពុទ្ធចក្ខុ ធម្មចក្ខុ
បវរចក្ខុទ្វយំ ២

បញ្ចុះនៅផ្ចិម

វជិរសមាបត្តិញ្ញាណបវរឧណ្ណាភាសុំ ២

បញ្ចុះព្រះកាមាទាំងពីរ

ទិព្វសោតញ្ញាណបវរសោតទ្វយំ ២

បញ្ចុះព្រះឃានទាំងពីរ

គោត្រភូញ្ញាណបវរឧតង្គឃានំ ២

បញ្ចុះព្រះមកលាពុថ្ពាល់ទាំងពីរ

មគ្គផលវិមុត្តិ ផលញ្ញាណបវរគណ្ឌទ្វយំ ២


www.elibraryofcambodia.org

បញ្ចុះព្រះឱស្ឋឈើក្រោម

លោកិយលោកុត្តរញ្ញាណបវរឱដ្ឋទ្វយំ ២

បញ្ចុះវង់ព្រះឱស្ឋធ្មេញ

សត្តតឹសបវរពោធិបក្ខិយញ្ញាណបវរសុក្កទន្តា ២

បញ្ចុះព្រះចង្កូមទាំងបួន

ចតុមគ្គញ្ញាណបវរចតុទាឋា ២

បញ្ចុះអណ្តាត

ចតុសច្ចញ្ញាណបវរជីវ្ហា ២

បញ្ចុះចង្កាក្រោម

អបជិហាគញ្ញាណបវរហនុកំ ២

បញ្ចុះដើមស្បូរង

អនុត្តរវិមោក្ខានិគមនញ្ញាណបវរខណំ ២

បញ្ចុះផ្ចិតស្បូរង

តិលក្ខណញ្ញាណបវរវិលសត្តតិទវិរាជិតំ ២


www.elibraryofcambodia.org

បញ្ចុះព្រះហស្តទាំងពីរ

ចតុវេសារជ្ជញាណបទរពាហទ្វយំ ២

បញ្ចុះម្រាមព្រះហស្តកណ្តាលខាងស្តាំ

ទសានុស្សតិញាណបទរវត្តង្គុលិសោភា ២

បញ្ចុះដើមទ្រូង

សត្តពោជ្ឈង្គបទរបិនទ្វរត្តលំ ២

បញ្ចុះដើមដោះទាំងពីរ

អសយានសយញាណបទរថនយុគ្គលំ ២

បញ្ចុះចុងដង្ហើម

ទសពលញាណបទរមជ្ឈិមង្គំ ២

បញ្ចុះចង្កេះខាងស្តាំ

បដិច្ចសមុប្បាទញាណបទរនាភិបញ្ចិន្ទ្រិយបញ្ចពលបទរជ
យនំ ២

បញ្ចុះភ្លៅទាំងពីរ

ចតុសមប្បធានបទរឩរុទ្វយំ ២



www.elibraryofcambodia.org

បញ្ចុះព្រះជង្គង់ទាំងពីរ

នសក្កុសលកម្មបថបវរជង្ឃទ្វយំ ២

បញ្ចុះព្រះបាទទាំងពីរ

ចតុរិទ្ធិបាទបវរបាទទ្វយំ ២

បញ្ចុះនៅសង្ឃាដី

សលសម្មាចញ្ញាណបវរសង្ឃាដី ២

បញ្ចុះនៅចីពរ

ហិរោកប្បញ្ញាណបវរបំសុក្កូលចីវរំ ២

បញ្ចុះនៅស្បង់

អដ្ឋន្តិមកមគ្គញាណបវរអន្តរវាសកំ ។

បញ្ចុះវត្ថពន្ធទ្រូង

ចតុសតិបដ្ឋានបវរកាយពន្ធនំ ២

អញ្ញេសទេវមនុស្សានំ ពុទ្ធោ អតិវរោ ចតិយ បន មត្តិកឆ្លាទិញ្ញាណំ សព្វញ្ញុតាទិកំ ធម្មាកាយមតីពុទ្ធានមេតំ លោកនាយកំ ធម្មកាយពុទ្ធលកនំ យោគាវចរកុលបុត្តេ



www.elibraryofcambodia.org

**តិក្ខញាណេន សព្វញ្ញុពុទ្ធភាវំ បជ្ជេន្តេន បណោនបនំ អនុស្សរិតព្វំ ៗ**

បើសូត្រថ្វាយព្រះលក្ខណៈបានពីរចប់ហើយ ទើបអាចារ្យសូត្រ អញ្ជើញព្រះពិស្ណុការ រួចហើយអោយសូត្ររំងាប់ ទើបគេអោយម្ហូលពីមកកាន់ឡើង ហើយយកមង្គលវាសវង់ព្រះនេត្រ ទាំងស្តាំ ទាំងឆ្វេង សូត្រថា **តថាគតោ ទិព្វចក្ខុំ វិសោធយិ ជយំ ទេវមនុស្សានំ ៗ**

បើចប់ហើយ ទើបយកម្ហូលបីមកវាសវង់ព្រះនេត្រ បីដងម្ខាង១ រួចយកកន្ត្រៃមក ទើបអោយសូត្រចំរើនព្រះកេសដូចនេះ **កេរស្សស្ស កេសា នន្ទិត្វា សព្វេ ពុទ្ធេ ហិ ទេសិតំ និព្វានំ ខមនក្ខាយ ៗ** បីចប់រួចហើយ ទើបអោយយកកាំបិតស្លាកោរ ជរះព្រះកេស រួចទើបអោយយកទឹកអប់មកស្រង់ជរះព្រះអង្គ រួចអោយយកគ្រឿងក្រអូបមកជរះព្រះភក្ត្រហើយស្រលាបលោបព្រះអង្គសព្វគ្រប់ហើយ ទើបលើកឡើង ដាក់តាំកល់ យកអំបោះព្រះនិស្ស័យពុទ្ធដូចដែលវិញ ហើយទើបអាចារ្យក្រាបថ្វាយបង្គំ កាន់អំបោះនិស្ស័យឡើង សូត្រថ្វាយព្រះលក្ខណៈមួយចប់ទៀត ជាបីចប់ ហើយទើបអោយសូត្រព្រះ ចតុរារិយសច្ច ពោធិបក្ខិយធម៌ បានបីចប់ហើយ សូត្រលោកុត្តរជ្ឈាន ៩ ចប់ ។

ក្បួននេះ ខ្ញុំបានសង្ខេបខ្លីប៉ុននេះ ។



www.elibraryofcambodia.org

*ឯកសារទី ៤*

ចំលងយក

# ពិធីពុទ្ធាភិសេក

ដែល

## សម្តេចព្រះមហាសុមេធាធិបតី

## ជ.ណា ជោតញ្ញាណោ

## ព្រះសង្ឃរាជ គណៈមហានិកាយ

រៀបរៀង



www.elibraryofcambodia.org

# ពិធីពុទ្ធាភិសេក

ការស្រោចស្រប់ រឺដដុះរលោស់ ព្រោះព្រំនូវសុគន្ធវារីថ្វាយព្រះពុទ្ធរូបដែល ទើបកសាងថ្មី ហៅថា **ពុទ្ធាភិសេក** ។ ពិធីនេះជាប្រពៃណីដែលពុទ្ធបរិស័ទ បានធ្វើអស់កាលយូរអង្វែងហើយ ជាប់មានដរាបមកដល់ សម័យយើងសព្វថ្ងៃ។ បណ្ឌិតអ្នកប្រាជ្ញពុទ្ធសាសនិកទាំងឡាយ មាន **ព្រះនាគសេនមហាថេរ** ជាដើម បានធ្វើតាមលំរាននរឿងដែល **ព្រះមហាបុរស-សិទ្ធត្ថ-សក្យមុនី-គោតម** ទ្រង់បានត្រាស់ដឹងនូវ **អនុត្តរសម្មាសម្ពោធិ** បានដល់នូវឋានៈជា **ព្រះអរហន្តសម្មាសម្ពុទ្ធ** ព្រាកដឡើង នៅពេលខាងចុងបច្ឆិមយាមនៃរាត្រីពេញបូណ៌មីខែពិសាខនោះ ព្រោះតែព្រះអង្គបានផ្ចាញ់មារហើយ បានត្រាស់ជា **ព្រះសម្ពុទ្ធ** ភ្លាម ក៏កើតមានអព្ភូតហេតុជាមហស្ចារ្យ ទេពតាឥន្ទព្រហ្មទាំងឡាយ និម្មិតខ្លួនតូចៗ ល្អិតៗ មកប្រជ្រៀតញ៉ាំពែនណាន់តាន់តាប់ បន្លឺវាចាអឹងអាប់ ថ្វាយពរថ្វាយជ័យ ចំពោះព្រះសម្មាសម្ពុទ្ធថា "**ព្រះពុទ្ធមានសិរី-ទ្រង់ឈ្នះហើយ ! មារមានបាបចាញ់ព្រះអង្គហើយ**[១] !" មិនត្រឹមតែបន្លឺឧឡោសនវាចាថ្វាយពរជ័យប៉ុននោះទេ . ទេពតាឥន្ទព្រហ្មទាំងនោះ ថែមទាំងបាចសាចសុគន្ធបុប្ផាទិព្វព្រោះព្រះសុគន្ធវារីទិព្វ . គន្ធព្វទេពតា ទាំងឡាយ ប្រគំតូរ្យតន្ត្រីទិព្វថ្វាយពរថ្វាយជ័យ ចំពោះព្រះសព្វញ្ញូសម្ពុទ្ធផងទៀត . ដោយ

---

(១) ឧឡោសនាការនេះ នឹងមានបាលីគាថាប្រាប់ទៅខាងមុខក្នុងពិធីពុទ្ធាភិសេកសង្ខេប ។ ចូរអានគាថានោះចុះ ។



www.elibraryofcambodia.org

អំនាចដ៏ក្រៃលែង។ ព្រះមហាបុរសទ្រង់បានត្រាស់ច្បាស់ជា **ព្រះអរហន្ត-សម្មាសម្ពុទ្ធ**រួចស្រេចហើយយ៉ាងនេះ ទើបអទិស្សមានកាយ (១) ទាំងឡាយមាន ទេពតាជាដើម បាននាំគ្នាមូលមកសម្ដែងសេចក្ដីគោរពចំពោះព្រះអង្គ។ ព្រោះ ហេតុនេះឯង បានជាពិធីនេះឈ្មោះថា **ពុទ្ធាភិសេក** ពីការបាចសាចប្រោះព្រំ សុគន្ធបុប្ផានឹងសុគន្ធវារីទិព្វ ថ្វាយស័ព្ទសាធុការពរជ័យចំពោះព្រះអង្គដោយ សោមនស្សចិត្ត នឹងសេចក្ដីជ្រះថ្លាក្រៃលែងនៃពពួកអទិស្សមានកាយមាន ទេពតាជាដើម បន្ទាប់ពីវេលាដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធរួចស្រេចហើយ **ពុំមែនព្រះអង្គបានត្រាស់ជាព្រះសម្ពុទ្ធដោយសារពពួកអទិស្សមានកាយថ្វាយព្រះអង្គទេ ២** ព្រោះហេតុនេះហើយ បានជាព្រះពុទ្ធទ្រង់មាន ព្រះ **នេមិត្តិកនាម** ថា **សម្មាសម្ពុទ្ធោ** ដែលមានអត្ថន័យថា " ព្រះអង្គ ត្រាស់ដឹងដោយប្រពៃ នូវញេយ្យធម៌ទាំងពួងដោយព្រះអង្គឯង ឥតមានទេពតា ឥន្ទព្រហ្ម រឺមនុស្សណាធ្វើអោយព្រះអង្គបានត្រាស់ឡើយ " ។

ដោយមានរឿងនេះជាមូលហេតុ , ទើបពុទ្ធបរិស័ទគ្រប់ប្រទេស ធ្វើពិធីពុទ្ធាភិសេក។ ពិធីនេះ ពុំសុទ្ធតែដូចគ្នាតែបែបមួយទេ គឺពុទ្ធសាសនិកជនខ្លះធ្វើដោយពិធីពិស្ដារ ខ្លះធ្វើដោយពិធីមធ្យមយ៉ាងកណ្ដាល ខ្លះធ្វើដោយពិធីសង្ខេបខ្លី តាមយោបល់និងតាមការលៃលក កុំអោយតែខានពុំបានធ្វើពិធីនោះសោះប៉ុននោះ ព្រោះគេជឿជាក់ថា ព្រះពុទ្ធរូបដែលគេបានកសាងថ្មីនោះ ទុកស្មើដូច

---

(១) អទិស្សមានកាយ ប្រែថា " សត្វពិសេសដែលមានរូបរាងកាយ ប៉ុន្តែមនុស្សយើងមើលពុំឃើញ " ។



www.elibraryofcambodia.org

អង្គព្រះពុទ្ធ ដែលទើបបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិថ្មី១ , គេគ្រាន់តែធ្វើពិធីអភិសេករំលឹកតាមលំអានរឿងនោះ កុំអោយតែខានធ្វើសោះ ដើម្បីអោយបានផលានិសង្សជាថ្មីថែមឡើងទៀតប៉ុននោះ . គេពុំមែនយល់ថាអភិសេកព្រះពុទ្ធរូបអង្គថ្មីអោយបានត្រាស់ទេ ។

**ពិធីពុទ្ធាភិសេកពិស្តារ**៉ នៅប្រទេសកម្ពុជា សឹងមានពណ៌នាក្នុងក្បួនបុរាណស្រាប់ហើយ ខ្ញុំមិនបាច់ថ្លែងទេ , ការគួរធ្វើដោយសព្វគ្រប់តាមក្បួនបុរាណ នឹងការមិនគួរធ្វើត្រង់ពិធីណាខ្លះនោះ គួរពុទ្ធបរិស័ទពិចារណារិះរេដោយហ្មត់ចត់ អោយឃើញតាមការណ៍ពិត និងការណ៍ពុំពិតចុះ ។

ក្នុងពិធីពុទ្ធាភិសេកពិស្តារនោះ , មានពុទ្ធសាសនិកជនបរទេសខ្លះ គេធ្វើអោយត្រូវត្រង់ថ្ងៃ ១៤ កើត និងថ្ងៃ ១៥ កើតខែពិសាខ តាមតែក្នុងឆ្នាំណាក៏ដោយ។ នៅថ្ងៃ ១៤ កើត គេរៀបគ្រឿងសក្ការបូជាថ្វាយព្រះពុទ្ធរូបអង្គថ្មី , តាំងពីពេលព្រលប់រហូតដល់ភ្លឺ គេធ្វើពិធីចំអិនមធុបាយាស ដែលហៅថា **និរុទកមធុបាយាស** គឺមធុបាយាសគោកគួរពូតជាពំនូតបាន។ គេថ្វាយព្រះពុទ្ធរូបអង្គថ្មី នៅពេលព្រឹកព្រលឹមនៃថ្ងៃ ១៥ កើត ខែពិសាខ អោយត្រូវតាមលំអានរឿងនៃនាងសុជាតា ដែលថ្វាយមធុបាយាសចំពោះ **ព្រះសិទ្ធត្ថ**៉**សក្យមុនី**៉**គោតម** ២ នៅថ្ងៃ ១៥ កើត ខែពិសាខនោះ , តាំងពីពេលព្រលប់រហូតដល់ភ្លឺ , ជាពិធីពុទ្ធាភិសេក។ គេបញ្ចប់ពិធីនេះនៅពេលព្រឹកនៃថ្ងៃ ១ រោច ។

**ពិធីពុទ្ធាភិសេកមធ្យម**៉ គឺពិធីយ៉ាងកណ្ដាល មិនវែងមិនខ្លីពេក។ តាមប្រពៃណី រីទំលាប់ក្នុងប្រទេសកម្ពុជាយើង , ទោះនៅថ្ងៃ , ខែ , ឆ្នាំ ណាក៏ដោយ , ពុទ្ធបរិស័ទធ្វើពិធីពុទ្ធាភិសេកមានរបៀបជារយៈ ៩ សង្កាត់ គឺ



www.elibraryofcambodia.org

**សង្កាត់ទី១.** រៀបគ្រឿងសក្ការបូជាមានផ្កាស្រស់ៗ នឹងទៀនធូបជាដើម ថ្វាយព្រះពុទ្ធរូបអង្គថ្មី ។

**សង្កាត់ទី២.** និមន្តព្រះភិក្ខុចំរើនព្រះបរិត្ត ។

**សង្កាត់ទី៣.** និមន្តព្រះធម្មកថិកមួយអង្គសំដែងរឿងបឋមព្រាស់ ។

**សង្កាត់ទី៤.** និមន្តព្រះភិក្ខុ ១ អង្គ រឺ ២ អង្គ សូត្របាលីពុទ្ធាភិសេក ។

**សង្កាត់ទី៥.** សូត្របទ **ធម្មប្បដិយោគ** ដែលធ្លាប់ហៅថា **ធមិយ៉ោគ ៗ**

**សង្កាត់ទី៦.** សូត្របទផ្កាញ់មារ[(១)] ។

**សង្កាត់ទី៧.** និមន្តព្រះសង្ឃសូត្របាលីគាថា **ពុទ្ធជយមង្គល** គឺធម៌ **ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ ។បេ។ មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។** រួចសូត្រ **មហាការុណិកោ នាថោ ។បេ។ ហោតុ តេ ជយមង្គលំ ។** រួចសូត្រ **ជយន្តោ ពោធិយា មូលេ ។បេ។ លភន្តត្ថេ**

---

(១) បទធម្មប្បដិយោគ ( ធមិយ៉ោគ ) និងបទផ្កាញ់មារ ទាំង ២ សង្កាត់នេះជាពាក្យកាព្យសំរាយ. ពុទ្ធបរិស័ទច្រើនតែនិមន្តសាមណេរតូចៗ ២ រូបមានសំលេងពីរោះដែលចេះសូត្របទទាំង ២ បែបនេះ អោយសូត្រតាំងពីដើមរហូតដល់ចប់។ បើរកសាមណេរប្រភេទនោះពុំបានទេ. គេអញ្ជើញបុរសគ្រហស្ថ ២ នាក់ មានសំលេងពីរោះដែលធ្លាប់សូត្របទនោះ អោយសូត្រក៏បាន តាមគួរដល់ការលៃលក។ ចំពោះត្រង់បទផ្កាញ់មារ. បើមានមធុបាយាសដែលត្រូវថ្វាយព្រះ. កាលបើដល់ពេលអរុណបញ្ចេញរស្មីភ្លឺស្រាងៗ. គេអោយសូត្រត្រង់ឃ្លាពាក្យកាព្យថា " អណ្ដាប់នោះណា នាងស្រីសុជាតា ថ្វាយមធុបាយាស សឹងគ្រឿងទិព្វគន់ ពេញទាំងភាជន៍មាស ទើបនាងអង្គាស ថ្វាយព្រះ ទសពល " ។ សូត្រ ៣ ដងដដែលៗ ។ គេថ្វាយមធុបាយាសគំនាលនឹងវេលាកំពុងសូត្រនេះ។ ( តាមលំអានរឿង. គួរថ្វាយមធុបាយាសពីព្រលឹម. លុះដល់ពេលយប់សឹម ធ្វើពិធីអភិសេក ) ។



www.elibraryofcambodia.org

**បទក្ខិណោ** រួចសូត្រ **តេ អត្ថលទ្ធា សុខិតា ឧបេខ សហ សព្វេហិ ញាតិភិ ១** បន្ទាប់ពីនេះ ជូនកាលក៏សូត្រ **ភវតុ សព្វមង្គលំ ឧបេខ សព្វសង្ឃានុភាវេន សទា សោត្ថី ភវន្តុ តេ ១**

**សង្កាត់ទី៨-** ពុទ្ធបរិស័ទបាច- សាចផ្កាស្រស់ៗ មានផ្កាម្លិះជាដើមទៅលើព្រះពុទ្ធរូបអង្គថ្មី , អ្នកខ្លះមានសុគន្ធវារី ក៏ជជុះរលាស់ទឹកក្រអូបនោះថ្វាយព្រះពុទ្ធរូបអង្គថ្មីដោយស្ងៀមៗ ឥត បញ្ចេញវាចាថាអ្វី , ជូនកាលកំពុងធ្វើពិធីនេះ អាចារ្យម្នាក់បញ្ចេញវាចាលឺខ្លាំងៗ អោយពុទ្ធបរិស័ទថាតាមទាំងអស់គ្នាថា **ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ ! មារមានបាបចាញ់ព្រះអង្គហើយ !** ( ថា ៣ ដង ) ។

**សង្កាត់ទី៩-** លុះចប់ពិធីនេះហើយ , ពុទ្ធបរិស័ទជាឧបាសក ឧបាសិកាទាំងអស់គ្នា សូត្រធមិនមស្សការព្រះរតនត្រ័យ តាមទំលាប់ដែលតែងតែសូត្ររៀងមក , រួចហើយសូត្រធមិ ឧទ្ទិសកុសលផលបុណ្យតាមទំលាប់ដូចសព្វដង ។ ក៏ សន្មត់ថាចប់ពិធីពុទ្ធាភិសេកមធ្យមត្រឹមប៉ុននេះ ។

**ពិធីពុទ្ធាភិសេកសង្ខេប-** ជាពិធីខ្លី ១ ខ្ញុំរៀបរៀងពិធីខ្លីនេះ ទុកជារបៀបអោយពុទ្ធបរិស័ទអ្នកត្រូវការធ្វើពិធីពុទ្ធាភិសេកសង្ខេប ។ ពិធីសង្ខេបនេះមានត្រឹមតែ ការរៀបតាក់តែងគ្រឿងសក្ការបូជាដោយផ្កាស្រស់ៗ និងទៀនធូបថ្វាយព្រះពុទ្ធរូបអង្គថ្មីប៉ុននោះ- រួចហើយត្រូវនិមន្តព្រះធម្មកថិកសំដែងរឿង **បឋមត្រាស់** តាមគួរដល់វេលា រឺមិនបាច់មានទេសនាបឋមត្រាស់ក៏បាន , មិនបាច់មានការសូត្របាលី **ពុទ្ធាភិសេក** ក៏បាន , ត្រូវនិមន្តព្រះភិក្ខុសង្ឃ ៤ អង្គ រឺច្រើនអង្គជាងនេះ សុំអោយលោកស្វាធ្យាយបាលីតាមលំដាប់ទៅ ។ នៅទីចប់បាលីទាំងអស់ មានប្រែជាសំរាយរាយសេចក្តីតាមលំអានបាលី សំរាប់អោយ


www.elibraryofcambodia.org

ដឹងដំនើររឿងនៃអភិសម្ពោធិក្នុងពិធីពុទ្ធាភិសេកសង្ខេបប៉ុននោះ ។ ព្រះភិក្ខុសង្ឃត្រូវការសូត្រសំរាយនោះផងក៏បាន មិនបាច់សូត្រក៏បាន ព្រោះសំរាយនៅខាងចុងដោយឡែកទេ ។ ( ត្រូវមើលលេខរៀងតាមលំដាប់ ) ។

ព្រះភិក្ខុសង្ឃត្រូវស្វាធ្យាយថា ÷

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស[១] ៚

តស្មឹ សមយេ ពោធិសត្តោ ពោធិរុក្ខក្ខន្ធំ បិដ្ឋិតោ កត្វា បុរត្ថាភិមុខោ ទឡ្ហមានសោ ហុត្វា

កាមំ តចោ នហារុ ច អដ្ឋិ ច អវសិស្សតុ

សព្វំបិ ហិទំ សរីរេ មំសលោហិតំ ឧបសុស្សតុ នេវ សម្មាសម្ពោធឹ អប្បត្វា ឥមំ បល្លង្កំ ន ភិន្ទិស្សាមីតិ អសនិសតសន្និបាតេនាបិ អភេជ្ជរូបំ អបរាជិតំ បល្លង្កំ អាភុជិត្វា និសីទិ[២] ៚

តតោ មហាបុរិសោ អនុលោមប្បដិលោមំ បដិច្ចសមុប្បាទំ មនសាកាសិ :

អវិជ្ជាបច្ចយា សង្ខារា , សង្ខារប្បច្ចយា វិញ្ញាណំ , វិញ្ញាណប្បច្ចយា នាមរូបំ , នាមរូបប្បច្ចយា សឡាយតនំ , សឡាយតនប្បច្ចយា ផស្សោ , ផស្សប្បច្ចយា វេទនា , វេទនាបច្ចយា តណ្ហា , តណ្ហាបច្ចយា ឧបាទានំ , ឧបាទានប្បច្ចយា ភវោ , ភវប្បច្ចយា ជាតិ , ជាតិប្បច្ចយា


www.elibraryofcambodia.org

ជរាមរណំ , សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ [៣] ។

អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ , សង្ខារនិរោធា វិញ្ញាណនិរោធោ , វិញ្ញាណនិរោធា នាមរូបនិរោធោ , នាមរូបនិរោធា សឡាយតននិរោធោ , សឡាយតននិរោធា ផស្សនិរោធោ , ផស្សនិរោធា វេទនានិរោធោ , វេទនានិរោធា តណ្ហានិរោធោ , តណ្ហានិរោធា ឧបាទាននិរោធោ , ឧបាទាននិរោធា ភវនិរោធោ , ភវនិរោធា ជាតិនិរោធោ , ជាតិនិរោធា ជរាមរណំ , សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ [៤] ។

មហាបុរិសោ ឯតមត្ថំ វិទិត្វា តទន្តរេ យថាក្កមំ តយោ វារេ ឧទានានិ ឧទានេសិ :

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មន្តិ [៥] ។

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា


www.elibraryofcambodia.org

យតោ ខយំ បច្ចយានំ អវេទីតិ [៦] ។
យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
វិធូបយំ តិដ្ឋតិ មារសេនំ
សុរិយោវ ឱភាសយមន្តលិក្ខន្តិ [៧] ។

តតោ មហាបុរិសោ បូរិតបារមីនំ ពោធិសត្តានំ អភិសម្ពុជ្ឈនទិវសេ បល្លង្កោ មយ្ហំ បាបុណាតីតិ វត្វា ឋិតំ មារំ អាហ មារ តុយ្ហំ ទានស្ស ទិន្នភាវេ កោ សក្ខីតិ [៨] ។ មារោ ឥមេ ឯត្តកា សក្ខិនោតិ មារគណាភិមុខំ ហត្ថំ បសារេសិ [៩] ។ តស្មឹ ខណេ មារបរិសាយ អហំ សក្ខី អហំ សក្ខីតិ បវត្តសទ្ទោ បឋវីឧទ្រីយនសទ្ទសទិសោ អហោសិ [១០] ។ អថ មារោ មហាបុរិសំ អាហ សិទ្ធត្ថ តុយ្ហំ ទានស្ស ទិន្នភាវេ កោ សក្ខីតិ [១១] ។ មហាបុរិសោ តុយ្ហំ តាវ ទានស្ស ទិន្នភាវេ សចេតនា សក្ខិនោ មយ្ហំ បន ឥមស្មឹ ឋានេ សចេតនោ កោចិ សក្ខី នាម នត្ថិ តិដ្ឋតុ តាវ មេ អវសេសត្តភាវេសុ ទិន្នទានំ វេស្សន្តរត្តភាវេ បន ឋត្វា សត្តសតកមហាទានស្ស តាវ ទិន្នភាវេ អយំ អចេតនាបិ មហាបឋវី សក្ខីតិ ចីវរគព្ភន្តរតោ ទក្ខិណហត្ថំ អភិនីហរិត្វា វេស្សន្តរត្តភាវេ ឋត្វា មយ្ហំ សត្តសតកមហាទានស្ស ទិន្នភាវេ ត្វំ សក្ខី ន សក្ខីតិ មហាបឋវ្យាភិមុខំ ហត្ថំ បសារេសិ [១២] ។ មហាបឋវី អហន្តេ



www.elibraryofcambodia.org

តទា សក្ទីតិ វិរាវសតេន វិរាវសហស្សេន មារពលំ អវត្ថរមានា វិយ ឧន្នាទិនី អហោសិ (១៣) ។ តតោ មហាបថវី ទិន្នន្តេ សិទ្ធត្ថ មហាទានំ ឧត្តមទានន្តិ (១៤) ។ វេស្សន្តរត្តភាវេន ទិន្នទានំ សម្មសន្តេ សម្មសន្តេ ទិយឌ្ឍយោជនសតិកោ គិរិមេខលហត្ថី ជន្នុកេហិ បតិដ្ឋាសិ (១៥) ។ មារបរិសា ទិសាវិទិសា បលាយិ (១៦) ។ ទ្វេ ឯកមគ្គេន គតា នាម នត្ថិ (១៧) ។ សីសាភរណានិ ចេវ និវត្ថវសនានិ ច បហាយ សម្មុខសម្មុខា ទិសាហិយេវ បលាយឹសុ (១៨) ។ តតោ ទេវសង្ឃា បលាយមានំ មារពលំ ទិស្វា មារស្ស បរាជយោ ជាតោ សិទ្ធត្ថមហាបុរិសស្ស ជយោ ជយបូជំ ករិស្សាមាតិ នាគា នាគានំ សុបណ្ណា សុបណ្ណានំ ទេវតា ទេវតានំ ព្រហ្មានោ ព្រហ្មានំ ឧគ្ឃោសេត្វា វិជ្ជាធរា គន្ធមាលាទិហត្ថា មហាបុរិសស្ស សន្តិកំ ពោធិបល្លង្កំ អាគមឹសុ (១៩) ។

តច្ចេវំ បន វេទិតព្វំ :

"ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !
មារស្ស ច បាបិមតោ បរាជយោ !"
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា នាគគណា មហេសិនោ ។
"ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !


www.elibraryofcambodia.org

មារស្ស ច បាបិមតោ បរាជយោ !"

ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា

សុបណ្ណសង្ឃាបិ ជយំ មហេសិនោ ។

"ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !

មារស្ស ច បាបិមតោ បរាជយោ !"

ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា

ជយំ តទា ទេវគណា មហេសិនោ ។

"ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !

មារស្ស ច បាបិមតោ បរាជយោ !"

ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា

ជយំ តទា ព្រហ្មគណាបិ តាទិនោ [២០] ។

មហាបុរិសោ បន ទសសហស្សិលោកធាតុំ ឧន្នាទេន្តោ អរុណុគ្គមនវេលាយ សព្វញ្ញុតញ្ញាណំ បដិវិជ្ឈិ [២១] ។ ឯវំ អបរិមាណេន សិរីវិភវេន បូជិយមានោ នានប្បការេសុ អច្ឆរិយធម្មេសុ បាតុភូតេសុ សព្វញ្ញុតំ បដិវិជ្ឈិត្វា សព្វពុទ្ធានំ អវិជ្ជហិតំ ឧទានំ ឧទានេសិ [២២] :

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ

គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ

គហការក ទិដ្ឋោសិ បុនគេហំ ន កាហសិ

សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ



www.elibraryofcambodia.org

**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ** (២៣) ៗ

## ប្រែជាសំរាយ

តាមលំដាប់ **នយលក្ខណៈ** លេខយោងតាំងពីលេខ ១ រៀងដល់លេខ ២៣ តទៅនេះ :

**១.** សូមនមស្សការ ចំពោះព្រះភគវ័ត គឺព្រះមានបុណ្យ មានសិរីជោគជ័យ ជាព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

**២.** ក្នុងសម័យនោះ ព្រះ ពោធិសត្វទ្រង់បែរព្រះប្រឹស្ដាង្គ គឺខ្នងព្រះអង្គទៅរកដើមពោធិព្រឹក្ស ឆ្ពោះព្រះភក្ត្រទៅខាងទិសបូពា ទ្រង់តាំងព្រះហឫទ័យយ៉ាងម៉ឺងម៉ាត់ថា " ស្បែកក្ដី សរសៃក្ដី ឆ្អឹងក្ដី (បើត្រូវស្ងួតក្រៀម) ក៏ចូរស្ងួតក្រៀមចុះ . ទោះសាច់និងឈាម ទាំងអស់ក្នុងសរីរៈរាងកាយនេះក៏ដោយ (បើត្រូវរីងស្ងួត ) ក៏ចូររីងស្ងួតទៅចុះ , បើអាត្មាអញពុំបានដល់នូវសម្មាសម្ពោធិក្នុងទីនេះទេ , អាត្មាអញនឹងមិនរំលាយ រំសាយភ្នែននេះឡើយ " - ហើយព្រះអង្គពែននូវអបរាជិតបល្ល័ង្ក គឺព្រះភ្នែន មានជ័យ មានសភាពនឹងធឹងដែលរន្ទះណាមួយឬវត្ថុអ្វីមួយនឹងទំលាយពុំបាន , ទ្រង់ គង់យ៉ាងនឹងធឹងឥតកំរើក . ប្រសិនបើរន្ទះទាំងរយបាញ់ប្រជុំគ្នាមក ក៏ព្រះអង្គ ឥតស្ញើបរំភើបឡើយ ។

**៣.** លំដាប់នោះ ព្រះមហាបុរស ទ្រង់រំពឹងពិចារណានូវបដិច្ចសមុប្បាទជាអនុលោមនិងបដិលោមថា សង្ខារទាំងឡាយកើតមានព្រោះអវិជ្ជា គឺមោហៈងងឹតល្ងង់ជាបច្ច័យអោយកើត , វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យអោយកើត , នាមធម៌និងរូបធម៌កើតមាន ព្រោះវិញ្ញាណ ជាបច្ច័យអោយកើត , អាយតនៈ ៦ កើតមាន ព្រោះនាមធម៌និងរូបធម៌ ជាបច្ច័យអោយកើត ,



www.elibraryofcambodia.org

ផស្សៈកើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ អោយកើត , វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យអោយកើត , តណ្ហាកើតមានព្រោះវេទនាជាបច្ច័យអោយកើត . ឧបាទានកើតមាន ព្រោះតណ្ហាជា បច្ច័យអោយកើត , ភពកើតមាន ព្រោះឧបាទានជាបច្ច័យអោយកើត , ជាតិ គឺ កំណើតកើតមានព្រោះភពជាបច្ច័យអោយកើត , ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យអោយកើត . (កាលបើបដិច្ចសមុប្បាទជាសម្ភវធម៌ទាំង១២នេះនៅមាន ) , សេចក្តីសោកស្តាយ អាល័យ - ការយំខ្សឹកខ្សួល - សេចក្តីលំបាកកាយ - ទោមនស្សតូចចិត្ត និងឧបាយាសៈ គឺសេចក្តីចង្អៀតតានតឹងចិត្ត ក៏តែងតែកើតមានឡើងផងដែរ។ ការកើតឡើងនៃកងទុក្ខទាំងអស់នេះចេះតែមាន ( ព្រោះមានធម៌ជាបច្ច័យទាក់ទងគ្នានាំអោយកើតមាន) យ៉ាងនេះឯង ( ពុំមែនដទៃក្រៅពីនេះឡើយ ) ។

៤. កាលបើអវិជ្ជារលត់សូន្យ ជាវិរាគធម៌ ឥតសេសសល់ហើយ សង្ខារក៏រលត់ , សង្ខាររលត់ វិញ្ញាណក៏រលត់ , វិញ្ញាណរលត់ នាមធម៌និងរូបធម៌ក៏រលត់ , នាមធម៌និងរូបធម៌រលត់ អាយតនៈ ៦ ក៏រលត់ , អាយតនៈ ៦ រលត់ ផស្សៈក៏រលត់ , ផស្សៈរលត់ វេទនាក៏រលត់ , វេទនារលត់ តណ្ហាក៏រលត់ , តណ្ហារលត់ ឧបាទានក៏រលត់ , ឧបាទានរលត់ ភពក៏រលត់ , ភពរលត់ ជាតិក៏រលត់ , ជាតិរលត់ ជរានិងមរណៈក៏រលត់ , ( កាលបើបដិច្ចសមុប្បាទទាំង ១២ នោះជានិរោធធម៌រលត់អស់ហើយ), សេចក្តីសោកស្តាយអាស័យ-ការយំខ្សឹក-ខ្សួល-សេចក្តីលំបាកកាយ - ទោមនស្សតូចចិត្ត និងឧបាយាសៈ គឺសេចក្តីចង្អៀតតានតឹងចិត្តក៏រលត់ផងដែរ។ ការរលត់នៃកង ទុក្ខទាំងអស់នេះមាន ( ត១គ្នាព្រោះអស់មានធម៌ជាបច្ច័យនាំអោយកើតតទៅទៀត ) យ៉ាងនេះឯង ( ពុំមែនដទៃក្រៅពីនេះឡើយ ) ។


www.elibraryofcambodia.org

៥. ព្រះមហាបុរស ទ្រង់ជ្រាបនូវបដិច្ចសមុប្បាទនោះហើយ ព្រះអង្គបន្លឺនូវព្រះឧទានវាចាទាំងឡាយ អស់វារៈ ៣ ដងផង តាមលំដាប់មុនក្រោយក្នុងចន្លោះ ៧ នៃការរំពឹងពិចារណា នូវបដិច្ចសមុប្បាទនោះថា កាលណាបើពោធិ-បក្ខិយធម៌ និងចតុរារិយសច្ចធម៌ទាំងឡាយ កើតមានប្រាកដ ដល់ខីណាសវ-ព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសអោយក្តៅសព្វ អ្នកដុតបំផ្លាញកិលេស , កាលនោះឯង សេចក្តីសង្ស័យទាំងអស់នៃខីណាសវព្រាហ្មណ៍នោះក៏បាត់សូន្យអស់ទៅ ព្រោះខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់នូវធម៌ទាំងហេតុគឺចតុរារិយសច្ចធម៌ មានទុក្ខសច្ចជាដើម ។

៦. កាលណាបើពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ ទាំងឡាយកើតមានប្រាកដ ដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសអោយក្តៅសព្វ អ្នកដុតបំផ្លាញកិលេស , កាលនោះឯង សេចក្តីសង្ស័យទាំងអស់នៃខីណាសវព្រាហ្មណ៍នោះ ក៏បាត់សូន្យអស់ទៅ ព្រោះខីណាសវព្រាហ្មណ៍នោះបានដឹងនូវការអស់នៃធម៌ជាបច្ច័យទាំងឡាយ ។

៧. កាលណាបើពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ទាំងឡាយ កើតមានប្រាកដ ដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសអោយក្តៅសព្វ អ្នកដុតបំផ្លាញកិលេស . ( កាលនោះឯង ខីណាសវព្រាហ្មណ៍នោះ ) កម្ចាត់បង់នូវមារ និងសេនាមារបាន ( ក៏ភ្លឺស្វាង ) ដូចជាព្រះអាទិត្យញុំាងអាកាសអោយភ្លឺច្បាស់ ដូចនោះឯង ។

**(យទា ហវេ** ទាំង ៣ គាថានេះជាព្រះឧទានវាចានៃមហាបុរស ។ ក្នុងគម្ពីរមានប្រាប់សេចក្តីថា ព្រះមហាបុរសទ្រង់បន្លឺព្រះឧទានវាចានេះ ក្នុងចន្លោះ និងចន្លោះនៃការពិចារណាបដិច្ចសមុប្បាទធម៌ ជាអនុលោមបដិលោម


www.elibraryofcambodia.org

សាចុះសាឡើងច្រើនដងច្រើនសា ។ ដោយហេតុនេះ បើពុទ្ធបរិស័ទអ្នកធ្វើពិធីពុទ្ធាភិសេកសង្ខេប មិនគិតពីពេលវែងខ្លីទេ , គួរនិមន្តព្រះភិក្ខុសង្ឃ សុំអោយលោកស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌ ១ ចប់ រួចស្វាធ្យាយបាលីគាថា **យទា ហវេ បាតុភវន្តិ ធម្មា ។បេ។ យតោ បជានាតិ សហេតុធម្មំ ។** រួចស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌ ១ ចប់ទៀត , ហើយស្វាធ្យាយ **យទា ហវេ បាតុភវន្តិ ធម្មា ។បេ។ យតោ ខយំ បច្ចយានំ អវេទិ ។** រួចស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌ ១ ចប់ទៀត , ហើយស្វាធ្យាយ **យទា ហវេ បាតុភវន្តិ ធម្មា ។បេ។ សូរិយោវ ឱភាសយមន្តលិក្ខំ ។** បើស្វាធ្យាយតាមន័យនេះ ឃើញថា ស្វាធ្យាយបាលីបដិច្ចសមុប្បាទ ៣ ចប់ **យទា ហវេ** ក៏ ៣ ចប់ដែរ គឺស្វាធ្យាយឆ្លាស់គ្នាក្នុងចន្លោះៗ ) ។

**៨.** គ្រានោះ ព្រះមហាបុរសទ្រង់មានព្រះបន្ទូលថា " បល្ល័ង្ក ( ដែលកើតឡើង ) ក្នុងថ្ងៃនៃការត្រាស់ដឹងនៃពោធិសត្វទាំងឡាយ ដែលបានបំពេញបារមីហើយ ត្រូវបានមកអរញ " . ហើយព្រះអង្គមានព្រះបន្ទូលទៅរកទេវបុត្រមារដែលឋិតនៅ ( ក្នុងទីនោះ ) ថា " នែមារ , អ្នកណាជាសាក្សីក្នុងភាវៈនៃទានដែលអ្នកឯងបានអោយហើយ ?" ។

**៩.** ទេវបុត្រមារលាដៃចង្អុលអាងទៅ រកពពួករេហ៍ពលថា " ពពួករេហ៍ពលទាំងអម្បាលនេះសុទ្ធតែជាសាក្សី " ។

**១០.** ខណៈនោះ សូរស័ព្ទសំដីនៃមារបរិស័ទ ក៏លាន់លឺកងរំពងរញ៉ូឡើងថា " ខ្ញុំជាសាក្សី ! ខ្ញុំជាសាក្សី ! " សូរស័ព្ទនោះហាក់ដូចជាស្ទួរស្រុតចុះនៃមហាប្រឹថពី ។


www.elibraryofcambodia.org

**១១.** លំដាប់នោះទេវបុត្រមារសួរព្រះមហាបុរសថា " នែ សិទ្ធត្ថ , អ្នកណាជាសាក្សីក្នុងភាវៈ នៃទានដែលអ្នកឯងបានអោយហើយ ?"

**១២.** ព្រះមហាបុរសទ្រង់ឆ្លើយថា " អ្នកឯងមានសាក្សីដែលមាន ចេតនាក្នុងភាវៈនៃទានដែលអ្នកឯងបានអោយហើយ , ចំនែកខាងអញ , ក្នុង ទីនេះ , ឥតមានអ្នកណាមួយដែលមានចេតនា ជាសាក្សីអញទេ , ទានដែលអញអោយហើយ ក្នុងអត្តភាពដ៏ពិសេសទាំងឡាយ ចូរលើកទុកចុះ (កុំបាច់យកមកនិយាយរាងឡើយ) , និយាយតែត្រឹម **សត្តសតកមហាទាន** ដែលកាលអញឋិតនៅក្នុងអត្តភាព ជាស្តេចវេស្សន្តរប៉ុននោះក៏បានហើយ , មហាប្រឹថពីដែលគ្មានចេតនានេះជាសាក្សីរបស់អញ " - លុះព្រះអង្គឆ្លើយតបយ៉ាងនេះហើយ , ទ្រង់បញ្ចេញព្រះហស្តខាងស្តាំពីក្នុងចន្លោះផ្ទៃនៃចីពរ ( ដែលព្រះអង្គឃុំស្រេចស្រាប់ពីនាយមក ), ទ្រង់សំយុងព្រះហស្តចង្អុលឆ្ពោះទៅរកមហាប្រឹថពី ដោយបញ្ជាក់ការណ៍ថា " កាលដែលអញឯងឋិតនៅក្នុងអត្តភាពជាស្តេចវេស្សន្តរ អញ បានអោយ សត្តសតកមហាទាន តើមហាប្រឹថពីឯងជាសាក្សីមែនរឺទេ ?" ។

**១៣.** ស្រាប់តែមហាប្រឹថពីបញ្ចេញសូរស័ព្ទលាន់លឺខ្ទរខ្ទាំង ហាក់ដូចជាសន្ទាប់ គំរាមរេហ៍ពលមារ ដោយសូរសំរែកសន្ទាប់រាប់រយរាប់ពាន់ឡើងថា " ក្នុងកាលនោះខ្ញុំម្ចាស់ជាសាក្សីរបស់ព្រះអង្គ !" ។

(មហាប្រឹថពីនេះ បញ្ចេញសូរស័ព្ទដោយសំដែងអាការជាស្រី , ដោយហេតុនេះឯង បានជាពោរាណាចារ្យហៅមហាប្រឹថពី ដែលមានសភាពជាមហាស្ចារ្យក្នុងគ្រាឆ្លើយអាងជាសាក្សីនៃព្រះមហាបុរសនោះថា " នាងធរណី ", អ្នកខ្លះហៅតាមទំលាប់តៗគ្នាមកថា " នាងគង្ហីងព្រះធរណី ") ។



www.elibraryofcambodia.org

**១៤.** មិនត្រឹមតែបញ្ចេញសំអាងជាសាក្សីប៉ុននោះឡើយ មហាប្រឹថពីថែមទាំងឆ្លើយឡើងទៀតថា " បពិត្រព្រះសិទ្ធត្ថ , មហាទានដែលព្រះអង្គបានអោយហើយ ជា ទានដ៏ឧត្តម " ។

**១៥.** កាលដែលព្រះមហាបុរស ទ្រង់ពិចារណាហើយពិចារណាទៀតជារឿយៗ នូវទានដែលកាលព្រះអង្គជាស្តេចវេស្សន្តរទ្រង់បានអោយហើយ (ជាមហាទានដ៏ឧត្តមនោះ), ក៏ស្រាប់តែដំរីឈ្មោះ **គិរិមេខលៈ** មានកំពស់ ១៥០យោជន៏ ( ជាជំនិះទេវបុត្តមារនោះ) ស្ទុតលុតជង្គងស្រុប ។

**១៦.** មារបរិស័ទ គឺពួករេហ៍ពលរបស់ទេវបុត្តកុមារ ក៏រត់ប្រសាចទៅតាមទិសទីទៃៗ ។

**១៧.** ពីរនាក់រត់ទៅតាមផ្លូវជាមួយគ្នា ពុំមានសោះឡើយ គឺរត់ទៅតាមផ្លូវដោយខ្លួនៗពីគ្នា ។

**១៨.** រេហ៍ពលមារទាំងនោះ បោះបង់គ្រឿងប្រដាប់ដែលពាក់នៅក្បាល និងគ្រឿងស្លៀកពាក់រត់ប្រសាច ទៅតាមទិសទីទាំងឡាយដែរចំមុខៗរៀងរាល់ខ្លួន ។

**១៩.** លំដាប់នោះ ពួកទេពតា ទាំងឡាយ បានឃើញរេហ៍ពលមារកំពុងរត់ប្រសាចរប៉ាត់រប៉ាយ ដូចនោះ ក៏ដឹងច្បាស់ថា " បរាជ័យបានទៅទេវបុត្តមារ , ជ័យជំនះបានមកព្រះសិទ្ធត្ថមហាបុរសហើយ , ពួកយើងនឹងទៅធ្វើជយបូជាចំពោះព្រះអង្គ " ក៏បញ្ចេញឧក្ឃោសនាការលឺខ្លាំងៗកងរំពងឡើង , គឺពួកនាគស្រែកប្រាប់នាគផងគ្នា , ពួកគ្រុឌស្រែក ប្រាប់គ្រុឌផងគ្នា , ពួកទេពតាស្រែកប្រាប់ទេពតាផងគ្នា , ពួកព្រហ្មស្រែក ប្រាប់ព្រហ្មផងគ្នា , ពួកពិទ្យាធរស្រែកប្រាប់ពិទ្យាធរផងគ្នា សុទ្ធសឹងតែមានហត្ថាកាន់គ្រឿងបូជាមានគន្ធមាលា


www.elibraryofcambodia.org

ជាដើម មូលគ្នាមកកាន់ពោធិបល្ល័ង្កជិតជុំវិញមហាបុរស ។

**២០.** ពួកពុទ្ធបរិស័ទជ្រាបថា នៅពេលដែលទេវនិកាយ មូលមកស្រែកទ្រហឹងអឺងកង ថ្វាយពរថ្វាយជ័យបូជា ចំពោះព្រះមហាបុរសនោះ ព្រះអដ្ឋកថាចារ្យលោកចងក្រងបាលី ៤ គាថានេះសំរាប់ស្វាធ្យាយក្នុងពិធីពុទ្ធាភិសេក រំលឹកដល់រឿងដែលព្រះមហាបុរស បានសំរេចអនុត្តរសម្មាសម្ពោធិ ។ ខ្ញុំប្រែចំពោះតែត្រង់ជយឃោសថា **ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ ! មារស្ស ច បាបិមតោ បរាជយោ !** "ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ ! មារមានបាបចាញ់ព្រះអង្គហើយ !" - ខ្ញុំប្រែតែត្រឹមប៉ុននេះសំរាប់អោយ ពុទ្ធបរិស័ទបន្លឺជ័យឃោសនេះ ថ្វាយសាធុការពរចំពោះព្រះពុទ្ធរូបអង្គថ្មី ក្នុងពិធីពុទ្ធាភិសេក ។

**២១.** ឯព្រះមហាបុរសទ្រង់ ញុំាងលោកធាតុទាំង ១ម៉ឺន អោយកំរើករំពើកហើយ , លុះវេលាអរុណនៃថ្ងៃ ១ រោច ខែ ពិសាខជិតរះ , ព្រះអង្គក៏បានត្រាស់ដឹងនូវព្រះសព្វញ្ញុតញ្ញាណ ។

**២២.** ព្រះសព្វញ្ញុពុទ្ធ , កាលដែលទេវនិកាយថ្វាយជយឃោស និងគ្រឿងបូជា ដោយសិរីវិភព គឺសម្បត្តិសិរីប្រមាណពុំបានយ៉ាងនេះ , កាលដែលអច្ឆរិយធម៌ទាំងឡាយមានប្រការផ្សេងៗ កើតមានប្រាកដឡើង ហើយ , ព្រះអង្គក៏បានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ , ហើយទ្រង់បន្លឺនូវ ព្រះឧទានវាចាដែលព្រះពុទ្ធគ្រប់ព្រះអង្គ (ទើបបានត្រាស់ភ្លាមៗ) ទ្រង់ ពុំដែលបោះបង់គឺព្រះអង្គពុំដែលខានបន្លឺសោះឡើយ ។

**២៣.** (ព្រះបន្លឺព្រះវាចាលឺខ្លាំងៗ ដោយសោមនស្សចំពោះសព្វញ្ញុតញ្ញាណ , ប្រាស្រ័យទៅរកតណ្ហាជាអរូបធម៌ ហាក់ដូចជាគេនិយាយទៅរក



www.elibraryofcambodia.org

មនុស្សផងគ្នា។ ខ្ញុំប្រែសំរួលសេចក្ដីអោយពុទ្ធបរិស័ទ អ្នកមិនចេះប្រែបាលី ងាយស្ដាប់ងាយយល់)។ ព្រះអង្គបន្លឺថា " នែ តណ្ហា ! អ្នកឯងជាមេជាង សាងសង់រូបរាងសពាង្គកាយអញតថាគត ដូចជាមេជាងដែលសង់ផ្ទះជាលំនៅ ទូទៅដូចនេះដែរ . អញតថាគតអន្ទោលកើតស្លាប់ ស្លាប់កើតក្នុងវាលវដ្ដសង្សារ ជាអនេកជាតិរាប់មិនអស់ ពីព្រោះតែតណ្ហាឯងហ្នឹងជាអ្នកសាងសង់ . អញតថាគតខំប្រឹងស្វះស្វែងរកអោយជួបនឹងជាងផ្ទះឯងនេះ អស់កាលយូរអង្វែងណាស់ហើយតើ ! ចេះតែឃ្លាង មិនជួបប្រទះអ្នកឯង ហ្នឹងសោះ (ព្រោះអ្នកឯងប៉ិនគេចវេះ ប៉ិនលាក់មុខ លាក់ខ្លួនណាស់ !) , (នែជាតិ !) , ជាតិឯងនេះ (ជាសំនង់របស់តណ្ហា) ចេះតែនាំយកទុក្ខព្រួយលំបាកមកផ្ដុករឿយៗ អោយអញតថាគត , នែជាងផ្ទះ ! (ឥឡូវ) អញតថាគតបានជួបប្រទះឃើញអ្នកឯងហើយ , អ្នកឯងនឹងសង់ផ្ទះទៀតលែងកើតហើយ. ឆ្អឹងជំនីរទាំងអស់ (ដែលទុកដូចជាគ្រឿងទព្វសំភារៈសំរាប់សង់ផ្ទះ) របស់អ្នកឯង អញតថាគតបានរុះរើបំបាក់ខ្ទេចខ្ទីអស់ហើយ , កំពូលផ្ទះ (របស់អ្នកឯង) អញតថាគតបានរុះរើបោះគ្រវែងចោលខ្ទេចខ្ទីល្អិតល្អន់អស់ហើយ , ចិត្ត (អញតថាគត) បានឡើងដល់ថ្នាក់វិសង្ខារ រួចផុតស្រលះចាកសំនង់ថ្មី ទៀត (របស់ជាងផ្ទះឯង) ហើយ , ចិត្តអញតថាគតបានដល់នូវតណ្ហាក្ស័យ ឈប់លែងចូលដៃសមគំនិត ស៊ុមគ្រលុំ ងងឹតងងល់ ជាមួយនឹងជាងផ្ទះឯងហ្នឹង តទៅទៀតហើយ !" ។


www.elibraryofcambodia.org

លុះព្រះភិក្ខុសង្ឃស្វាធ្យាយបាលីឧទានគាថានេះចប់ហើយ . លោកអាចារ្យ គ្របាស្ដម្នាក់សូត្រអោយអ្នកទាំងអស់ថាតាមព្រមៗគ្នាថា :

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ ! "ព្រះពុទ្ធមានសិរីច្រេះ ពស្នះហើយ " , មារស្ស ច បាបិមតោ បរាជយោ ! មារមានបាបចាញ់ព្រះអង្គហើយ !** " ។ សូត្រអោយថាតាមព្រមៗគ្នាបីដង។ សូត្របណ្ដើរ បាចសាច គន្ធបូជាបណ្ដើរ។ បន្ទាប់មក ពុទ្ធបរិស័ទសូត្រធម៌ នមស្សការព្រះរតនត្រ័យ ដូច ទំលាប់សព្វដង។ សន្មតថាចប់ពិធីពុទ្ធាភិសេក សង្ខេបត្រឹមតែប៉ុននេះ ។


www.elibraryofcambodia.org

# ពិធីចំអិននឹងការថ្វាយមធុបាយាស

បើពុទ្ធបរិស័ទត្រូវការធ្វើពិធីពុទ្ធាភិសេកពិស្តារ ជាពិសេសប្លែកពីពិធីដែលធ្លាប់ធ្វើរៀងមកនោះ ត្រូវធ្វើអស់រយៈកាល **បីថ្ងៃ** គឺថ្ងៃ ១៤ កើត ១៥ កើត និង ថ្ងៃ ១រោចនៃខែពិសាខ តាមតែក្នុងឆ្នាំណាក៏ដោយ ។

នៅវេលារសៀលនៃថ្ងៃ ១៤ កើត ត្រូវរៀបចំគ្រឿងពុទ្ធបូជាចំពោះព្រះពុទ្ធរូបអង្គថ្មី , ត្រូវធ្វើព្រះរាជវ័តិខ្នាតតូច ២ ម៉ែត្រ ៤ ជ្រុងស្មើ នៅលើទីដីដ៏ស្អាត មិនឆ្ងាយប៉ុន្មានពីទីតាំកល់ព្រះពុទ្ធរូបអង្គថ្មីនោះ , ដោយមានទង់ និងឆត្ររូត ដែលធ្វើដោយក្រដាសពណ៌ផ្សេងៗ ដោតដង្ហែរ ជុំវិញព្រះរាជវ័តិនោះ , មានចង្ក្រានចំកណ្តាលព្រះរាជវ័តិ និងខ្ទះស្ពាន់ រឺខ្ទះដែកជំទើរមួយ ហើយនិងធ្យូងសំរាប់ដុតចំអិនមធុបាយាស កុំអោយមានផ្សែងដូចដុតអុស ។ នៅវេលាយប់ ១៤ កើតនោះ , ចាប់តាំងពីម៉ោង ២០ ទៅដល់ម៉ោង ៣ , ស្ត្រីចាស់ក្មេងច្រើននាក់ នាំគ្នាបកគ្រាប់ស្រូវដំនើបអោយបានជាអង្ករ កុំអោយមានបាក់សូមបីតែ ១គ្រាប់ អោយបានចំនួនល្មមដល់ការចំអិនមធុបាយាសគោក , ប្រសិនបើពូតជាពំនូតៗ ល្មមពមកើត អោយបានចំនួន ៤៩ ពំនូត ។ លុះដល់វេលាម៉ោង ៤ នៃយប់ ១៤ កើតនោះ , ស្ត្រីទាំងអស់នាំគ្នាផ្សំគ្រឿង ដោយមានទឹកដោះគោកំប៉ុង , ស្ករក្រាម រឺស្ករសក៏បាន , ស្ករអំពៅបន្ទះៗ ត្រូវយកកាំបិតស្អាតចិតអោយល្អិត , ទឹកឃ្មុំ , គ្រាប់ក្រវាញដែលបុកល្អិតផង់ និងផ្លែជីប្លីក្រៀមដែលបុកល្អិតផង់ដែរ , (ផង់គ្រាប់ក្រវាញ និងផង់ផ្លែជីប្លីទាំង ២ មុខនេះ យកតែ



www.elibraryofcambodia.org

បន្តិច១ កុំអោយច្រើនហួសប្រមាណ) . អោយមានអំបិលផង តែបន្តិចបាន ហើយ។ ត្រូវយកគ្រឿងទាំងអស់នេះផ្សំជាមួយនឹងអង្ករដំណើបដែលបកហើយ នោះ ដាក់ក្នុងខ្ទះហើយលាយទឹកអោយល្មមមធុបាយាសនោះឡើងទឹកខាប់ . កាលបើឆ្អិនស្រេចហើយ អោយល្មមពូតជាពំនូតបាន។ ការចំអិននេះ ត្រូវ អោយនាងកញ្ញា ២ នាក់ជាអ្នកចំអិន , អោយកូរបង្វិលជាទក្ខិណាវត្ត គឺកូរ អោយវិលពីស្តាំទៅឆ្វេង (ដូចគេដើរប្រទក្សិណអ្វី១ដែរ)។ ត្រូវកូរបណ្តើរមើល ថែភ្លើងបណ្តើរ កុំអោយភ្លើងដែលដុតច្បូងនោះឆេះខ្លាំង គឺត្រូវបន្ថយភ្លើងជា ដរាប។ ត្រូវចំអិនដោយប្រយ័ត្នជានិច្ច កុំអោយមធុបាយាសនោះមានក្លិនឆ្អៀម រឺខ្លោច។ នៅពេលកំពុងចំអិននោះ ត្រូវមានបុរស ៤ នាក់ ដែលតែងខ្លួនធ្វើជា លោកបាលមហារាជទាំង ៤ ដើរប្រទក្សិណក្រលឹងជុំវិញព្រះរាជវ័តិ . ដើរក្រលឹង ច្រើនបកច្រើនសា ត្រាតែមធុបាយាសនោះឆ្អិនស្រេចដោយប្រពៃ។ លុះ មធុបាយាសនោះឆ្អិនស្រេចហើយ , នៅពេលដែលអរុណ ១៥ កើត ខែពិសាខរះ ភ្លឺច្បាស់ , នាងកញ្ញាទាំង ២ នាក់នោះ ដួសដោះមធុបាយាសដាក់ក្នុងចានគ្រប ពិសេស ហើយតំកល់ចានលើតោកទឹបមាស រឺតោកដាំខ្យង រឺក៏ដាំកញ្ចក់ , ពុំ នោះ ទោះតំកល់លើពានជំទើរក៏បាន , ប្រសិនបើមានចានមាស រឺចានប្រាក់ កាឡៃមាស ក៏ជាការប្រពៃណាស់ សមនឹងលំអានរឿងថា " ភាជនីមាស " ពុំ ចាំបាច់តំកល់លើតោក រឺពានជំទើរឡើយ។ ត្រូវនាងកញ្ញាម្នាក់ទូលមធុបាយាស ដើរមុន (សន្មត់នាងនេះថា នាងសុជាតា បុត្រីនៃសេនកុដុម្ពីក៏នៅសេនានិគម ឧរុវេលា). នាងកញ្ញាម្នាក់ទៀតដើរក្រោយបន្ទាប់គ្នា ឥតទូលរឺកាន់អ្វីទេ (សន្មត់ថា នាងបុណ្ណា ជាទាសីនៃនាងសុជាតា)។ កញ្ញាម្នាក់នេះដើរសំរៀម១ មិនរលេះរលាំងទេ។ រីស្ត្រីទាំងអស់ក្រៅពីកញ្ញាទាំង ២ នាក់នោះ ត្រូវដើរហែ



www.elibraryofcambodia.org

ពីក្រោយ អោយឃ្លាតឆ្ងាយបន្តិច។ លុះកញ្ញាទាំង ២ នាក់បានមកដល់ទីតាំងលំ ព្រះពុទ្ធរូបអង្គថ្មី , ក៏ដាក់មធុបាយាសចំពោះព្រះភក្រ្តព្រះពុទ្ធរូប , លុតជង្គង់ក្រាបថ្វាយបង្គំ ហើយលើកហត្ថាប្រណម្យ បញ្ចេញវាចាថ្វាយមធុបាយាសថា **ខ្ញុំម្ចាស់សូមថ្វាយមធុបាយាសនេះ ចំពោះព្រះភគវ័ត ! សូមទ្រង់ទទួលដោយសេចក្តីអនុគ្រោះ !**

នេះជាពិធីចំអិន និងការថ្វាយមធុបាយាស ។

លុះដល់ពេលព្រលប់ថ្ងៃ ១៥ កើត ខែពិសាខ , ពុទ្ធបរិស័ទត្រូវធ្វើពិធីពុទ្ធាភិសេកតាមលំដាប់ទៅ រហូតដល់អរុណោទ័យនៃថ្ងៃ ១ រោច។ នៅថ្ងៃ ១ រោច ខែពិសាខនោះឯង , ពុទ្ធបរិស័ទត្រូវធ្វើពិធីឆ្លងបុណ្យពុទ្ធាភិសេក ពាមគួរដល់សទ្ធាជ្រះថ្លា , ដោយការអង្គាសចង្ហាន់ព្រឹក និងថ្ងៃត្រង់ ប្រគេនព្រះសង្ឃជាទក្ខិណាសង្ឃគតាទាន និងការនិមន្តព្រះធម្មកថិក សំដែងធម៌ក្នុងថ្ងៃនោះផងទៀតក៏បាន ។

គួរពុទ្ធមាមកជនជ្រាបថា ពិធីបែបនេះ ពុំមែនងាយធ្វើកើតទេ , បើបែរជាធ្វើកើត , ក៏ជាបុណ្យកុសលពិសេស គួររីករាយណាស់។ ប៉ុន្តែផ្ទុយទៅវិញ , បើពុំបានគិតរិះរអោយម៉ត់ចត់ល្អិតល្អន់អំពីចេតនានៃអ្នកធ្វើពិធីបែបនេះទេ , ក៏បែរជារកកល់នឹងយល់ឃើញថា ប្រហែលគ្នា រឺដូចគ្នានឹងរឿងល្ខោន រឺរឿងភាពយន្តទៅវិញទេដឹង ? - ឯតាមការពិត , ពុំមែនដូចនោះឡើយ ព្រោះពិធីពុទ្ធាភិសេកបែបនេះកើតមានឡើងអំពីចេតនា ជាកាមាវចរកុសលសុទ្ធសាធ។ បើពុទ្ធបរិស័ទអាចធ្វើបាន ក៏គួរធ្វើចុះ !



www.elibraryofcambodia.org

១. កុំយកកន្ទ្រើកាំបិតកោរវាសជន្លហាក់ដូចជាកាត់ព្រះកេសាព្រះ ដ្បិតព្រះពុទ្ធរូបអង្គថ្មីនោះជាងគេសាងរួចសព្វគ្រប់ស្រេចហើយ ។

២. កុំប្រើពិធីបើកព្រះនេត្រព្រះ ដ្បិតព្រះពុទ្ធអង្គថ្មីនោះជាងគេសាងអោយមានព្រះនេត្រទាំង ២ ស្រេចទៅហើយ ។

៣. កុំយកអំបោះចងព្រះពុទ្ធរូបចាស់ ទាញមកទាក់ភ្ជាប់នឹងព្រះពុទ្ធរូបថ្មី ដ្បិតអំបោះនោះពុំអាចស្រូបយកបារមីទាំង ៣០ ពីព្រះចាស់មកព្រះថ្មីទេ។ ការយល់របស់អ្នកខ្លះដែលធ្លាប់តែធ្វើយ៉ាងនេះ លើសពីការពិតឆ្ងាយណាស់ . ពុំគួរធ្វើដូចនេះឡើយ ។

៤. ដុតធូបថ្វាយព្រះ ត្រូវដុតថ្វាយដោយគោរព , កុំដុតអោយទាល់តែហុយផ្សែងទ្រុបទៅលើព្រះ ។

៥. កុំអោយមនុស្សអ្នកក្រមាច់កំប្លែង រឺមនុស្សកំពុងស្រវឹងស្រា តែងខ្លួនធ្វើជាទេវបុត្តមារ មកស្រែកតំរាមព្រះ ដោយសំដែងកាយវិការ និងសំដីពុំគោរពទៅរកព្រះឡើយ ។

៦. ពិធីណាក៏ដោយ ដទៃក្រៅពីពិធីផ្លូវខាងលើនេះ ក៏ពុទ្ធបរិស័ទពុំត្រូវធ្វើពិធីនោះឡើយ ដ្បិតជា **ពុទ្ធេ អគារវតា** " ការមិនគោរពចំពោះព្រះពុទ្ធ " ទៅវិញ។ បើមិនគោរពចំពោះព្រះពុទ្ធហើយ ក៏ឈ្មោះថាមិនគោរពព្រះធម៌ និងព្រះសង្ឃដែរ។ ( គួរយើងគោរពអោយសមឋានៈជាពុទ្ធសាសនិកជន) ។



www.elibraryofcambodia.org